សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

University Royale de Droit et des Sciences Economies

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ទម្រង់មតកសាសន៍

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុន ឆ្នាំ២០២១

ស្រាវជ្រាវដោយនិស្សិតឈ្មោះ

ឈ្មោះនិស្សិត៖ **ក. ជា ទឹមដាលីស**

**ក. ម៉ាប់ ប្រាស**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត៖ **ព្រុំ រិទ្ធី**

ថ្នាក់បរិញ្ញាបត្រ៖ **នីតិសាស្ត្រ**

ជំនាន់ទី៖ ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្ដីថ្លែងអំណរគុណ

ក្រុមនាងខ្ញុំឈ្មោះ **ជា ទឹមជាលីស** និង **ម៉ាប់ ប្រាស** ជានិស្សិតសិក្សាថ្នាក់ L4B2 ផ្នែកបរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី២១ ឆ្នាំសិក្សា ២០១៧ - ២០២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមគោរពការដឹងគុណយ៉ាងច្រើនអនេកចំពោះ**

លោកឪពុក៖ **ជា អមរិទ្ធ** ព្រមនិងអ្នកម្ដាយ៖ **យ៉េម សាឃឿន**

លោកឪពុក៖ **ចាន ម៉ាប់** ព្រមនិងអ្នកម្ដាយ៖ **ភឿន ចាន់ថា**

ដែលបានផ្ដល់កំណើត និងចិញ្ចឹមបីបាច់ថែក្សាតាំងពីកូនៗមិនទាន់ដឹងក្ដីរហូតដល់ធំប្រកបដោយព្រហ្មវិហារធម៌ អប់រំប្រៀនប្រដៅកូនៗឲ្យក្លាយជាមនុស្សល្អក្នុងសង្គម ផ្ដល់នូវសេចក្ដីស្រឡាញ់យ៉ាងជ្រាលជ្រៅដែលមិនអាចកាត់ថ្លៃបាន ព្រមទាំងទំនុកបំរុងជាសម្ភារៈ និងថវិកាគ្រប់បែបគ្រប់យ៉ាងដល់កូន។ លោកទាំងទ្វេជាមនុស្សដែលហ៊ានលះបង់ ខិតខំតស៊ូ ព្យាយាមអំណត់គ្រប់បែបយ៉ាង ដើម្បីឲ្យកូនទទួលបានការអប់រំៗ ដែលជាស្ពានឆ្ពោះទៅរកអនាគតដ៏ល្អ ដោយមិនគិតពីការលំបាករបស់ខ្លួនឡើយ។

សម្រាប់នាងឈ្មោះ៖ ម៉ាប់ ប្រាស ដែលជានិស្សិតទទួលបានអាហារូបករណ៍ពេញពីអង្គការ **អប់រំផ្នែកច្បាប់សម្រាប់ស្ត្រីនៅកម្ពុជា** (CLEW) សូមថ្លែងអំណរគុណយ៉ាងក្រៃលែងដែលបានផ្ដល់ឱកាសមួយនេះដល់នាងខ្ញុំ បានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនេះផងដែរ។

ក្រៅពីនេះក្រុមនាងខ្ញុំសូមថ្លែងអំណរអគុណដល់ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងសាស្ត្រាចារ្យ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចំណាយពេលវេលា កម្លាំងកាយចិត្ត បង្ហាត់បង្រៀន ផ្ទេរនូវចំណេះដឹងដោយមិនលំអៀងដល់និស្សិតគ្រប់ៗគ្នាក្នុងវិស័យច្បាប់។

**ក្រុមនាងខ្ញុំសូមថ្លែងអំណរអគុណជាពិសេសចំពោះ**

លោកសាស្ត្រាចារ្យបណ្ឌិត **ព្រុំ រិទ្ធី** ដែលជាសាស្ត្រាចារ្យណែនាំសម្រាប់ការតាក់តែងសារណាមួយនេះឡើង ដោយលោកបានចំណាយពេលវេលាយ៉ាងមានតម្លៃរបស់លោក ក្នុងការជួយជ្រោមជ្រែង ផ្ដល់យោបល់ដែលជាអនុសាសន៍ល្អៗ និងកែសម្រួលនូវកំហុសខុសឆ្គងទាំងឡាយដូចជា ខ្លឹមសារ អក្ខរាវិរុទ្ធ ដើម្បីឲ្យទទួលបាននូវលទ្ធផលល្អក្នុងការសរសេរសារណានេះឡើងមក។

ជាចុងបញ្ចាប់យើងខ្ញុំសូមគោរពជូនពរ លោកឪពុកអ្នកម្ដាយ លោកសាស្ត្រាចារ្យបណ្ឌិត **ព្រុំ រិទ្ធី** និងលោក / លោកស្រីសាស្ត្រាចារ្យ ទាំងឡាយ ឲ្យជួបតែសេចក្ដីសុខ ចម្រើន អាយុ វណ្ណៈ សុខៈ ពលៈ តរៀងទៅ។

# អារម្ភកថា

ក្នុងនាមក្រុមនាងខ្ញុំជានិស្សិតដែលបានសិក្សា ផ្នែកនីតិសាស្ត្រ ក្នុងរយៈពេលបួនឆ្នាំកន្លងមកនេះបានសម្រេចចិត្តជ្រើសរើសយក "**ទម្រង់មតកសាសន៍**" ដែលផ្នែកមួយនៃមេរៀនសន្តតិកម្មតាមមតកសាសន៍មកធ្វើកិច្ចការស្រាវជ្រាវសម្រាប់បញ្ចប់ការសិក្សា។ ក្រុមនាងខ្ញុំបានធ្វើការខិតខំសហការគ្នាបានយ៉ាងល្អក្នុងការស្រាវជ្រាវ និងធ្វើការចងក្រងនូវសៀវភៅសារណានេះឡើង ដើម្បីរួមចំណែកផ្តល់ជាចំណេះដឹងសម្រាប់និស្សិតជំនាន់ក្រោយអាចយកធ្វើការសិក្សារៀនសូត្រ ស្រាវជ្រាវបន្ថែម។

ប្រធានបទមួយនេះ បានធ្វើការឆ្លុះបញ្ចាំងអំពីប្រភេទនៃលិខិតគតិយុត្តមួយប្រភេទដែលធ្វើឡើង ដើម្បីបង្ហាញបំណងចុងក្រោយ ឬឆន្ទៈរបស់មតកជនក្នុងការបែងចែកទ្រព្យសម្បត្តិរបស់ខ្លួន និងចង់ឆ្លុះបញ្ចាំងឲ្យកាន់តែច្បាស់ពីការយល់ដឹងទាក់ទងនឹងទម្រង់លិខិតមតកសាសន៍ ក៏ដូចការរួមចំណែកកាត់បន្ថយជម្លោះក្នុងសង្គមចំពោះការបែងទ្រព្យសម្បត្តិក្រោយមរណភាពរបស់ម្ចាស់បណ្តាំ ។

ក្រុមនាងខ្ញុំទាំងពីរនាក់ ពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងក្នុងការសរសេរប្រធានបទមួយនេះ ព្រមទាំងទទួលបាននូវបទពិសោធន៍ថ្មីៗ ការខិតខំស្វះស្វែងរកនូវប្រភពឯកសារនានា កម្រងច្បាប់គតិយុត្តទាំងឡាយណាដែលទាក់ទិននឹងប្រធានបទនៃកិច្ចការស្រាវជ្រាវនិងបង្កើនចំណេះដឹងបន្ថែមទៀត។

យើងខ្ញុំសូមគោរព និងអរគុណលោកសាស្ត្រាចារ្យបណ្ឌិត **ព្រុំ រិទ្ធី** ដែលបានខិតខំក្នុងការបង្រៀន និងជួយណែនាំក្នុងការចងក្រងសៀវភៅសារណាបញ្ចប់ឆ្នាំសិក្សា ដើម្បីជំរុញដំណើរទៅបានយ៉ាងរលូន និងសម្រេចដោយជោគជ័យ ទោះបីស្ថិតក្នុងកាលៈទេសៈដ៏លំបាក នៃការឆ្លងរាលដាលយ៉ាងរបស់ វីរុសកូវីដ១៩ និងមានការរក្សាគម្លាតសង្គម ដើម្បីរក្សាសុវត្ថិភាពសម្រាប់ទាំងអស់គ្នា។ បន្ថែមពីនេះទៀតក៏សូមអរគុណទៅដល់ដៃគូសរសេរសារណាផងដែរក្នុងការខិតខំស្វះស្វែង សហការគ្នាបានយ៉ាងល្អ និងចេះផ្លាស់ប្តូរគំនិតគ្នាទៅវិញទៅមករហូតឈានដល់ការសម្រេចសម្មិផលនៃសារណាមួយនេះ ។

យើងខ្ញុំសូមអភ័យទោស ចំពោះការខ្វះខាតនានាដោយប្រការណាមួយ និងការធ្វេសប្រហែសត្រង់ចំណុចណាមួយដោយអចេតនាពីយើងខ្ញុំទាំងពីរនាក់។

ជាចុងបញ្ចប់ក្រុមនាងខ្ញុំរីករាយ និងទទួលស្វាគមន៍ជានិច្ចចំពោះការរិះគន់ក្នុងន័យស្ថាបនាទាំងឡាយណាពីសំណាក់អ្នកអានទាំងអស់គ្នា និងសូមធ្វើការអរគុណចំពោះអ្នកសិក្សាស្រាវជ្រាវទាំងអស់គ្នាដែលបានអានសមិទ្ធផលបញ្ចប់ឆ្នាំសិក្សាមួយនេះ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........................................ ១

## ជំពូកទី១

## លក្ខខណ្ឌសុពលភាពនៃមតកសាសន៍

**ផ្នែកទី១ ៖ លក្ខខណ្ឌគ្រឹះនៃមតកសាសន៍** ........................................ ៥

**កថាខណ្ឌទី១៖ សមត្ថភាពក្នុងការធ្វើមតកសាសន៍** ........................................ ៥

១.បុគ្គលដែលអាចក្លាយជាមតកជន........................................៥

២. សមត្ថភាពខាងស្មារតីរបស់មតកជន........................................៦

**កថាខណ្ឌទី២ ៖ ខ្លឹមសារនៃលិខិតមតកសាសន៍** ........................................ ៧

១. ការកំណត់ចំណែកមត៌ក........................................៧

១.១. វិធីកំណត់ចំណែកមត៌កតាមភាគ........................................៨

១.២. វិធីកំណត់ចំណែកមត៌កតាមទ្រព្យសម្បត្តិជាក់ស្តែង........................................៨

២. ការកំណត់វិធីបែងចែកមត៌ក........................................៨

២.១. ការកំណត់បែងចែកមត៌កដោយមតកជន........................................៨

២.២. មតកជនធ្វើការហាមឃាត់ការបែងចែកមត៌ក........................................៩

៣. ការផ្តាច់មត៌កពីជនដែលសន្មតថាជាសន្តតិជន........................................៩

៣.១. ការផ្តាច់មត៌កតាមខ្លឹមសារនៃមតកសាសន៍........................................៩

៣.២. ការផ្តាច់មត៌កតាមការដាក់ពាក្យសុំទៅតុលាការ........................................១០

៤. អច្ច័យទាន........................................១០

៤.១. អច្ច័យទានសកល........................................១០

៤.២. អច្ច័យទានមានកំណត់........................................១១

៥. គោលបំណងផ្សេងៗរបស់មតកជន..........................................................................................១១

**កថាខណ្ឌទី៣៖ កាលបរិច្ឆេទ និងហត្ថលេខា** ................................................................ ១១

១. កាលបរិច្ឆេទ............................................................................................................១១

២. ហត្ថលេខា..............................................................................................................១២

**កថាខណ្ឌទី៤៖ សាក្សី** ................................................................................................ ១២

១. សាក្សី.....................................................................................................................១២

១.១. បុគ្គលអសមត្ថភាព អនីតិជន ឬជនស្ថិតអាណាព្យាបាលទូទៅ................១៣

១.២. បុគ្គលដែលជាសន្តតិជនអច្ច័យលាភីសហព័ទ្ធនិងញាតិលោហិតខាងផ្ទាល់.១៣

១.៣. សារការី សហព័ទ្ធរបស់សារការី ញាតិលោហិតរបស់សារការី ក្រឡាបញ្ជី និងនិយោជករបស់សារការី.............................................................................១៣

**ផ្នែកទី២ ៖ ទម្រង់លិខិតមតកសាសន៍**............................................................................១៤

**កថាខណ្ឌទី១៖ ទម្រង់មតកសាសន៍ក្នុងស្ថានភាពទូទៅ ឬ ធម្មតា**.................១៥

១. មតកសាសន៍ជាលិខិតយថាភូត....................................................................................១៥

២. មតកសាសន៍ជាលិខិតឯកជន.......................................................................................១៦

៣. មតកសាសន៍ជាលិខិតសម្ងាត់.......................................................................................១៧

**កថាខណ្ឌទី២៖ មតកសាសន៍ស្ថិតក្នុងស្ថានភាពពិសេស**...............................១៩

១. មតកសាសន៍ជនដែលស្ថិតក្រោមអាណាព្យាបាលទូទៅ...................................................១៩

២. មតកសាសន៍ជនកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត...............................២០

៣. មតកសាសន៍ជនជាប់ឃុំឃាំង ឬជនជាប់ក្នុងនាវា យន្តហោះ..................................២១

៤. មតកសាសន៍ជនជាតិខ្មែររស់នៅបរទេស.........................................................................២៣

៥. មតកសាសន៍ជនមិនអាចនិយាយបាន.............................................................................២៣

# ជំពូក២
# អានុភាព ការប្រតិបត្តិ និង ការលុបចោល នៃមតកសាសន៍


**ផ្នែកទី១៖ អានុភាពនៃមតកសាសន៍**....................................................................២៥

**កថាខណ្ឌទី១៖ ពេលដែលមតកសាសន៍បង្កើតអានុភាព**................................២៥

១. មរណភាពរបស់ម្ចាស់បណ្តាំ.................................................................. ២៦

២. មតកសាសន៍ដែលភ្ជាប់លក្ខខណ្ឌបង្អង់...................................................... ២៦

៣. ការប្រកាសពីការបាត់ខ្លួន.......................................................................២៧

**កថាខណ្ឌទី២៖ អានុភាពនៃការកំណត់ចំណែកមត៌ក**....................................២៨

**ផ្នែកទី២៖ ការប្រតិបត្តិមតកសាសន៍**....................................................................២៩

**កថាខណ្ឌទី១៖ ការពិនិត្យបញ្ជាក់ និង ការបើកលិខិតមតកសាសន៍**..............២៩

១. តុលាការដែលមានសមត្ថកិច្ចខាងលំនៅឋាន.................................................... ២៩

២. លិខិតមតកសាសន៍ជាយថាភូតដែលតម្កល់នៅសារការី...................................... ៣០

**កថាខណ្ឌទី២៖ ការជ្រើសរើសអ្នកប្រតិបត្តិមតកសាសន៍**.............................. ៣០

១. ការកំណត់អ្នកប្រតិបត្តិដោយម្ចាស់បណ្តាំ.......................................................... ៣១

១.១. ការកំណត់អ្នកប្រតិបត្តិដោយម្ចាស់បណ្តាំនៅក្នុងមតកសាសន៍............... ៣១

១.២. ការប្រគល់អាណត្តិទៅឲ្យតតិយជនជាអ្នកកំណត់អ្នកប្រតិបត្តិ................ ៣១

១.៣. ការជ្រើសរើសដោយតុលាការ........................................................ ៣២

២. ជនដែលមិនអនុញ្ញាតឲ្យក្លាយជាអ្នកប្រតិបត្តិមតកសាសន៍...................................៣២

៣. តួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍............................................................. ៣៣

៤. ការចំណាយសម្រាប់មតកសាសន៍..................................................................៣៣

៤.១. សោហ៊ុយនៃការប្រតិបត្តិមតកសាសន៍............................................... ៣៤

៤.២. កម្រៃអ្នកប្រតិបត្តិមតកសាសន៍........................................................ ៣៤
ក. ការប្រតិបត្តិដោយយកកម្រៃ......................................................៣៤
ខ. ការប្រតិបត្តិដោយមិនយកកម្រៃ................................................. ៣៥
៥. ការបញ្ចប់មុខងារអ្នកប្រតិបត្តិមតកសាសន៍...................................................... ៣៥
៥.១. សិទ្ធិជ្រើសតាំងបន្ត........................................................................៣៥
៥.២. ការលាឈប់ដោយខ្លួនឯង................................................................ ៣៦
៥.៣. ការបញ្ឈប់តួនាទីអ្នកប្រតិបត្តិមតកសាសន៍ដោយសន្តតិជន.....................៣៦
**ផ្នែកទី៣. ការលុបចោលនូវមតកសាសន៍** ..........................................................៣៧
**កថាខណ្ឌទី១៖ ការលុបចោលមតកសាសន៍តាមលិខិតមតកសាសន៍**...........៣៧
**កថាខណ្ឌទី២៖ ការលុបចោលមតកសាសន៍តាមច្បាប់កំណត់** ..................... ៣៨
១. ម្ចាស់បណ្តាំចាត់ចែងពេលនៅមានជីវិត.............................................................៣៨
២. ការលុបចោលដោយការបដិសេធលិខិតមតកសាសន៍..........................................៣៩
៣. ការលុបចោលអច្ច័យទានជាប់បន្ទុក...................................................................៤០
**សេចក្តីសន្និដ្ឋាន**..............................................................................................៤១
**អនុសាសន៍**......................................................................................................៤២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ជាក់ស្តែងនៅជីវិតមនុស្សម្នាក់ៗនៅពេលដែលរស់រានមានជីវិត គឺពិតខិតខំប្រឹងប្រែងក្នុងការស្វែងរកនូវទ្រព្យសម្បត្តិ មាស ប្រាក់ ដីធ្លី ផ្ទះសម្បែងជាដើម ហើយទទឹមនឹងនោះផងដែរ ក៏មានទ្រព្យអកម្មមួយចំនួនដូចជាបំណុលជាអាទិ៍ផងដែរ។ ហើយនៅពេលដែលបុគ្គលនោះបានទទួលមរណភាពទៅ ទ្រព្យសម្បត្តិ និងបំណុលទាំងនោះត្រូវធ្លាក់ទៅឲ្យញាតិរបស់បុគ្គលនោះ ហើយញាតិរបស់បុគ្គលនោះនិងធ្វើការចាត់ចែង និងបែងចែកទ្រព្យសម្បត្តិរបស់ជនដែលស្លាប់នោះ។ សកម្មភាពក្នុងការបែងចែកនិងចាត់ចែងទ្រព្យសម្បត្តិត្រូវបានកំណត់ថាជាសន្តតិកម្ម។ ជាការពិតសន្តតិកម្មនោះមានតាំងសម័យបុរាណមកម្ល៉េះ។ ក្នុងរឿងព្រេងខ្មែរក៏មានលើកយកការផ្ទេរទ្រព្យសម្បត្តិនេះមកបង្ហាញដែរ ដូចជានៅក្នុងរឿង "កូន៤នាក់មិនបានបម្រើឪពុក" នៅក្នុងរឿងនោះបានឆ្លុះបញ្ចាំងអំពីការបែងចែកទ្រព្យសម្បត្តិកាលពីសម័យបុរាណកាល គឺកាលពីនៅរស់ឪពុកបានធ្វើការបែងចែកមត៌ករបស់គាត់ទៅឲ្យកូននីមួយៗគ្រប់ៗគ្នា ក្រោយពីធ្វើការបែងចែកទ្រព្យសម្បត្តិរួចរាល់ កូននីមួយៗរបស់គាត់មិនបានមើលថែរក្សាគាត់នោះទេ គាត់បានរកឃើញល្បិចមួយដោយយកពាងកាកសំណល់របស់គាត់ទៅកប់ក្រោមផ្ទះរបស់គាត់ ដោយគាត់បាននិយាយថា ប្រសិនបើកូនណាម្នាក់បានមើលថែមុនពេលស្លាប់ និងធ្វើបុណ្យសពជូនគាត់ពេលដែលគាត់ស្លាប់ទៅនឹងទទួលបានទ្រព្យសម្បត្តិនៅក្នុងពាងដែលគាត់បានកប់។ ដោយសារតែចង់បានទ្រព្យសម្បត្តិកូននីមួយៗបានមើលថែ និងធ្វើពិធីបុណ្យសពជូនគាត់យ៉ាងអធិបអធម ក្រោយពីបានធ្វើពិធីបុណ្យរួចរាល់ហើយកូននីមួយៗ ក៏បានយកពាងដែលឪពុកកប់ទុកដែលជាសន្តតិកម្មទុកក្រោយដែលនៅសល់នោះមកបើក ដើម្បីធ្វើការបែងចែកគ្នា។[1] ចំណែកឯក្នុងរឿង "តេជោយ៉ត" ដែលមានតួអង្គតេជោមាសជាមេទ័ពដែលមានសមត្ថភាពដ៏ខ្លាំងក្លា និងពូកែ ហើយគាត់មានកូនសិស្សជំនិតគឺ យ៉ត ហើយតែងតែនាំទៅធ្វើសង្គ្រាមជាមួយ លុះពេលដែលតេជោមាសទទួលមរណភាពទៅ នាយយ៉តបានទទួលមុខតំណែងដែលជាមេទ័ពក្នុងការដឹកនាំទ័ពធ្វើសង្គ្រាមជំនួសតេជោមាស។ ក្នុងរឿងនេះ គឺបានបង្ហាញពីតេជោយ៉តបានស្នងតំណែងបុណ្យសក្តិរបស់តេជោមាសដែលជាគ្រូរបស់ខ្លួនដែលប្រៀបបីដូចជា ឪពុកបង្កើត ព្រោះតេជោមាសពុំមានកូនឡើយ ហើយយ៉ត គឺជាកូនសិស្សតែម្នាក់គត់ដែលស្រលាញ់ និងទុកចិត្តដូចកូនបង្កើត ថ្វីត្បិតតែតេជោយ៉តជា

[1]ពុទ្ធសាសនបណ្ឌិត្យ, *ប្រជុំរឿងព្រេងខ្មែរ ភាគទី១* បោះពុម្ពផ្សាយឡើងវិញតាមច្បាប់ដើមដោយគ្រឹះស្ថានបោះពុម្ព និងចែកចាយនៃក្រសួងអប់រំ យុវជន និងកីឡា , (ភ្នំពេញ៖ អប់រំ,២០០១),១៤-១៨។

កូនសិស្សពិតប្រាកដមែន ប៉ុន្តែតេជោមាសបានបង្ហាត់បង្រៀនពីសឹកសង្គ្រាមគ្រប់បែបយ៉ាងដល់យ៉ត ដូចមានបំណងចង់ឲ្យយ៉តបានបន្តតំណែងពីខ្លួន។[2]

ជាពិសេសនៅក្នុងសម័យបុរាណពុំមានទំនៀមទំលាប់ អំពីការបែងចែកទ្រព្យសម្បត្តិរបស់សហព័ទ្ធបានច្បាស់លាស់នោះទេ ពេលមានការបែងចែកទ្រព្យសម្បត្តិឲ្យសន្តតិកម្មតែមួយគត់នោះគឺកូន។ ហើយរបបសន្តតិ-កម្មនាសម័យបុរាណក៏មិនបានចែងច្បាស់លាស់អំពីវិធីក្នុងការបែងចែកទ្រព្យសម្បត្តិដែរ។

ដោយសារតែការអនុវត្តន៍តាមគ្នាជាបន្តបន្ទាប់នោះ ហើយទើបមានការលេចឡើងនូវក្រមរដ្ឋប្បវេណីនាឆ្នាំ១៩២០បានចែងពីសន្តតិកម្ម គឺជាការបញ្ជូនតាមច្បាប់នូវទ្រព្យរបស់អ្នកស្លាប់ ទៅឲ្យអ្នករស់ ឬ មត៌ក ឬទ្រព្យរបស់ខ្មោចដែលត្រូវបានទៅទាយាទ។ នៅក្នុងមាត្រានោះដដែលក៏បានចែងថា សន្តតិកម្មមាន២ប្រភេទ គឺសន្តតិកម្មមានបណ្តាំ និងសន្តតិកម្មឥតមានបណ្តាំ។ សន្តតិកម្មឥតបណ្តាំ គឺជាការផ្ទេរទ្រព្យសម្បត្តិតាមច្បាប់ ចំណែកឯសន្តតិកម្មតាមបណ្តាំ គឺជាការផ្ទេរទ្រព្យសម្បត្តិតាមឆន្ទៈរបស់ខ្មោច។[3] ក្រោយពីមានក្រមរដ្ឋប្បវេណីឆ្នាំ១៩២០មក ធ្វើឲ្យយើងដឹងថាការបែងចែកទ្រព្យសម្បត្តិកាលពីសម័យបុរាណមានភាពលំអៀងយ៉ាងពិតប្រាកដ ដោយសារតែការបែងចែកទ្រព្យសម្បត្តិនោះធ្វើតាមអារម្មណ៍របស់ម្ចាស់ទ្រព្យ ក្នុងករណីដែលចង់ប្រគល់ទ្រព្យសម្បត្តិនោះឲ្យទៅកូនដែលខ្លួនស្រលាញ់ច្រើនជាងគេ ចំណែកកូនដែលម្ចាស់ទ្រព្យមិនពេញចិត្តក៏មិនបានប្រគល់ទ្រព្យសម្បត្តិអ្វីសោះឡើយ ហេតុទាំងនេះហើយដែលសម្តែងឲ្យឃើញពីភាពលំអៀងនៅក្នុងការបែងចែកទ្រព្យសម្បត្តិនៅក្នុងសម័យបុរាណ ក្រោយពីមានការកែប្រែពីការប្រើប្រាស់ទំនៀមទំលាប់បុរាណក្នុងការបែងចែកទ្រព្យសម្បត្តិមកជាការអនុវត្តតាមក្រមរដ្ឋប្បវេណីឆ្នាំ១៩២០វិញ ធ្វើឲ្យមានការបែងចែកទ្រព្យសម្បត្តិទៅតាមច្បាប់កំណត់វិញ។

នៅឆ្នាំ១៩៧៥ ដោយសារតែភ្លើងសង្គ្រាមនាសម័យកម្ពុជាប្រជាធិបតេយ្យធ្វើឲ្យប្រទេសកម្ពុជាបាត់បង់ទាំងស្រុងនូវច្បាប់នានា រួមទាំងច្បាប់ស្តីពីសន្តតិកម្ម។ របបកម្ពុជាប្រជាធិបតេយ្យ គឺជារបបដល់ខ្មៅងងឹតមួយដែលប្រជាពលរដ្ឋមានការខ្លាចរអា ប្រទេសជាតិត្រូវទទួលរងនៅការខូចខាតយ៉ាងខ្លាំង។ ប្រជាជនគ្រប់រូបដែលធ្លាប់តែរស់នៅជួបជុំគ្នា មានកម្មសិទ្ធិ ប្រើប្រាស់ទៅលើទ្រព្យសម្បត្តិរបស់ខ្លួនដោយសេរី ត្រូវបានផ្លាស់ប្តូរមកជាគ្មានកម្មសិទ្ធិអ្វីទាំងអស់ ទ្រព្យសម្បតិត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់អង្គការ សូម្បីតែចាន ស្លាបព្រា ឆ្នាំងមិនមែនជាកម្មសិទ្ធិរបស់បុគ្គលណាម្នាក់ឡើយ គ្រួសារត្រូវបានរស់នៅបែកគ្នាតាមការចាត់ចែងរបស់អង្គការ។ របបកម្ពុជាប្រជាធិបតេយ្យ ជារបបដែលត្រូវបានកាត់ផ្តាច់នៅទំនាក់ទំនងបុគ្គលជាមួយគ្រួសារទាំងមូលបំបាត់នូវសេរី

[2] ទី ជីហួត, *រឿងតេជោយ៉ត*, បោះពុម្ពលើកទី២ (ភ្នំពេញ៖ ស្រី ប៊ុនដន,២០០៥)។

[3] មាត្រា៤៨៦ ក្រមរដ្ឋប្បវេណីចាស់, ឆ្នាំ១៩២០។

ភាពការបង្ហាញឆន្ទៈគ្រប់បែបយ៉ាង។ ចំពោះឃ្លាដែលអង្គការប្រើប្រាស់សម្គាល់សម្រាប់ការរស់រួមនោះគឺ ពាក្យ "*សមូហភាព*" ឃ្លានេះជាឃ្លាដែលប្រជាពលរដ្ឋមិនចង់ឮ នាពេលបច្ចុប្បន្ន (អ្នកឆ្លងកាត់របបនេះ) ពេលឮហើយគាត់មានអារម្មណ៍ថាសោកសៅយ៉ាងខ្លាំង គាត់បានមានប្រសាសន៍ថាសមូហភាព គឺមានន័យថាយើងគ្មានអ្វីដែលជារបស់ខ្លួនឡើយ។[4] អ្វីទាំងអស់ដែលមានក្នុងសម័យនោះសុទ្ធតែជាកម្មសិទ្ធរបស់អង្គការ (កម្មាភិបាលខ្មែរក្រហម)។[5]

តាមច្បាប់ភូមិបាល ពាក្យថាសន្តតិកម្មត្រូវបានឲ្យនិយមន័យថា ជាការផ្ទេរតាមច្បាប់នូវទ្រព្យរបស់អ្នកស្លាប់ឲ្យទៅអ្នករស់។ មត៌ក ឬ ទ្រព្យសម្បត្តិរបស់ខ្មោចដែលត្រូវបានទៅទាយាទ (អ្នកបន្តមត៌ក)។[6]

តាមក្រមរដ្ឋប្បវេណីថ្មីឆ្នាំ២០០៧ បានចែងពីសន្តតិកម្មគឺជាការផ្ទេរនូវសិទ្ធិនិងករណីយកិច្ចរបស់មតកជនទៅឲ្យសន្តតិជនម្នាក់ ឬ ច្រើននាក់តាមឆន្ទៈ ឬ តាមច្បាប់។[7] និយមន័យតាមច្បាប់បានផ្ដោតជាសំខាន់ទៅលើការផ្ទេរទ្រព្យ សិទ្ធិ និងករណីយកិច្ច។ ប៉ុន្តែតាមពិតពាក្យសន្តតិកម្មនេះមានន័យទូលំទូលាយជាងនេះទៅទៀត។ សន្តតិជន ឬ ទាយាទអាចទទួលបានមិនត្រឹមតែទ្រព្យសម្បត្តិ សិទ្ធិ និងករណីយកិច្ចប៉ុណ្ណោះទេ ថែមទាំងទទួលបាននូវអត្ថប្រយោជន៍នានាបន្ថែមមួយចំនួនទៀតពីមតកជន(អ្នកស្លាប់)។ មត៌កទាំងនោះក៏អាចជាមុខរបរ អំណាច សេដ្ឋកិច្ច (ការដឹកនាំក្រុមហ៊ុន) អំណាចវប្បធម៌ និងអំណាចនយោបាយជាដើម។ ជាមួយនេះក៏មានសន្តតិកម្មក្រៅបេតិកភណ្ឌដូចជា នាមត្រកូល សញ្ជាតិ និងសិទ្ធិសីលធម៌របស់អ្នកនិពន្ធ។ ប៉ុន្តែសេចក្ដីស្រលាញ់ដែលមតកជនបន្សល់ទុកដល់កូនៗ គឺជាមត៌កដែលមិនអាចកាត់ថ្លៃបានឡើយហើយមានតម្លៃខ្ពស់ជាងបេតិកភណ្ឌដែលមតកជនបន្សល់ទុកឲ្យកូនទៅទៀត។ បុព្វហេតុដែលនាំឲ្យកើតមានសន្តតិកម្ម គឺការទទួលមរណភាពរបស់មតកជន ក្នុងន័យនេះ គឺការដែលនាំឲ្យមានសន្តតិកម្ម គឺការស្លាប់របស់បុគ្គលណាម្នាក់ដែលជាម្ចាស់ទ្រព្យសម្បត្តិ។ សន្តតិកម្មត្រូវបានបែងចែកចេញជា២(ពីរ)ប្រភេទគឺ សន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាមឆន្ទៈរបស់ម្ចាស់បណ្ដាំ។ សន្តតិកម្មតាមច្បាប់ គឺជាការផ្ទេរទ្រព្យសម្បត្តិពីមតកជនទៅសន្តតិជនច្រើនរូបដោយមិនមានឆន្ទៈរបស់ម្ចាស់បណ្ដាំ ការចែកបែងនោះត្រូវធ្វើឡើងតាមច្បាប់ដែលបានកំណត់តែប៉ុណ្ណោះ។ បុគ្គលជាច្រើនរូបសុទ្ធតែអាចក្លាយសន្តតិជនក្នុងនោះរួមមានសហព័ទ្ធរបស់ម្ចាស់បណ្ដាំ កូនរបស់ម្ចាស់បណ្ដាំ ឪពុកម្ដាយ និងបងប្អូនរបស់មតកជន។ ចំណែកឯសន្តតិកម្មតាមឆន្ទៈរបស់ម្ចាស់បណ្ដាំ តាមន័យច្បាប់នោះគឺជា

[4] សម្ដីផ្ទាល់របស់ជនដែលធ្លាប់បានឆ្លងកាត់របបកម្ពុជាប្រជាធិបតេយ្យ (ខេត្តសៀមរាប)។

[5] របបកម្ពុជាប្រជាធិបតេយ្យ ១៧ មេសា ១៩៧៥- ០៧ មករា ១៩៧៩។

[6] មាត្រា១៧០, ច្បាប់ភូមិបាល ១០ សីហា ១៩៩២។

[7] សន្ទានុក្រមនៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

សន្តតិកម្មតាមមតកសាសន៍ ជាការផ្ទេរទ្រព្យសម្បត្តិពីមតកជនទៅសន្តតិជនតាមលិខិតបណ្តាំដែលកើតចេញពីឆន្ទៈរបស់ម្ចាស់បណ្តាំមុនពេលដែលទទួលមរណភាព។ បុគ្គលដែលអាចក្លាយជាសន្តតិជនក្នុងសន្តតិកម្មតាមមតកសាសន៍រួមមាន សហព័ន្ធរបស់មតកជន កូនរបស់មតកជន ឪពុកម្តាយ បងប្អូន ក្មួយរបស់មតកជន និងជនដែលមាននិស្ស័យពិសេសផងដែរ។ ភាពសំខាន់របស់សន្តតិកម្មតាមមតកសាសន៍ គឺជាការផ្ទេរទ្រព្យសម្បត្តិពីមតកជនទៅកាន់សន្តតិជនម្នាក់ៗដោយឆន្ទៈរបស់ម្ចាស់បណ្តាំ។ ចំណុចត្រង់នេះហើយ ដែលបង្ហាញថាការផ្ទេរទ្រព្យសម្បត្តិត្រូវបានកើតឡើងដោយមានការសម្រេចចិត្ត និងពេញចិត្តពីម្ចាស់បណ្តាំ ហើយម្ចាស់បណ្តាំក៏អាចសម្រេចបំណងចុងក្រោយរបស់ខ្លួនក្នុងការបែងចែកទ្រព្យសម្បត្តិ ទៅឲ្យសន្តតិកម្មរបស់ខ្លួនផងដែរ។ ក្នុងន័យនេះផងដែរ លិខិតមតកសាសន៍ គឺជាលិខិតឯកតោភាគីដែលកើតចេញពីឆន្ទៈរបស់មតកជនតែម្ខាងប៉ុណ្ណោះ ប៉ុន្តែអានុភាពរបស់វានោះគឺជាការផ្ទេរទ្រព្យសម្បត្តិចូលទៅក្នុងបេតិកភណ្ឌនៃអ្នកដែលត្រូវទទួល និងចាប់មានពីពេលដែលមតកជននោះបានទទួលមរណភាពទៅដោយមិនគិតពីឆន្ទៈយល់ព្រម ឬមិនយល់ព្រមពីអ្នកទទួលទ្រព្យសម្បត្តិនោះឡើយ។ ដើម្បីឲ្យសន្តតិកម្មតាមមតកសាសន៍មានអានុភាពពេញលេញម្ចាស់បណ្តាំនៃលិខិតមតកសាសន៍នោះត្រូវធ្វើលិខិតបណ្តាំស្របតាមទម្រង់នៃមតកសាសន៍ដែលច្បាប់បានកំណត់ (និងលើយកមកបង្ហាញយ៉ាងលំអិតនៅក្នុងកិច្ចការស្រាវជ្រាវ)។

ជាការពិតណាស់ ទោះបីជាមានការសិក្សាយ៉ាងលំអិតទៅអត្ថន័យរបស់លិខិតមតកសាសន៍ហើយក៏ដោយហាក់នូវតែពុំទាន់ មានភាពច្បាស់លាស់ក្នុងសិក្សាស្វែងយល់ពីលិខិតមតកសាសន៍នៅឡើយទេ។ ជាហេតុដែលនាំឲ្យមានការសិក្សាយ៉ាងលំអិត និងស៊ីជម្រៅបន្ថែមទៀតស្តីពី "**ទម្រង់នៃមតកសាសន៍**" ។ ជាហេតុដែលនាំឲ្យមានសំណួរមួយចំនួនលើកឡើងមកថា តើលិខិតមតកសាសន៍នោះមានលក្ខខណ្ឌប៉ុន្មានយ៉ាង? ហើយមានលក្ខខណ្ឌអ្វីខ្លះ? តើលក្ខខណ្ឌទាំងនោះមានអានុភាពយ៉ាងដូចម្តេច? ដើម្បីធ្វើឲ្យលិខិតមតកសាសន៍នោះមានអានុភាពយ៉ាងពេញបរិបូណ៌ តើត្រូវអនុវត្តយ៉ាងដូចម្តេច? តើកត្តាអ្វីខ្លះដែលនាំឲ្យមានការលុបចោលនូវលិខិតមតកសាសន៍?

ដើម្បីឆ្លើយតបទៅនិងសំណួរទាំងអម្បាលម៉ានខាងលើនេះ ជាដំបូងនឹងធ្វើការសិក្សាពីលក្ខខណ្ឌនៃលិខិតមតកសាសន៍ដែលបកស្រាយនៅក្នុងជំពូកទី១ និងធ្វើការអត្ថាធិប្បាយអំពីអានុភាព ការប្រតិបត្តិ និងការលុបចោលនៃមតកសាសន៍ក្នុងជំពូកទី២ផងដែរ។

# ជំពូកទី១

# លក្ខខណ្ឌសុពលភាពនៃមតកសាសន៍

# ជំពូកទី១

# លក្ខខណ្ឌសុពលភាពនៃមតកសាសន៍

មតកសាសន៍ គឺជាកិច្ចឯកតោភាគី ដូចនេះហើយទើបលិខិតមតកសាសន៍មានភាពដូចគ្នាទៅនឹងកិច្ចគតិយុត្តដទៃទៀតដែរ ដើម្បីបង្កើតអានុភាពតាមផ្លូវច្បាប់បាន ចាំបាច់ត្រូវគោរពតាមលក្ខខណ្ឌនីតិវិធីនៃការបង្កើត។ ជាគោលការណ៍ច្បាប់លក្ខខណ្ឌនៃការបង្កើតលិខិតគតិយុត្តមាន២យ៉ាងគឺ លក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់។ លក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់ជាអ្នកកំណត់ពីសុពលភាពនៃលិខិតគតិយុត្ត។ ជំពូកទី១នេះនឹងសិក្សាពី លក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់ដែលជាផ្នែកមួយនៃប្រធានបទស្តីពី "**ទម្រង់មតកសាសន៍**" ។

## ផ្នែកទី១ ៖ លក្ខខណ្ឌគ្រឹះនៃមតកសាសន៍

គ្រប់លិខិតបណ្តាំទាំងអស់ចាំបាច់ត្រូវគោរពតាម លក្ខខណ្ឌគ្រឹះជាមុន ដើម្បីឲ្យមានសុពភាពនៃលិខិតមតកសាសន៍ផ្នែកលក្ខខណ្ឌគ្រឹះ។ សម្រាប់ផ្នែកទី១នេះ នឹងធ្វើការបកស្រាយទៅលើលក្ខខណ្ឌគ្រឹះនៃលិខិតមតកសាសន៍ មាន៤កថាខណ្ឌមានដូចជា៖ កថាខណ្ឌទី១ សមត្ថភាពក្នុងការធ្វើមតកសាសន៍ កថាខណ្ឌទី២ ខ្លឹមសារនៃមតកសាសន៍ កថាខណ្ឌទី៣ កាលបរិច្ឆេទ និងហត្ថលេខា កថាខណ្ឌទី៤ សាក្សី ។

### កថាខណ្ឌទី១៖ សមត្ថភាពក្នុងការធ្វើមតកសាសន៍

បុគ្គលណាម្នាក់ដែលមានបំណងចង់បង្កើតលិខិតមតកសាសន៍ ត្រូវមានលក្ខខណ្ឌសមត្ថភាពដូចជា៖ ១.សមត្ថភាពនៃបុគ្គលដែលអាចក្លាយជាមតកជន និង ២. សមត្ថភាពខាងស្មារតីរបស់មតកជន។

#### ១. បុគ្គលដែលអាចក្លាយជាមតកជន

មិនមែនគ្រប់បុគ្គលទាំងអស់សុទ្ធតែអាចធ្វើលិខិតមតកសាសន៍បាននោះទេ មានតែបុគ្គលមួយចំនួនដែលបានកំណត់ដោយក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ ដែលមានសិទ្ធិក្នុងការធ្វើលិខិតមតកសាសន៍។[8]

បុគ្គលដែលអាចធ្វើលិខិតមតកសាសន៍បាននោះរួមមាន៖

នីតិជន គឺជាជនដែលមានអាយុគ្រប់១៨(ដប់ប្រាំបី)ឆ្នាំឡើងទៅ ដូចដែលក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់ ដោយមានការយល់ឃើញថា បុគ្គលដែលមានវ័យគ្រប់១៨(ដប់ប្រាំ)ឆ្នាំឡើងទៅ

[8] មាត្រា១១៦៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

មានសមត្ថភាពគ្រប់គ្រាន់ក្នុងការពិចារណា និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវរាល់អំពើរបស់ខ្លួនតាមផ្លូវច្បាប់។[9]

អនីតិជនដែលទទួលបានអត្តាធីនភាព គឺជាបុគ្គលដែលមិនទាន់មានអាយុគ្រប់១៨(ដប់ប្រាំបី)ឆ្នាំតាមច្បាប់បានកំណត់[10] ប៉ុន្តែពួកគេជាអនីតិជនដែលអាចមានសមត្ថភាពដូចនីតិជនដែរ ដោយផ្អែកទៅលើការទទួលបានអត្តាធីនភាព។ លក្ខខណ្ឌដែលអនីតិជនទទួលបានអត្តាធីនភាពមាន៖ អនីតិជនដែលមានអាយុដល់១៦(ដប់ប្រាំមួយ)ឆ្នាំ អាចទ្រទ្រង់ជីវភាពរស់នៅរបស់ខ្លួនឯងបានដោយឯករាជ្យ តុលាការនឹងប្រកាសពីអត្តាធីនភាពដែលអនីតិជនទទួលដោយស្របតាមផលប្រយោជន៍ និងតាមការដាក់ពាក្យសុំរបស់អនីតិជន ចំពោះករណីនេះ តុលាការត្រូវសួរយោបល់ពីអ្នកដែលមានអំណាចមេបាជាមុនសិន[11] និងអនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ស្របតាមផ្លូវច្បាប់ជាមួយនឹងនីតិជន ពួកគេនឹងទទួលបានអត្តាធីនភាពដោយស្វ័យប្រវត្តិ ទោះបីជាមានការលែងលះគ្នាកើតពេលក្រោយក៏ដោយអត្តាធីនភាពនេះមិនរលត់ដែរ។[12]

### ២. សមត្ថភាពខាងស្មារតីរបស់មតកជន

មតកជន គឺជាបុគ្គលដែលធ្វើលិខិតមតកសាសន៍ ឬជាម្ចាស់នៃលិខិតបណ្ដាំ។ មតកជនត្រូវមានសមត្ថភាពគ្រប់គ្រាន់នៅពេលធ្វើលិខិតមតកសាសន៍។ ត្រង់ចំណុចនេះចង់បញ្ជាក់ន័យថា បុគ្គលដែលអាចធ្វើលិខិតមតកសាសន៍បាន គឺត្រូវតែមានស្មារតីគ្រប់គ្រាន់អាចយល់ដឹង និងធ្វូលការវិនិច្ឆ័យពីទង្វើរបស់ខ្លួនបានតាមផ្លូវច្បាប់។ មតកជនមិនអាចធ្វើលិខិតមតកសាសន៍បានទេ ប្រសិនបើមតកជននោះស្ថិតក្នុងស្ថានភាពបាត់បង់ស្មារតីដោយសារគ្រឿងស្រវឹង ដោយការបង្ខិតបង្ខំដោយជនណាម្នាក់ ទទួលរងនូវការបោកប្រាស់ពីជនណាម្នាក់ ឬចាស់វង្វេងស្មារតីជាអាទិ៍។ នៅក្នុងស្ថានភាពទាំងអម្បាលម៉ានខាងលើនេះត្រូវចាត់ទុកថា ម្ចាស់បណ្ដាំគ្មានសមត្ថភាពគ្រប់គ្រាន់ក្នុងការវិនិច្ឆ័យយល់ដឹងពីភាពត្រឹមត្រូវ និងគ្មានបញ្ញាស្មារតីក្នុងការបង្កើតលិខិតមតកសាសន៍នោះទេ។ ដូចនេះលិខិតមតកសាសន៍នោះនិងចាត់ទុកជាមោឃៈ។ នៅពេលធ្វើមតកសាសន៍ម្ចាស់បណ្ដាំត្រូវតែមានស្មារតីគ្រប់គ្រាន់ និងមានសមត្ថភាពក្នុងការត្រិះរិះពិចារណាយ៉ាងម៉ត់ចត់ទើបអាចធ្វើការសន្និដ្ឋានថា លិខិតមតកសាសន៍ច្បាប់នោះបានកើតឡើងដោយឆន្ទៈរបស់មតកជនយ៉ាងពិតប្រាកដមែន។[13]

---

[9] សន្ទានុក្រម នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[10] មាត្រា ១៧ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[11] មាត្រា ២១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[12] មាត្រា ២១ កថាខណ្ឌទី២និងកថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[13] មាត្រា១១៦៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

ករណីមានបុគ្គលណាម្នាក់មកអះអាងថា មតកជន ខ្វះសមត្ថភាពក្នុងការបង្កើតលិខិតមតកសាន៍ នោះបុគ្គលដែលអះអាងត្រូវស្វែងរកភស្តុតាងមកបញ្ជាក់ឲ្យបានជាក់លាក់ អំពីហេតុដែលនាំឲ្យមតកជនខ្វះសមត្ថភាពកំឡុងពេលធ្វើលិខិតមតកសាសន៍។[14]

**កថាខណ្ឌទី២ ៖ ខ្លឹមសារនៃលិខិតមតកសាសន៍**

មតកជនអាចបង្ហាញឆន្ទៈគ្រប់យ៉ាងរបស់ខ្លួននៅក្នុងលិខិតមតកសាសន៍បាន ក្រៅពីការបែងចែកនូវទ្រព្យសម្បត្តិ ដូចជាការធ្វើបណ្តាំទាក់ទងនឹងការសំណូមពរ ការផ្តាំផ្ញើ ឬចេតនាចុងក្រោយរបស់ខ្លួន។ ចំពោះខ្លឹមសារនៃលិខិតមតកសាសន៍ មតកជនអាចសរសេរ៖ ១.ការកំណត់ចំណែកមត៌ក ២. ការកំណត់វិធីបែងចែកមត៌ក ៣.ការផ្តាច់មត៌កពីជនដែលសន្មតថាជាសន្តតិជន ៤.អច្ច័យទាន ៥.គោលបំណងផ្សេងៗរបស់ មតកជន។

**១. ការកំណត់ចំណែកមត៌ក**

មតកជនអាចធ្វើការកំណត់នូវចំណែកមត៌ករបស់សហសន្តតិជន និងអ្នកពាក់ព័ន្ធនឹងផលប្រយោជន៍តាមរយៈខ្លឹមសារក្នុងលិខិតមតកសាសន៍ដែលជនទាំងនោះនឹងត្រូវទទួលបាន។ ម្យ៉ាងវិញទៀត មតកជនអាចធ្វើការបង្ហាញឆន្ទៈរបស់ខ្លួនផ្ទុយពីបញ្ញត្តិស្តីពីចំណែកបុគ្គលដែលទទួលបានផលប្រយោជន៍ពិសេស។[15]

បុគ្គលណាម្នាក់ក្នុងចំណោមសហសន្តតិជនដែលបានទទួល ផលប្រយោជន៍ពិសេសដូចជា៖ ការទទួលបានទទួលប្រទានកម្ម ឬអច្ច័យទានពីមតកជន នៅក្នុងឱកាសអាពាហ៍ពិពាហ៍ដោយមតកជនបានចងជាចំណងដៃនៃអាពាហ៍ពិពាហ៍នោះ ឬបានផ្តល់ជាមូលធនក្នុងជីវិតរស់នៅដើម្បីធ្វើការរកស៊ី ឬវិនិយោអ្វីមួយ ឬតាមរយៈហេតុការណ៍ផ្សេងៗទៀត ដែលអាចកើតមាននៅក្នុងជីវភាពរស់នៅរបស់មតកជន និងសន្តតិជនដោយមានការបង្ហាញឆន្ទៈត្រឹមត្រូវពេលធ្វើសកម្មភាពនោះ ជាហេតុនាំឲ្យតម្លៃសរុបនៃមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្មដោយបូកបញ្ចូលនូវតម្លៃប្រទានកម្មត្រូវបានចាត់ទុកជាមត៌ក។[16]

បើតម្លៃប្រទានកម្ម ឬអច្ច័យទានស្មើគ្នានឹងតម្លៃនៃចំណែកមត៌ក ឬ លើសពីតម្លៃនៃចំណែកមត៌កទៀត សហសន្តតិជននោះពុំអាចទទួលយកចំណែកមត៌កបានឡើយ។ [17]

---

[14] មាត្រា១១៦៧ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[15] មាត្រា១១៨២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[16] មាត្រ ១១៦៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[17] មាត្រា១១៦៣ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

ការកំណត់ចំណែកមត៌កនេះ មិនអាចធ្វើការបំពានទៅលើភាគបម្រុងបាននោះទេ ដោយត្រូវអនុលោមតាមបញ្ញត្តិស្តីពីភាពបម្រុង។[18]

វិធីកំណត់ចំណែកអាចធ្វើទៅតាម២(ពីរ)របៀប៖

**១.១.វិធីកំណត់ចំណែកមត៌កតាមភាគ**

មតកជនអាចកំណត់មត៌ករបស់ខ្លួនជាភាគ ដោយប្រើការបែងចែកទ្រព្យសម្បត្តិជាភាគទៅឲ្យសន្តតិជនម្នាក់ៗ។ ឧទាហរណ៍៖ សុខជាមតកជន ដោយសន្តតិជនរបស់គាត់មាន ប្រពន្ធ និងកូនទាំងបីរបស់គាត់។ ដូចនេះកូនទាំងបីរបស់គាត់ទទួលបានចំណែក១/៤(មួយភាគបួន) ប៉ុន្តែគាត់បានកំណត់ឲ្យប្រពន្ធរបស់គាត់ទទួលបានចំណែក១/២(មួយភាគពីរ)។[19]

**១.២. វិធីកំណត់ចំណែកមត៌កតាមទ្រព្យសម្បត្តិជាក់ស្តែង**

មតកជនអាចធ្វើការបែងចែកនូវមត៌កទៅឲ្យសន្តតិជន តាមស្ថានភាពជាក់ស្តែងនៃទ្រព្យសម្បត្តិរបស់ខ្លួនដែលកំពុងតែមាន។ ឧទាហរណ៍៖ មតកជន មានផ្ទះមួយកន្លែង ដីមួយកន្លែងនិងលុយ១៥០,០០០$(ដប់ប្រាំម៉ឺនដុល្លារ)។ គាត់បានធ្វើការចែកផ្ទះទៅឲ្យប្រពន្ធរបស់គាត់ ដីចែកទៅឲ្យកូនស្រីរបស់គាត់ និងលុយ១៥០,០០០$(ដប់ប្រាំម៉ឺនដុល្លារ)ចែកឲ្យកូនប្រុសរបស់គាត់។[20]

**២. ការកំណត់វិធីបែងចែកមត៌ក**

លិខិតមតកសាសន៍ត្រូវបានទទួលស្គាល់ថា ជាលិខិតមួយដែលអាចឲ្យមតកជនធ្វើការកំណត់វិធីបែងចែកនៃមត៌ក។ ម្យ៉ាងវិញទៀត មតកជនក៏អាចធ្វើការប្រើប្រាស់ លិខិតមតកសាសន៍នេះក្នុងការហាមឃាត់បែងចែកនូវមត៌ករបស់ខ្លួនបាន ក្នុងរយៈពេលកំណត់មួយដូចនៅក្នុងក្រមរដ្ឋប្បវេណី។[21] ការកំណត់វិធីសាស្ត្រក្នុងការបែងចែកទ្រព្យសម្បត្តិ ការហាមឃាត់ការបែងចែកទ្រព្យសម្បត្តិ និងធ្វើការបកស្រាយដូចខាងក្រោម៖

**២.១. ការកំណត់វិធីបែងចែកដោយមតកជន**

មតកជនអាចបង្ហាញឆន្ទៈនៅក្នុងខ្លឹមសារនៃមតកសាសន៍ ដោយកំណត់នូវអ្វីដែលសន្តតិជនម្នាក់ៗនឹងត្រូវទទួលបាន។ ឧទាហរណ៍៖ មតកជនបានកំណត់ឲ្យសន្តតិជនទី១ ទទួលបានផ្ទះមួយកន្លែង សន្តតិជន

[18] មាត្រា១១៨២ វាក្យខណ្ឌទី២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[19] Ms. MIURA YASUKO, សិក្ខាសិលាស្តីពីសន្តតិកម្ម,ចំណុច៥.២, ១ ។

[20] Ms. MIURA YASUKO, សិក្ខាសិលាស្តីពីសន្តតិកម្ម, ចំណុច៥.២,២ ។

[21] មាត្រា១១៨៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៨។

ទី២ ទទួលបានឡាន៤(បួន)គ្រឿង សន្តតិជនទី៣ ទទួលបានលុយ២០០,០០០$(ម្ភៃម៉ឺនដុល្លារ)។ ម្យ៉ាងវិញទៀត មតកជនអាចធ្វើការបង្ហាញឆន្ទៈរបស់ខ្លួនផ្ទុយពីនេះក៏បាន ដោយកំណត់វិធីបែងចែកដោយគិតទៅតាមភាគនៃមត៌កទាំងអស់ ឬមួយផ្នែកចំពោះសន្តតិជនម្នាក់ ឬច្រើននាក់។

### ២.២. មតកជនធ្វើការហាមឃាត់ការបែងចែកមត៌ក

មតកជនអាចធ្វើការហាមឃាត់មិនឲ្យមានការបែងចែកមត៌ក ក្នុងរយៈពេលកំណត់ណាមួយតាមឆន្ទៈផ្ទាល់របស់ខ្លួន។ ចំពោះរយៈពេលដែលបានកំណត់នេះ គឺមិនឲ្យលើសពី៥(ប្រាំ)ឆ្នាំ គិតចាប់ពីពេលដែលចាប់ផ្តើមសន្តតិកម្មនោះឡើយ ។

### ៣. ការផ្តាច់មត៌កពីជនដែលសន្មតថាជាសន្តតិជន

បុគ្គលដែលសន្មតថាជាសន្តតិជន និងមានសិទ្ធិយ៉ាងស្វ័យប្រវត្តិក្នុងការទទួលបាននូវចំណែកមត៌ក។ ដោយយោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា សន្តតិកម្មដែលធ្វើឡើងដោយលិខិតមតកសាសន៍ មតកជនអាចបង្ហាញឆន្ទៈរបស់ខ្លួនក្នុងការកំណត់បុគ្គលដែលត្រូវទទួលបានទ្រព្យសម្បត្តិរបស់ខ្លួន ទោះបីជាបុគ្គលនោះមិនមែនជាសន្តតិជនក៏ដោយក៏មានសិទ្ធិទទួលបានចំណែកមត៌កនោះស្របតាមឆន្ទៈរបស់មតកជននឹងមិនផ្ទុយពីបញ្ញត្តិស្តីពីភាគបម្រុងឡើយ។

បុគ្គលដែលសន្មតទុកថាជា សន្តតិជនក៏នៅតែអាចក្លាយជាជនដែលត្រូវផ្តាច់មត៌កបាន តាមរយៈការសម្តែងឆន្ទៈរបស់មតកជន។

### ៣.១. ការផ្តាច់មត៌កតាមខ្លឹមសារនៃលិខិតមតកសាសន៍

មតកជនដែលជាម្ចាស់បណ្តាំអាចសម្តែងឆន្ទៈរបស់ខ្លួនក្នុងការផ្តាច់មត៌ក ពីជនដែលសន្មតទុកថាជាសន្តតិជនម្នាក់ ឬច្រើននាក់បាន ដោយមានការបញ្ជាក់ពីមូលហេតុដែលនាំឲ្យមានការផ្តាច់មត៌កពីជនដែលសន្មតថាជាសន្តតិជនឲ្យបានច្បាស់លាស់នៅក្នុងខ្លឹមសារនៃលិខិតមតកសាសន៍។ ដូចនេះអ្នកប្រតិបត្តិមតក-សាសន៍ត្រូវធ្វើការដាក់ពាក្យសុំទៅតុលាការ ដើម្បីផ្តាច់មត៌កពីសន្តតិជនណាម្នាក់ ឬច្រើននាក់ដែលបានកំណត់ដោយគ្មានការយឺតយ៉ាវ ចាប់ពីពេលដែលលិខិតមតកសាសន៍មួយច្បាប់នោះបង្កើតអានុភាព។[22]

[22] មាត្រា១១៥២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៨។

### ៣.២. ការផ្តាច់មត៌កតាមការដាក់ពាក្យសុំទៅតុលាការ

មតកជនអាចដាក់ពាក្យសុំផ្តាច់មត៌កពី ជនដែលសន្មតថាជាសន្តតិជនទៅកាន់តុលាការដោយមិនឲ្យជននោះទទួលបាននូវមត៌ក។ ប្រសិនបើជននោះត្រូវបានសន្មតថា ជាសន្តតិជនដែលមានភាគបម្រុងបានប្រព្រឹត្តនូវសកម្មភាពមួយចំនួន ដូចការកំណត់ក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជារួមមាន[23]៖

បុគ្គលដែលធ្វើបាបចំពោះមតកជន បានប្រមាថយ៉ាងធ្ងន់ធ្ងរ និងមិនបានមើលថែមតកជន ក្នុងពេលដែលអាចមើលថែមតកជនបាន នៅពេលមតកជនមានជម្ងឺ ត្រូវការមើលថែដោយយកចិត្តទុកដាក់។ បុគ្គលដែលបានទទួលសាលក្រម ឬសាលដីកាផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត និងបុគ្គលដែលបានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរដែលគួរឲ្យកត់សម្គាល់ជាអាទិ៍។ ហើយមតកជនក៏អាចធ្វើការស្នើសុំទៅតុលាការឲ្យលុបចោលការផ្តាច់មត៌កពីសន្តតិជននៅពេលណាវិញក៏បានតាមឆន្ទៈរបស់ម្ចាស់បណ្តាំ។

## ៤.អច្ច័យទាន

មតកជនអាចសម្តែងឆន្ទៈក្នុងការធ្វើអច្ច័យទានទៅឲ្យនរណាម្នាក់ ឬច្រើននាក់ដែលមិនមែនជាសន្តតិ-ជនរបស់ខ្លួន ឬក៏អាចហៅថាជាជនមាននិស្ស័យពិសេស។ អច្ច័យទាន គឺជាប្រទានកម្មដែលម្ចាស់បណ្តាំបានប្រគល់ទ្រព្យឲ្យនរណាម្នាក់ ឬច្រើននាក់ដែលមិនសន្មតទុកថាជាសន្តតិជន ។ អច្ច័យទានមាន២(ពីរ)ប្រភេទ៖

### ៤.១. អច្ច័យទានសកល

អច្ច័យទានសកល គឺជាប្រភេទនៃប្រទានកម្មដែលមតកជនបានផ្តល់ឲ្យទៅបុគ្គលណាម្នាក់ ឬច្រើននាក់នូវទ្រព្យសម្បត្តិរបស់ខ្លួនទាំងអស់ ឬមួយផ្នែកដែលបានកំណត់ទៅតាមភាគ។ ចំពោះករណីមតកជនធ្វើអច្ច័យទានជាសកលទៅឲ្យអច្ច័យលាភី មុននឹងធ្វើការបែងចែកមត៌កទៅឲ្យអច្ច័យលាភី នោះសន្តតិជន និងអ្នកប្រតិបត្តិមត៌កត្រូវធ្វើការពិភាក្សាគ្នា ដើម្បីកំណត់នូវចំណែកកម្មសិទ្ធិរបស់អច្ច័យលាភីទៅលើភាពជាក់ស្តែង។[24]

ឧទាហរណ៍៖ មតកជនបានកំណត់នៅក្នុងលិខិតមតកសាសន៍ថា មត៌កដែលមានជាលុយចំនួន៣០០,០០០$ (សាមសិបម៉ឺនដុល្លារ) ត្រូវធ្វើអច្ច័យទាន១/៥(មួយភាគប្រាំ)ទៅឲ្យគ្រូពេទ្យដែលបានថែទាំជម្ងឺរបស់គាត់។ ដូចនេះក្រោយពេលដែលលិខិតមតកសាសន៍បង្កើតអានុភាពសន្តតិជន និងអ្នកប្រតិបត្តិមតកសាសន៍ចាំបាច់ត្រូវពិភាក្សាគ្នា ក្នុងការបែងចែកមត៌ក ដើម្បីកាត់ចំនួន១/៥(មួយភាគប្រាំ)នៃលុយ៣០០,០០០$ (សាមសិបម៉ឺនដុល្លារ) ទៅឲ្យគ្រូពេទ្យនោះ។

---

[23] មាត្រា១១៥១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៨។

[24] មាត្រា១១៩៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

**៤.២. អច្ច័យទានមានកំណត់**

អច្ច័យទានមានកំណត់ ជាប្រទានកម្មដែលកំណត់នូវទ្រព្យសម្បត្តិជាក់ស្តែងឲ្យទៅបុគ្គលណាម្នាក់ ឬច្រើននាក់នូវទ្រព្យសម្បត្តិរបស់មតកជនដូចមានការកំណត់ជាក់លាក់តាមរយៈលិខិតមតកសាសន៍។ នៅពេលដែលលិខិតមតកសាសន៍បង្កើតអានុភាព នោះមត៌កដែលកំណត់ជាក់លាក់នឹងត្រូវធ្លាក់ទៅលើអច្ច័យលាភីដោយមិនចាំបាច់ធ្វើការពិភាក្សាគ្នារវាងសន្តតិជន និងអ្នកប្រតិបត្តិមត៌កនោះឡើយ។[25] ឧទាហរណ៍៖ មតកជនបានកំណត់នៅក្នុងមតកសាសន៍ថា លុយនៅក្នុងធនាគារអេប៊ីអេចំនួន៥០,០០០$(ប្រាំម៉ឺនដុល្លារ)ជាអច្ច័យទានដែលត្រូវប្រគល់ឲ្យក្មេងស្រីម្នាក់ដែលបានជួយគាត់នៅពេលជួបគ្រោះថ្នាក់ចរាចរណ៍កាលពីឆ្នាំ២០១៥។ ដូចនេះ នៅពេលដែលលិខិតមតកសាសន៍នោះបានបង្កើតអានុភាពលុយចំនួន៥០,០០០$(ប្រាំម៉ឺនដុល្លារ)ដូចដែលបានកំណត់ក្នុងលិខិតមតកសាសន៍របស់មតកជននឹងត្រូវប្រគល់ឲ្យក្មេងស្រីនោះ។

**៥. គោលបំណងផ្សេងៗរបស់មតកជន**

នៅក្នុងខ្លឹមសារលិខិតមតកសាសន៍មតកជនមិនចាំបាច់សរសេរតែពីការបែងចែកទ្រព្យសម្បត្តិនោះទេ។ មតកជនអាចសរសេរពីបំណង ឬចេតនាចុងក្រោយរបស់ខ្លួនដូចជា៖ សរសេរពីការរៀបចំបុណ្យសពរបស់ខ្លួន ទីកន្លែងធ្វើបុណ្យសព សពត្រូវបញ្ចុះ ឬបូជា ឬសរសេរពីយោបល់របស់ខ្លួន ដើម្បីឲ្យមានភាពសុខដុមរមនាក្នុងក្រុមគ្រួសារ ដូចជាការសំណូមពរឲ្យបងប្អូនចេះយោគយល់គ្នា ស្រឡាញ់គ្នា មានទំនាក់ទំនងល្អនឹងគ្នា ចេះជួយគ្នាទៅវិញទៅមកជាអាទិ៍។ សន្តតិជន ឬអ្នកដែលទទួលបានមត៌កត្រូវតែគោរពធ្វើតាមលិខិតមតកសាសន៍ដែលមតកជនបានបន្សល់ទុក។ ចំពោះករណីដែលសន្តតិជន ឬបុគ្គលដែលទទួលបានមត៌កមិនអាចធ្វើតាមការស្នើសុំរបស់មតកជនក៏មិនមាន ទណ្ឌកម្មអ្វីចំពោះបុគ្គលទាំងនោះឡើយ។

**កថាខណ្ឌទី៣៖ កាលបរិច្ឆេទ និងហត្ថលេខា**

**១. កាលបរិច្ឆេទ**

លិខិតគតិយុត្តទាំងអស់ត្រូវតែមាន កាលបរិច្ឆេទឲ្យបានច្បាស់លាស់ បូករួមទាំងលិខិតមតសាសន៍ផងដែរ។ ក្នុងករណីដែលលិខិតមតកសាសន៍ណាមួយ មិនបានចុះកាលបរិច្ឆេទឲ្យបានច្បាស់លាស់ ដើម្បីធ្វើឲ្យលិខិតមតកសាសន៍នោះអាចមានសុពលភាពបាន លុះត្រាតែលិខិតមតកសាសន៍នោះមិនផ្ទុយនឹងខ្លឹមសារនៃលិខិតមតកសាសន៍ដទៃទៀតដែលមានចុះកាលបរិច្ឆេទឲ្យបានច្បាស់លាស់។ ប្រសិនបើលិខិតមតកសាសន៍ច្បាប់ណាមួយដែលមិនបានចុះកាលបរិច្ឆេទច្បាស់លាស់ ហើយមានខ្លឹមសារផ្ទុយពីលិខិតមតកសាសន៍ដែល

[25] មាត្រា១១៩៩ នៃសេចក្តីកំណត់ក្រមរដ្ឋប្បវេណី,ក្រសួងយុត្តិធម៌ ២០១០។

បានចុះកាលបរិច្ឆេទច្បាស់លាស់ នោះលិខិតមតកសាសន៍ដែលមិនចុះកាលបរិច្ឆេទច្បាស់លាស់នឹងត្រូវចាត់ទុកជាមោឃៈ។ ប្រសិនបើមានលិខិតមតកសាសន៍ច្រើនមិនបានចុះកាលបរិច្ឆេទឲ្យបានត្រឹមត្រូវ ហើយមានខ្លឹមសារផ្ទុយគ្នា នោះលិខិតមតកសាសន៍នឹងធ្វើការបន្ថយអានុភាពគ្នាទៅវិញទៅមក។ ក្នុងករណីលិខិតមតកសាសន៍មានច្រើនមិនបានចុះកាលបរិច្ឆេទច្បាស់លាស់ ប៉ុន្តែមានខ្លឹមសារដូចគ្នានោះអានុភាពនៃលិខិតមតកសាសន៍នឹងកើតឡើងធម្មតា។[26]

### ២. ហត្ថលេខា

មតកជនមិនត្រូវបានអនុញ្ញាក្នុងប្រើប្រាស់ការផ្តិតស្នាមម្រាមដៃជំនួសការឲ្យចុះហត្ថលេខាទេ។ ដោយសារតែមានការចាំបាច់ត្រូវធ្វើការពិនិត្យផ្ទៀងផ្ទាត់ មើលហត្ថលេខារបស់មតកជនទៅលើលិខិតផ្សេងៗដែលមតកជនធ្លាប់បានចុះហត្ថលេខា។ ការផ្តិតស្នាមម្រាមដៃ ធ្វើឲ្យមានការពិបាកក្នុងការផ្ទៀតផ្ទាត់មើលពីភាពត្រឹមត្រូវនៃស្នាមម្រាមដៃរបស់មតកជន ដូចនេះការចុះហត្ថលេខា គឺងាយស្រួលក្នុងការផ្ទៀងផ្ទាត់ជាងការផ្តិតស្នាម្រាដៃរបស់មតកជន។ ប៉ុន្តែមតកជនក៏នៅអាចប្រើប្រាស់ ការសរសេរនាមត្រកូល នាមខ្លួន និងការផ្តិតស្នាមម្រាមដៃណាមួយមកប្រើប្រាស់ជំនួសឲ្យការចុះហត្ថលេខាបាន ក្នុងករណីដែលមានវត្តមានសារការី និងសាក្សីបានចុះហត្ថលេខាបញ្ជាក់ពីការផ្តិតស្នាមម្រាមដៃរបស់មតកជនដោយយោងតាមទំនៀមទំលាប់របស់ព្រះរាជាណាចក្រ-កកម្ពុជា។[27]

## កថាខណ្ឌទី៤៖ សាក្សី

### ១. សាក្សី

សាក្សីគឺជាបុគ្គលដែលជួយសម្រួលដល់ការបញ្ជាក់ពីភាពត្រឹមត្រូវរបស់លិខិតមតកសាសន៍តាមឆន្ទៈរបស់មតកជនបានយ៉ាងរឹងមាំ និងមានសុពលភាពយ៉ាងពេញលេញតាមនីតិវិធីដែលច្បាប់មានកំណត់។ គ្រប់រូបវន្តបុគ្គលទាំងអស់សុទ្ធតែអាចធ្វើជាសាក្សីនៃលិខិតមតកសាសន៍បានទាំងអស់ លើកលែងតែបុគ្គលមួយចំនួនដែលបានកំណត់ដោយក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាថាមិនអាចក្លាយជាសាក្សីបានរួមមាន[28]៖

[26] មាត្រា១១៧០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[27] មាត្រា១១៨០ នៃសេចក្តីកំណត់ក្រមរដ្ឋប្បវេណី,ក្រសួងយុត្តិធម៌ ២០១០។

[28] មាត្រា១១៧២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

### ១.១.បុគ្គលអសមត្ថភាព អនីតិជន ឬជនស្ថិតក្រោមអាណាព្យាបាលទូទៅ

បុគ្គលអសមត្ថភាព អនីតិជន ឬជនស្ថិតក្រោមអាណាព្យាបាលទូទៅមិនអាចក្លាយខ្លួនជាសាក្សីក្នុងលិខិតមតកសាសន៍បានទេ។ ដោយហេតុបុគ្គលទាំងនោះត្រូវបាន កម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពដោយអាណាព្យាបាលរបស់ពួកគេ ហេតុនេះពួកគេខ្វះលក្ខណៈសម្បត្តិ ដើម្បីក្លាយជាសាក្សីនៃលិខិតមតកសាសន៍។ សាក្សី គឺជាតួអង្គយ៉ាងសំខាន់ក្នុងការបញ្ជាក់ថា មតកជនពិតជាបានធ្វើលិខិតមតកសាសន៍ពិតប្រាកដមែន។[29]

### ១.២. បុគ្គលដែលជាសន្តតិជន អច្ឆ័យលាភី សហព័ទ្ធ និងញាតិលោហិតខាងផ្ទាល់

បុគ្គលដែលសន្មតថាជា សន្តតិជន អច្ឆ័យលាភី សហព័ទ្ធ និងញាតិលោហិតខាងផ្ទាល់របស់មតកជនត្រូវបានហាមឃាត់មិនឲ្យក្លាយជាសាក្សីក្នុងការធ្វើលិខិតមតកសាសន៍នោះឡើយ។ ដោយសំអាងថាបុគ្គលទាំងនេះជាបុគ្គលដែលខ្វះលក្ខណៈសម្បត្តិជាសាក្សី យោងតាមមូលហេតុសន្តតិជនជាជនអាចនឹងទទួលបានមត៌កដែលកំណត់ដោយមតកជនក្នុងលិខិតបណ្តាំ ទោះបីជាទទួលបានតិច ឬច្រើនក្តី ជាហេតុនាំឲ្យកើតការមិនសុខចិត្ត និងមិនមានយុត្តិធម៌សម្រាប់សហសន្តតិជនដទៃទៀត។ អច្ឆ័យលាភីក៏មិនអាចក្លាយជាសាក្សីបានដោយសារតែបុគ្គលនេះមានទំនាក់ទំនងនឹងផលប្រយោជន៍នៃទ្រព្យសម្បត្តិក្នុងមត៌ក និងអាចបង្កើតជាបញ្ហាមិនសុក្រឹត្យភាពនៃចម្លើយរបស់សាក្សី ។ រីឯសហព័ទ្ធ និងញាតិលោហិតខ្សែផ្ទាល់របស់មតកជនក៏មិនអាចធ្វើជាសាក្សីបានដែរ ព្រោះបុគ្គលទាំងនោះសុទ្ធតែមានទំនាក់ទំនងនឹងផលប្រយោជន៍នៃលិខិតមតកសាសន៍របស់មតកជន។ [30]

### ១.៣. សារការី សហព័ទ្ធរបស់សារការី ញាតិលោហិតរបស់សារការី ក្រឡាបញ្ជី និងនិយោជករបស់សារការី

ក្នុងករណីដែលសារការីជាអ្នកពាក់ព័ន្ធក្នុងការធ្វើលិខិតមតកសាសន៍ សហព័ន្ធរបស់សារការី ញាតិលោហិតខ្សែផ្ទាល់ ក្រឡាបញ្ជី និងនិយោជិតរបស់សារការីមិនអាចក្លាយខ្លួនជាសារការីបានទេ។ ក្នុងពេលដែលសារការីជាអ្នកពាក់ព័ន្ធនឹងការធ្វើមតកសាសន៍។ ជាហេតុដែលចាំបាច់ត្រូវមានមានវត្តមានរបស់តតិយជន ក្រៅពីបុគ្គលដូចដែលមានទំនាក់ទំនងដូចការរៀបរាប់ខាងលើមកធ្វើជាសាក្សី ដើម្បីធានានូវសុក្រឹតភាព។ ប្រសិនបើអនុញ្ញាតឲ្យបុគ្គលដែលមានទំនាក់ទំនងដូចដែលបានកំណត់ជាមួយសារការីក្លាយខ្លួនជាសាក្សី នោះនឹងមាន

---

[29] មាត្រា១១៧២ កថាខណ្ឌទី១ នៃសេចក្តីកំណត់ក្រមរដ្ឋប្បវេណី ,ក្រសួងយុត្តិធម៌ ២០១០។

[30] មាត្រា១១៧២ កថាខណ្ឌទី២ នៃសេចក្តីពន្យល់ក្រមរដ្ឋប្បវេណី,ក្រសួងយុត្តិធម៌ ២០១០។

បញ្ហាអំពីភាពគ្មានលក្ខណៈសម្បត្តិជាតតិយជនរបស់សាក្សី ហើយជាគោលការណ៍បុគ្គលទាំងនោះជាបុគ្គលដែលខ្វះលក្ខណៈសម្បត្តិជាសាក្សីក្នុងមតកសាសន៍។[31]

## ផ្នែកទី២៖ ទម្រង់នៃលិខិតមតកសាសន៍

លិខិតមតកសាសន៍ ត្រូវបានធ្វើឡើងស្របតាមទម្រង់ណាមួយដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជាទើបអាចចាត់ទុកថាមានសុពលភាពខាងទម្រង់។[32] ចំពោះករណីលិខិតមតកសាសន៍ ធ្វើឡើងដោយមិនស្របតាមទម្រង់ដែលបានកំណត់ក្នុងបញ្ញាត្តិនេះនឹងត្រូវចាត់ទុកជា មោឃៈ។[33] ប៉ុន្តែបញ្ញត្តិនេះ មានករណីលើកលែង ចំពោះលិខិតមតកសាសន៍ណាដែលមិនមានចុះកាលបរិច្ឆេទច្បាស់លាស់ ហើយមិនមានខ្លឹមសារ ប្រះចាកពីលិខិតមតកសាសន៍ដទៃទៀតដែលបានធ្វើឡើងដោយម្ចាស់បណ្តាំតែម្នាក់។

សម្គាល់៖ សារការី គឺជាអ្នកទទួលបានសិទ្ធិ និងសម្បទាផ្លូវច្បាប់ក្នុងការបំពេញសេវាកម្មដែលតម្រូវឲ្យមានតាមបញ្ញត្តិច្បាប់។ ដូច្នេះគ្រប់លិខិតចេញដោយសារការីជាលិខិតដែលត្រឹមត្រូវតាមផ្លូវច្បាប់។ ជុំវិញការតាក់តែងលិខិតយថាភូតរបស់សារការីមានដូចជា៖ លិខិតយថាភូតដែលទាក់ទងនឹងផ្នែកអចលនវត្ថុ លិខិតយថាភូតទាក់ទងនឹងនីតិមត៌ក លិខិតយថាភូតទាក់ទងនឹងនីតិគ្រួសារ និងលិខិតយថាភូតទាក់ទងនឹងនីតិពាណិជ្ជកម្មជាដើម។[34]

ផ្អែកតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧នៃព្រះរាជាណាចក្រកម្ពុជា មតកជនអាចធ្វើលិខិតបណ្តាំបានតាមស្ថានភាព២(ពីរ)យ៉ាង ទី១.ទម្រង់មតកសាសន៍ក្នុងស្ថានភាពទូទៅ ឬធម្មតា និងទី២.ការធ្វើលិខិតមតកសាសន៍ដែលស្ថិតក្នុងស្ថានភាពពិសេស។[35]

---

[31] មាត្រា១១៧២ កថាខណ្ឌទី៣ នៃសេចក្តីពន្យល់ក្រមរដ្ឋប្បវេណី,ក្រសួងយុត្តិធម៌ ២០១០។

[32] មាត្រា១១៧១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[33] មាត្រា១១៧០ កថាខ័ណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[34] មន្ទីសារការីអង្គរ ចំណុចដកស្រង់ចេញពីផ្នែក *សេវាកម្ម* មានទីតាំងអគារលេខ១៧អេហ្វ ផ្លូវលេខ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ អាចរកបាននៅ http://angkornotary.com.kh/km/ ចូលមើលថ្ងៃទី ៤ ខែ សីហា ឆ្នាំ២០២១។

[35] បកស្រាយដោយលោកគ្រូ អ៊ឹង ប៉ូលី ប្រធានបទ៖ *ការបែងចែកមតកសាសន៍តាមបណ្តាំ* របស់កម្មវិធីនាទីច្បាប់របស់ BTV អាចចូលទស្សនាបាននៅ https://www.youtube.com/watch?v=YiFcJlOdaSw&list=PL48iwV2gkPae7-7_dWlSt6Vr6rZ9LG5NM&index=5 នាទីទី ៥.៣៩ (ចូលទស្សនានៅថ្ងៃទី ៤ ខែ សីហា ឆ្នាំ ២០២១)។

**កថាខណ្ឌទី១៖ ទម្រង់មតកសាសន៍ក្នុងស្ថានភាពទូទៅ ឬ ធម្មតា**

ទម្រង់មតកសាសន៍ធម្មតាត្រូវបានបែងចែកជា ៣(បី)ទម្រង់ ដូចខាងក្រោម៖ ១.មតកសាសន៍ដែលជាលិខិតយថាភូត ២.មតកសាសន៍ដែលជាលិខិតឯកជន ៣.មតកសាសន៍ដែលជាលិខិតសម្ងាត់។

**១. មតកសាសន៍ជាលិខិតយថាភូត**

លិខិតមតកសាសន៍ជាយថាភូត គឺជាលិខិតដែលមានភាពជឿទុកចិត្តបានច្រើនជាងគេក្នុងចំណោមលិខិតមតកសាសន៍ទាំងអស់ ដោយហេតុថាលិខិតនោះត្រូវបានធ្វើឡើងដោយមានវត្តមានសារការី។ ទៀតសោតសារការី ជាបុគ្គលដែលទទួលខុសត្រូវក្នុងការតាក់តែង និងមើលថែរក្សាលិខិតមតកសាសន៍នេះរហូតដល់ម្ចាស់បណ្តាំទទួលមរណភាពនឹងបន្តអនុវត្តលិខិតបណ្តាំត្រូវបានបញ្ចប់ជាស្ថាពរតាមផ្លូវច្បាប់។

ដើម្បីឲ្យលិខិតមតកសាសន៍ជាយថាភូត មានសុពលភាពគតិយុត្តខាងទម្រង់នៃលិខិតត្រូវធ្វើឡើងតាមលក្ខខណ្ឌបានកំណត់ក្នុងបញ្ញត្តិស្តីពីទម្រង់នៃលិខិតមតកសាសន៍។ លក្ខខណ្ឌនៃទម្រង់ក្នុងការបង្កើតលិខិតមតកសាសន៍ប្រភេទនេះមាន៖

- ត្រូវធ្វើឡើងដោយមានវត្តមានរបស់ម្ចាស់បណ្តាំនៅចំពោះមុខសារការី។
- ចាំបាច់ត្រូវមានសាក្សីយ៉ាងតិច២(ពីរ)រូប។
- ម្ចាស់បណ្តាំជាអ្នកប្រាប់ដោយផ្ទាល់មាត់នូវខ្លឹមសារនៃមតកសាសន៍ចំពោះមុខសារការី។
- សារការីត្រូវសរសេរគ្រប់ពាក្យសំដីរបស់ម្ចាស់បណ្តាំចូលក្នុងខ្លឹមសារមតកសាសន៍នោះជាលាយលក្ខណ៍អក្សរ ហើយត្រូវសូត្រឲ្យម្ចាស់បណ្តាំ និងសាក្សីគ្រប់រូបស្តាប់។
- បន្ទាប់ពីការស្តាប់របស់ម្ចាស់បណ្តាំ និងសាក្សីរួច ហើយម្ចាស់បណ្តាំ និងសាក្សីត្រូវមានការទទួលស្គាល់ថា ការសរសេរជាលាយលក្ខណ៍អក្សរនោះត្រឹមត្រូវ ហើយជននីមួយៗត្រូវមើលឲ្យបានច្បាស់លាស់នៅលើឯកសារអំពីឈ្មោះ អាយុ និងលំនៅឋាន ហើយចុះហត្ថលេខារៀងខ្លួនៗ។ ចំពោះករណីដែលម្ចាស់បណ្តាំមិនអាចសរសេរអក្សរ ឬចុះហត្ថលេខាបានទេ នោះសារការីអាចជំនួសការសរសេរ និងហត្ថលេខាដូចបានកំណត់ខាងលើនេះទៅជាការសរសេរឈ្មោះរបស់មតកជន អាយុ និងលំនៅឋានរបស់ម្ចាស់បណ្តាំដោយមានការសរសេរបន្ថែមនូវហេតុផលផងដែរ។
- សារការីត្រូវសរសេរថ្ងៃខែឆ្នាំដែលបានធ្វើបណ្តាំនោះ ដោយមានការចុះហត្ថលេខារបស់សារការីផង។[36]

**គុណសម្បត្តិ និងគុណវិបត្តិ**

[36] មាត្រា១១៧៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

❖ គុណសម្បត្តិ៖

- សារការីជាអ្នកដែលមានជំនាញខាងច្បាប់ច្បាស់លាស់នោះមិនអាចមានករណីដែលមតកសាសន៍នៃលិខិតយថាភូតនេះអសុពលភាពដោយសារតែកង្វះខាតនូវលក្ខណៈណាមួយនោះឡើយ។
- បើទោះបីជាម្ចាស់បណ្តាំមិនចេះអក្សរក៏អាចធ្វើមតកសាសន៍ជាលិខិតយថាភូតបាន ដោយម្ចាស់បណ្តាំ គ្រាន់តែពន្យល់នូវខ្លឹមសារដែលខ្លួនចង់សរសេរប្រាប់ដោយផ្ទាល់មាត់ទៅកាន់សារការីតែប៉ុណ្ណោះ។
- ចំណុចពិសេសមួយទៀតនោះ នៅពេលដែលត្រូវអនុវត្តលិខិតមតកសាសន៍ មិនចាំបាច់ត្រូវមាននីតិវិធីពិនិត្យបញ្ជាក់ពីតុលាការនោះទេ។

❖ គុណវិបត្តិ ៖

- ត្រូវមានតតិយជនដែលជាសាក្សីមកដឹងនូវខ្លឹមសាររបស់លិខិតមតកសាសន៍មុនពេលដែលម្ចាស់បណ្តាំទទួលមរណភាព។
- ត្រូវចំណាយថវិកាក្នុងការសុំអន្តរាគមន៍ពីសំណាក់សារការី។

### ២. មតកសាសន៍ជាលិខិតឯកជន

មតកសាសន៍ដោយលិខិតឯកជន ជាលិខិតមតកសាសន៍ដែលម្ចាស់បណ្តាំជាអ្នកសរសេរផ្ទាល់នូវខ្លឹមសារ ពាក្យពេចន៍ទាំងមូលនៃមត៌កព្រមទាំងចុះថ្ងៃខែឆ្នាំ និងហត្ថលេខាដោយខ្លួនឯងផ្ទាល់។[37] មូលហេតុតម្រូវឲ្យធ្វើការ ចុះហត្ថលេខា និងចុះថ្ងៃខែឆ្នាំដោយខ្លួនឯងផ្ទាល់ គឺដើម្បីមានភាពងាយស្រួលករណីមានបញ្ហាទាក់ទិននឹងសុក្រឹត្យភាពនៃលិខិតមតកសាសន៍កើតឡើង គេមិនអាចទាមទារហៅសាមីខ្លួនដែលបានទទួលមរណភាពមកបញ្ជាក់ពីសេចក្តីថ្លែងការណ៍នោះទេ។ គេត្រូវធ្វើការផ្ទៀងផ្ទាត់មើលទៅលើអក្សររបស់ម្ចាស់បណ្តាំរវាងមតកសាសន៍ជាលិខិតឯកជនជាមួយនិងលិខិតផ្សេងៗដែលម្ចាស់បណ្តាំធ្លាប់បានសរសេរកាលនៅជារូបវន្ត

បុគ្គល ដើម្បីយកមកធ្វើការប្រៀបធៀបគ្នារកលក្ខណៈដូចគ្នានៃអក្សរ។[38] ក្រោយពីធ្វើការប្រៀបធៀបរួចមកឃើញថា អក្សរលើលិខិតទាំងពីរនេះជាអក្សរដែលសរសេរដោយបុគ្គលតែម្នាក់នោះចាត់ទុកថាលិខិតនោះមានភាពត្រឹមត្រូវ និងត្រូវបានសរសេរដោយម្ចាស់បណ្តាំផ្ទាល់យ៉ាងពិតប្រាកដ ហើយគេអាចយកលិខិតមត្យាសន៍នោះមកអនុវត្តបាន។ ទន្ទឹមនឹងនេះបើការប្រៀបធៀបនៃអក្សរចេញលទ្ធផលមកឃើញថា ខុសគ្នានោះលិខិតបណ្តាំត្រូវសន្មតថាមោឃៈ។

---

[37] មាត្រា១១៧៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[38] មាត្រា១១៧៤ កថាខណ្ឌទី១ នៃសេចក្តីពន្យល់ក្រមរដ្ឋប្បវេណី។

ជាមួយគ្នានោះដែលលិខិតមតកសាសន៍ ធ្វើឡើងដោយឲ្យតតិយជនជាអ្នកសរសេរជំនួសម្ចាស់បណ្តាំ ឬដោយការវាយដោយម៉ាស៊ីនជំនួសដោយការសរសេរដៃត្រូវចាត់ថាមោឃៈ។[39] ចំពោះករណីដែលម្ចាស់បណ្តាំចង់សរសេរបន្ថែម,ការផ្លាស់ប្តូរចំណុចណាមួយ ឬការលុបចេញនូវចំណុចណាមួយក្នុងខ្លឹមសារនៃបណ្តាំ ម្ចាស់បណ្តាំត្រូវសរសេរបញ្ជាក់ឲ្យបានច្បាស់លាស់នូវការផ្លាស់ប្តូរនោះ ហើយចាំបាច់ត្រូវចុះហត្ថលេខា ដើម្បីជាការបញ្ជាក់នៅពេលមានការផ្ទៀងផ្ទាត់ លិខិតបណ្តាំនឹងលិខិតផ្សេងទៀតដែលមានហត្ថលេខារបស់សាមីខ្លួនដើម្បីបញ្ជាក់ថា តើការផ្លាស់ប្តូរត្រូវបានធ្វើឡើងដោយម្ចាស់បណ្តាំយ៉ាងពិតប្រាកដមែនរឺទេ? ការចុះហត្ថលេខាបញ្ជាក់នេះ ដើម្បីបញ្ចៀសករណីដែលមានតតិយជនណាម្នាក់ធ្វើការផ្លាស់ប្តូរខ្លឹមសារនៃលិខិតបណ្តាំ។[40]

**គុណសម្បត្តិ និង គុណវិបត្តិ**

❖ គុណសម្បត្តិ

- ម្ចាស់បណ្តាំអាចធ្វើលិខិតបណ្តាំបានដោយខ្លួនឯងបានមិនចាំបាច់មានការអន្តរាគមន៍ពីវត្តមានសារការី និងសាក្សី។
- មិនចាំបាច់ចំណាយសោហ៊ុយពីការសុំអន្តរាគមន៍ពីសារការី។
- អាចរក្សាការសម្ងាត់នៃខ្លឹមសារបណ្តាំមត៌ក។

❖ គុណវិបត្តិ

- លិខិតមតកសាសន៍និងត្រូវចាត់ទុកជាមោឃៈដោយសារតែកំហុសនៃទម្រង់ ព្រោះតែមានការទាមទារឲ្យគោរពតាមទម្រង់យ៉ាងតឹងរ៉ឹង ហើយគ្មានវត្តមានសារការីដែលជាអ្នកយល់ដឹងផ្នែកច្បាប់ចូលរួម។
- ប្រសិនបើម្ចាស់បណ្តាំជាអនក្ខរជន នោះគាត់មិនអាចធ្វើលិខិតមតកសាសន៍បានទេ ព្រោះខ្លឹមសារនៃលិខិតមតកសាសន៍ទាំងមូលតម្រូវឲ្យគាត់ជាអ្នកសរសេរដោយខ្លួនឯងផ្ទាល់ ហើយគាត់ក៏មិនបានអនុញ្ញាតប្រើប្រាស់បច្ចេកវិទ្យាក្នុងការធ្វើលិខិតមតកសាសន៍ជំនួសដោយការសរសេរដៃដែរ។
- អាចបាត់ ឬអាចមានការក្លែងបន្លំ ព្រោះម្ចាស់បណ្តាំជាអ្នករក្សាលិខិតមតកសាសន៍នេះដោយខ្លួនឯងផ្ទាល់។
- ចាំបាច់ត្រូវមានការពិនិត្យបញ្ជាក់ពីតុលាការ ដើម្បីអាចអនុវត្តលិខិតមតកសាសន៍នេះបាន។

[39] មាត្រា១១៧៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[40] មាត្រា១១៧៤ កថាខណ្ឌទី២ នៃសេចក្តីពន្យល់ក្រមរដ្ឋប្បវេណី។

### ៣. មតកសាសន៍ជាលិខិតសម្ងាត់

មតកសាសន៍ជាលិខិតសម្ងាត់ គឺជាលិខិតមួយប្រភេទដែលសារការីជាអ្នកបញ្ជាក់ថាមានលិខិតបណ្តាំរបស់មតកជនយ៉ាងពិតប្រាកដ ហើយខ្លឹមសារនៅក្នុងលិខិតបណ្តាំត្រូវបានរក្សាទុកជាការសម្ងាត់។ យ៉ាងណាមិញមតកសាសន៍ជាលិខិតសម្ងាត់នេះទៀតសោត ម្ចាស់បណ្តាំអាចសរសេរដោយខ្លួនឯង ឬស្នើសុំឲ្យនរណាម្នាក់ជាអ្នកសរសេរខ្លឹមសារក្នុងលិខិតមតកសាសន៍ ឬអាចប្រើប្រាស់បច្ចេកវិទ្យាកុំព្យូទ័របានទេ។ ម្ចាស់បណ្តាំត្រូវធ្វើការចុះហត្ថលេខាដោយខ្លួនឯងផ្ទាល់ ដើម្បីបញ្ជាក់ថាលិខិតមតកសាសន៍បានកើតចេញមកពីមតកជនយ៉ាងពិតប្រាកដ។[41] មតកសាសន៍ជាលិខិតសម្ងាត់ត្រូវធ្វើឡើងដោយយោងតាមទម្រង់ដែលបានកំណត់ដូចខាងក្រោមនេះ[42]៖

- ម្ចាស់បណ្តាំត្រូវចុះហត្ថលេខាដោយផ្ទាល់លើលិខិតនោះ។
- ម្ចាស់បណ្តាំត្រូវដាក់លិខិតមតកសាសន៍នោះក្នុងស្រោមបិទជិត ហើយត្រូវចុះហត្ថលេខា ឬសរសេរសញ្ញាសម្គាល់ ឬប្រើប្រាស់មធ្យោបាយផ្សេងៗទៀតដែលអាចសំអាងក្នុងការវិនិច្ឆ័យបានអំពីការបានបើក ឬមិនបានបើកស្រោមលិខិតនោះនៅមាត់ស្រោមលិខិតនោះ។
- ម្ចាស់បណ្តាំត្រូវដាក់លិខិតដែលបិទជិតនោះ នៅចំពោះមុខសារការីម្នាក់ និងសាក្សី២(ពីរ)នាក់នឹងធ្វើសេចក្តីថ្លែងការណ៍អំពីឈ្មោះ និងលំនៅឋានរបស់ជនដែលបានសរសេរនោះ។
- សារការីត្រូវចុះថ្ងៃខែឆ្នាំដែលសាមីខ្លួនបានដាក់លិខិតនោះ និងសរសេរសេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តាំនៅលើស្រោមលិខិតដែលបិទជិតនោះ ហើយត្រូវចុះហត្ថលេខាលើស្រោមលិខិតនោះជាមួយសាក្សី និងម្ចាស់បណ្តាំ។

ម្យ៉ាងវិញទៀតទោះបីជាលិខិតបណ្តាំនោះមិនស្របតាមលក្ខខណ្ឌនៃទម្រង់មតកសាសន៍ដែលជាលិខិតសម្ងាត់ក៏ដោយក៏អាចមានសុពលភាពជាមតកសាសន៍ដែលជាលិខិតឯកជនដែរដរាបណាលិខិតមតកសាសន៍នោះអនុលោមតាមទម្រង់នៃមតកសាសន៍ដែលជាលិខិតឯកជន។[43]

### គុណសម្បត្តិ និង គុណវិបត្តិ

- ❖ គុណសម្បត្តិ

[41] នៃសេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ៣ ទំព័រទី៥២។

[42] មាត្រា១១៧៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[43] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ៣ ទំព័រទី៥៣។

- ទោះបីជាម្ចាស់បណ្តាំមិនចេះសរសេរអក្សរក៏អាចធ្វើលិខិតបណ្តាំបានដែរ ព្រោះគាត់អាចស្នើសុំឲ្យនរណាម្នាក់សរសេរខ្លឹមសារជំនួស ឬប្រើប្រាស់បច្ចេកវិទ្យាបាន។
- អាចការពារពីការក្លែងបន្លំ ឬការផ្លាស់ប្តូរ ព្រោះមតកសាសន៍នេះត្រូវបានរក្សាទុកជាសម្ងាត់ក្នុងស្រោមសំបុត្របិទជិត។
- អាចរក្សាការសម្ងាត់ពីខ្លឹមសារនៃលិខិតមតកសាសន៍នោះ ព្រោះលិខិតមតកសាសន៍ត្រូវបានរក្សាទុកក្នុងស្រោមសំបុត្របិទជិត និងមានការរក្សាទុកពីសារការីផងដែរ។

❖ គុណវិបត្តិ

- ចាំបាច់មានការអន្តរាគមន៍ពីសារការី
- ចាំបាច់ធ្វើការពិនិត្យបញ្ជាក់ ពេលអនុវត្តលិខិតមតកសាសន៍
- ចាំបាច់ចំណាយថវិកា ដើម្បីសុំអន្តរាគមន៍ពីសារការី
- មានតតិយជនដឹងពីខ្លឹមសារមតកសាសន៍មុនពេលម្ចាស់បណ្តាំស្លាប់ ក្នុងករណីដែលម្ចាស់បណ្តាំស្នើសុំឲ្យនរណាម្នាក់ដែលតតិយជនជាអ្នកសរសេរជំនួស។

### កថាខណ្ឌទី២៖ មតកសាសន៍ស្ថិតក្នុងស្ថានភាពពិសេស

ការបកស្រាយកថាណ្ឌទី១ ដែលបានរៀបរាប់ពីទម្រង់មតកសាសន៍ដែលស្ថិតក្នុងស្ថានភាពទូទៅ ឬធម្មតាត្រូវបានបញ្ចប់។ ឥលូវនេះនឹងធ្វើការបកស្រាយកថាខណ្ឌទី២ ដែលនិយាយអំពីការធ្វើលិខិតមតកសាសន៍ស្ថិតក្នុងស្ថានភាពពិសេសវិញម្តង។ ក្នុងបញ្ញត្តិនៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាលិខិតមតក-សាសន៍ធ្វើឡើងក្នុងស្ថានភាពពិសេសមាន៥(ប្រាំ)ទម្រង់ដូចជា៖ ១.មតកសាសន៍នៃជននៅក្រោមអាណា-ព្យាបាលទូទៅ ២.មតកសាសន៍នៃជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ៣.មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង ឬជនដែលនៅក្នុងនាវា យន្តហោះ ៤.មតកសាសន៍ជនជាតិខ្មែរដែលរស់នៅបរទេស ៥.មតកសាសន៍នៃជនដែលមិនអាចនិយាយបាន។

#### ១. មតកសាសន៍ជនស្ថិតក្រោមអាណាព្យាបាលទូទៅ

ជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅមានសិទ្ធិក្នុងការធ្វើលិខិតមតកសាសន៍បាន នៅពេលដែលបុគ្គលនោះបានជាសះស្បើយឡើងវិញមួយរយៈ អាចមានសមត្ថភាពក្នុងការយល់ដឹង និងការវិនិច្ឆ័យនូវលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន។ ប៉ុន្តែជននៅក្រោមអាណាព្យាបាលទូទៅអាចធ្វើលិខិតបណ្តាំនេះបានចាំបាច់ត្រូវមានវត្តមានវេជ្ជបណ្ឌិត២( ពីរ)រូបយ៉ាងតិចសម្រាប់ធ្វើការបញ្ជាក់ថាម្ចាស់បណ្តាំពិតជាបានជាសះស្បើយមួយរយៈឡើងវិញ និងមានសមត្ថភាពក្នុងការធ្វើលិខិតមតកសាសន៍ ដើម្បីបញ្ចៀសជម្លោះនៅពេល

ដែលអនុវត្តលិខិតមតកសាសន៍។[44] នៅពេលដែលធ្វើលិខិតមតកសាសន៍វេជ្ជបណ្ឌិតត្រូវតែមានវត្តមាននៅកន្លែងធ្វើលិខិតមតកសាសន៍នោះ ឬនៅពេលដែលម្ចាស់បណ្តាំធ្វើការបង្ហាញខ្លឹមសារនៃលិខិតមតកសាសន៍នោះទៅកាន់សារការីដែលត្រូវមានកាតព្វកិច្ចធ្វើជាសាក្សី ដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់អំពីការជាសះស្បើយឡើងវិញមួយរយៈរបស់ម្ចាស់បណ្តាំ។ ចំពោះករណីដែលជននោះធ្វើមតកសាសន៍ដែលជាលិខិតយថាភូតចាំបាច់តម្រូវឲ្យមានវត្តមានសាក្សីផ្សេងទៀតក្រៅពីវេជ្ជបណ្ឌិតផងដែរ។

ប្រសិនបើជនស្ថិតក្រោមអាណាព្យាបាលទូទៅ ធ្វើមតកសាសន៍ជាលិខិតឯកជន ឬលិខិតសម្ងាត់ ក្នុងករណីនេះ ចាំបាច់តម្រូវឲ្យមានវត្តមានរបស់វេជ្ជបណ្ឌិត ដើម្បីធ្វើជា សាក្សីនៅពេលសរសេរមតកសាសន៍ដោយផ្ទាល់ ឬ នៅពេលដែលម្ចាស់បណ្តាំបង្ហាញខ្លឹមសារនៃមតកសាសន៍ទៅឲ្យសារការី។[45] វេជ្ជបណ្ឌិតដែលមានវត្តមានជាសាក្សីនៅពេលធ្វើលិខិតមតកសាសន៍ត្រូវសរសេរបន្ថែមនៅលើលិខិតមតកសាសន៍ នោះថាមតកជនធ្វើលិខិតបណ្តាំនេះ ពុំបានស្ថិតក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និងការវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួននោះទេ វេជ្ជបណ្ឌិតដែលមានវត្តមាននោះចុះហត្ថលេខាដោយមានការបញ្ជាក់ថាខ្លួនជាវេជ្ជបណ្ឌិត។[46] ប្រសិនបើគ្មានវត្តមានរបស់វេជ្ជបណ្ឌិត នៅពេលធ្វើលិខិតមតកសាសន៍តាមគ្រប់ទម្រង់នៃលិខិតមតកសាសន៍ដូចបានកំណត់ក្នុងក្រមរដ្ឋប្បវេណីនោះ លិខិតមតកសាសន៍ទាំងនោះនឹងត្រូវចាត់ទុកជាមោឃៈ។ ដូច្នោះហើយទើបវត្តមានរបស់វេជ្ជបណ្ឌិត គឺជាសាក្សីដ៏សំខាន់ក្នុងការធ្វើលិខិតមតកសាសន៍របស់ជនស្ថិតក្រោមអាណាព្យាបាលទូទៅ។ មានតែវេជ្ជបណ្ឌិតប៉ុណ្ណោះដែលអាចមានសមត្ថភាពក្នុងការវិនិច្ឆ័យពីស្ថានភាពស្មារតី របស់ម្ចាស់បណ្តាំបាន។

## ២. មតកសាសន៍ជនកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត

ខណៈពេលដែលកំពុងស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ប្រសិនបើមតកជនមានបំណងចង់ធ្វើលិខិតបណ្តាំ គេក៏អាចធ្វើបានដោយតម្រូវឲ្យមានវត្តមានសាក្សីចំនួន៣(បី)នាក់ ជាអ្នកបញ្ជាក់ក្នុងស្ថានភាពនាពេលនោះ។[47] ជាការពិតណាស់ ទោះបីស្ថិតក្នុងស្ថានភាពបែបនេះក៏ដោយ ម្ចាស់បណ្តាំនៅតែអាចធ្វើលិខិតមតកសាសន៍ជាលិខិតឯកជនបានដែរ ចំពោះករណីម្ចាស់បណ្តាំមានសមត្ថភាពក្នុងការធ្វើលិខិតមតក-សាសន៍នោះ។ មួយវិញទៀត ករណីម្ចាស់បណ្តាំអាចធ្វើការអញ្ជើញសារការីបាន ម្ចាស់បណ្តាំនៅតែមានសិទ្ធិធ្វើ

---

[44] មាត្រា១១៧៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

[45] មាត្រា១១៧៦ នៃសេចក្តីពន្យល់មាត្រនីមួយៗក្រមរដ្ឋប្បវេណី។

[46] មាត្រា១១៧៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

[47] មាត្រា១១៧៧ វាក្យខណ្ឌ១ កថាខ័ណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

លិខិតមតកសាសន៍ជាលិខិតយថាភូត ឬជាលិខិតសម្ងាត់ ដោយផ្អែកលើបរិបទនៃស្ថានភាពជាក់ស្ដែង ប៉ុន្តែចាំបាច់ត្រូវមានវត្តមានសាក្សី ២(ពីរ)នាក់។[48]

គួរបញ្ជាក់ផងដែរថា ទោះក្នុងកាលទេសៈនេះក៏ដោយជនដែលត្រូវហាមឃាត់មិនឲ្យក្លាយជាសាក្សី ឬធ្វើជាអ្នកសង្កេតការណ៍ កំឡុងពេលធ្វើលិខិតបណ្ដាំក៏ត្រូវតែយកមកអនុវត្ត។ ជនត្រូវបានហាមឃាត់នោះមានដូចជា៖ ជនដែលត្រូវបានសន្មតថាជា សន្តតិជន ឬជាជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ អនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ សារការី សហព័ទ្ធរបស់សារការី ញាតិលោហិតរបស់សារការី ក្រឡាបញ្ជី និងនិយោជករបស់សារការីជាអាទិ៍។ ដោយសារតែការធ្វើលិខិតមតកសាសន៍នៃជនដែលកំពុងជួបប្រទះគ្រោះថ្នាក់ដល់អាយុជីវិត ជាករណីពិសេសទើបតម្រូវឲ្យមានការបញ្ជាក់ពីតុលាការក្នុងកំឡុងពេលមួយខែ គិតចាប់ពីថ្ងៃបានធ្វើលិខិតបណ្ដាំនោះឡើង។ ករណីនេះ បើសាក្សីណាម្នាក់ ឬបុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍មិនបានដាក់ពាក្យទៅតុលាការនៅក្នុងកំឡុងពេលមួយខែតាមការកំណត់ដែលជាហេតុពុំបានទទួលការបញ្ជាក់ភាពត្រឹមត្រូវពីតុលាការទេនោះ លិខិតមតកសាសន៍នឹងត្រូវចាត់ទុកថាគ្មានអានុភាពក្នុងការអនុវត្ត។[49]

តុលាការ គឺជាអ្នកមានសមត្ថកិច្ច និងមានបទដ្ឋានក្នុងការវិនិច្ឆ័យបញ្ជាក់ថា លិខិតមតកសាសន៍នេះកើតចេញពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្ដាំដែរឬទេ។ បន្ទាប់ពីការវិនិច្ឆ័យបានបញ្ចប់លទ្ធផលតុលាការមានការជឿជាក់ចំពោះលិខិតមតកសាសន៍ថាពិតជាកើតចេញពីឆន្ទៈរបស់ម្ចាស់បណ្ដាំពិតមែន នោះតុលាការនឹងធ្វើការបញ្ជាក់ទៅលើលិខិតមតកសាសន៍។ ប្រសិនបើតុលាការរកឃើញពីភាពមិនអាចទុកចិត្តបានចំពោះលិខិតមតកសាសន៍ទេ តុលាការក៏មិនអាចធ្វើការបញ្ជាក់លិខិតមតកសាសន៍នោះបានឡើយ។[50]

### ៣. មតកសាសន៍ជនជាប់ឃុំឃាំង ឬជនជាប់ក្នុងនាវា យន្តហោះ

ជនដែលត្រូវជាប់ឃុំឃាំងនៅទីកន្លែងដាច់ដោយឡែក ដោយសាលក្រម សាលដីកា ឬការចាត់ចែងផ្នែករដ្ឋបាល ឬជនស្ថិតនៅលើនាវា យន្តហោះ ក៏មានសិទ្ធិធ្វើលិខិតបណ្ដាំបានដែរ។[51] ហើយគេក៏អាចធ្វើលិខិតមតកសាសន៍ជាលិខិតយថាភូត និងលិខិតឯកជនបាន។ ប៉ុន្តែបើក្នុងករណីដែលជនទាំងនេះជា អនក្ខរជន ឬ

[48] មាត្រា១១៧៧ នៃសេចក្តីពន្យល់មាត្រនីមួយៗក្រមរដ្ឋប្បវេណី។

[49] មាត្រា១១៧៧ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

[50] មាត្រា១១៧៧ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

[51] មាត្រា១១៧៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

មានរបួសដៃ មិនអាចធ្វើលិខិតមតកសាសន៍តាមលិខិតឯកជនបានឡើយ។[52] ជាហេតុដែលនាំឲ្យមានអនុវត្តដូចខាងក្រោម៖

- ចំពោះជនដែលត្រូវជាប់ឃុំឃាំង

បុគ្គលដែលជាប់ឃុំឃាំងនៅទីកន្លែងដាច់ដោយឡែក ដោយសាលក្រម សាលដីកា ឬដោយសារការចាត់ចែងផ្នែករដ្ឋបាល អាចធ្វើលិខិតមតកសាសន៍បានដោយតម្រូវឲ្យមានវត្តមាននគរបាល ឬមន្ត្រីឃុំឃាំងម្នាក់ និងសាក្សីយ៉ាងតិច២(ពីរ)នាក់។ ប្រសិនបើមិនមានវត្តមានរបស់មន្ត្រីនគរបាល ឬមន្ត្រីឃុំឃាំងម្នាក់ ឬសាក្សីយ៉ាងតិច២នាក់នោះលិខិតមតកសាសន៍នោះនិងចាត់ទុកថាគ្មានអានុភាពក្នុងការអនុវត្ត។

- ចំពោះជនដែលជាប់ក្នុងនាវា ឬយន្តហោះ

បុគ្គលដែលស្ថិតនៅក្នុងនាវា ឬយន្តហោះអាចធ្វើលិខិតមតកសាសន៍បានដោយតម្រូវឲ្យមានវត្តមានមេបញ្ជាការ បរិបាលនាវា យន្តហោះ ឬបុគ្គលិកនាវា ឬយន្តហោះម្នាក់ និងសាក្សីយ៉ាងតិច២(ពីរ)នាក់។

ជារួមមក ក្នុងស្ថានភាពទាំងពីរខាងលើនេះ ម្ចាស់បណ្តាំអាចធ្វើមតកសាសន៍ដោយផ្ទាល់មាត់ចំពោះមុខនគរបាល មន្ត្រីឃុំឃាំង មេបញ្ជាការ បរិបាលនាវា យន្តហោះ ឬបុគ្គលិកនាវា ឬយន្តហោះណាម្នាក់បានផងដែរ។ ចំពោះករណីខាងលើនេះ បញ្ញត្តិស្តីពីការធ្វើមតកសាសនស៍ដោយលិខិតយថាភូត ត្រូវបានអនុវត្តដូចគ្នា ពាក្យថា សារការីក្នុងករណីនេះ ត្រូវបានបកស្រាយថាជា នគរបាល មន្ត្រីឃុំឃាំង មេបញ្ជាការ បរិបាលនាវា យន្តហោះ ឬបុគ្គលិកនាវា ឬយន្តហោះ។

ករណីម្ចាស់បណ្តាំបន្តនៅមានជីវិតក្នុងអំឡុងពេល៦ខែគិតចាប់ពីពេលធ្វើលិខិតបណ្តាំទុក ក្រោយពីការដោះលែងពីការឃុំឃាំង ឬចុះចតពីនាវា ឬយន្តហោះ បើម្ចាស់បណ្តាំមានបំណងចង់ផ្លាស់ប្តូរ ឬធ្វើលិខិតមតក-សាសន៍ថ្មី ម្ចាស់បណ្តាំក៏មានសិទ្ធក្នុងការផ្លាស់ប្តូរនោះ ហើយត្រូវស្របតាមទម្រង់ណាមួយដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី ។ លិខិតមតកសាសន៍ធ្វើឡើងនៅកំឡុងពេលដែលជាប់ឃុំឃាំង ឬជាប់លើនាវា ឬ យន្តហោះ និងពុំមានអានុភាពយកមកការអនុវត្តបានឡើយ ប៉ុន្តែអនុវត្តជំនួសវិញនូវលិខិតមតកសាសន៍ច្បាប់ថ្មី ដែលបានសរសេរក្រោយពេលដែលម្ចាស់បណ្តាំត្រូវបាន ដោះលែងពីការជាប់ឃុំឃាំង ឬជាប់លើនាវា ឬយន្តហោះជាដើម។

[52] មាត្រា១១៧៨ នៃសេចក្តីពន្យល់មាត្រនីមួយៗក្រមរដ្ឋប្បវេណី។

### ៤. មតកសាសន៍ជនជាតិខ្មែររស់នៅបរទេស

មតកសាសន៍នេះត្រូវបានធ្វើឡើងសម្រាប់ជនជាតិខ្មែរដែលនៅរស់នៅបរទេស ដែលមានបំណងចង់ធ្វើលិខិតមតកសាសន៍។ ជនជាតិខ្មែរដែលរស់នៅបរទេសក៏អាចធ្វើមតកសាសន៍ជាលិខិតយថាភូត ឬលិខិតឯកជន និងលិខិតសម្ងាត់បាន ប៉ុន្តែចាំបាច់ត្រូវមានវត្តមានកុងស៊ុល ដើម្បីធ្វើឲ្យលិខិតមតកសាសន៍នោះមានអានុភាពក្នុងការអនុវត្តន៍។

ម៉្យាងវិញទៀត ជនជាតិខ្មែរដែលរស់នៅបរទេសក៏អាចប្រើប្រាស់វិធីសាស្ត្រផ្សេងទៀត ក្នុងការធ្វើលិខិតមតកសាសន៍ទៅតាមទម្រង់មតកសាសន៍នានាដូចបានកំណត់ក្នុងច្បាប់របស់ប្រទេសដែលខ្លួនកំពុងរស់នៅ។ ប៉ុន្តែត្រូវធ្វើចំពោះមុខសារការីនៃប្រទេសដែលខ្លួនបានរស់នៅនោះ។ ចំពោះការធ្វើលិខិតមតកសាសន៍នេះ ត្រូវធ្វើឡើងនៅចំពោះមុខសារការីដែលជាជនបរទេស និងត្រូវការប្រើប្រាស់ភាសានៃប្រទេសដែលខ្លួនបានរស់នៅក្នុងការសរសេរខ្លឹមសារនៃលិខិតមតកសាសន៍។ ហេតុនេះហើយ ដើម្បីអនុញ្ញាតឲ្យជនដែលមិនចេះភាសាបរទេសអាចមានលទ្ធភាពធ្វើមតកសាសន៍ជាលិខិតយថាភូត ឬលិខិតសម្ងាត់ជាភាសាខ្មែរបាន នោះកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានប្រគល់សិទ្ធិឲ្យអនុវត្តតួនាទីជំនួសសារការី ដើម្បីឲ្យលិខិតមតកសាសន៍នោះមានអានុភាពគ្រប់គ្រាន់ក្នុងការយកមកអនុវត្ត ហើយវត្តមានរបស់កុងស៊ុលគឺជាភាពចាំបាច់ចំពោះការធ្វើលិខិតមតកសាសន៍របស់ម្ចាស់បណ្តាំដែលរស់នៅបរទេស។[53]

### ៥. មតកសាសន៍ជនមិនអាចនិយាយបាន

សម្រាប់ជនពិការផ្នែកណាមួយដូចជា៖ មិនអាចនិយាយបាន ឬថ្លង់មិនអាចស្តាប់ឮ ហើយមានបំណងចង់ធ្វើលិខិតបណ្តាំ តើគាត់ត្រូវធ្វើយ៉ាងដូចម្តេច? យ៉ាងណាមិញឃើញថាទោះបីជាគាត់ជាជនពិការក៏ច្បាប់នៃព្រះរាជាណាចក្រកម្ពុជានៅតែការពារពួកគាត់ដូចបុគ្គលដទៃទៀត។ តាមគោលការណ៍សមភាពនៃសមត្ថភាពទទួលបានសិទ្ធិ៖ រូបវន្តបុគ្គលគ្រប់រូបមានលក្ខណៈសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិនិងកាតព្វកិច្ចបាន។[54]

លិខិតមតកសាសន៍នៃជនដែលមិនអាចនិយាយបាន ត្រូវបានធ្វើឡើងសម្រាប់បុគ្គលមិនអាចនិយាយបាន ដោយប្រើប្រាស់ការធ្វើកាយវិការជំនួសឲ្យការនិយាយ និងមានការបកប្រែពីអ្នកបកប្រែ ឬការសរសេរខ្លឹមសារនៃលិខិតបណ្តាំដោយដៃរបស់ម្ចាស់បណ្តាំផ្ទាល់។ ថ្វីបើ ម្ចាស់បណ្តាំជាជនដែលមិនអាចនិយាយបាន ប៉ុន្តែគាត់ក៏អាចធ្វើលិខិតមតកសាសន៍ជាទម្រង់លិខិតយថាភូត ឬលិខិតសម្ងាត់ ឬជាលិខិតឯកជនដែរ។ ម្ចាស់

[53] មាត្រា១១៨១ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី រៀបចំដោយគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១៤។

[54] មាត្រា ៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

បណ្តាំដែលមិនអាចនិយាយបានត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ភាសាសញ្ញា ឬសរសេរដោយដៃខ្លួនឯងផ្ទាល់ចំពោះមុខសារការី ឬសាក្សី ដើម្បីជំនួសការនិយាយប្រាប់ពីសេចក្តីថ្លែងការណ៍។ចំពោះករណីនេះត្រូវបានប្រើប្រាស់សម្រាប់ម្ចាស់បណ្តាំដែលអាចសរសេរអក្សរបាន និងយល់ដឹងពីអ្វីដែលខ្លួនបានសរសេរ។[55]

សាក្សីជាបុគ្គលមិនអាចស្តាប់ឮ(ថ្លង់)ក៏មិនខុសអ្វីពីម្ចាស់លិខិតមតកសាសន៍ដែលធ្វើឡើងដោយជនដែលមិនអាចនិយាយបានដែរ ដោយតម្រូវឲ្យមានអ្នកបកប្រែភាសាកាយវិការ ឬភាសាសញ្ញា ដើម្បីធ្វើកាយវិការឲ្យសាក្សីនោះបានយល់ពីខ្លឹមសារនៅក្នុងលិខិតមតកសាសន៍។

ក្រោយពីបានសរសេរលិខិតបណ្តាំជាលាយលក្ខណ៍អក្សររួច សារការីត្រូវអានខ្លឹមសារអត្ថន័យនៅក្នុងបណ្តាំឲ្យម្ចាស់បណ្តាំ និងសាក្សីបានស្តាប់ ឬឲ្យអ្នកបកប្រែជាអ្នកធ្វើកាយវិការតាមភាសាសញ្ញាបង្ហាញដល់ម្ចាស់បណ្តាំ ឬសាក្សីដែលមិនអាចស្តាប់ឮ។ ករណីសារការី និងជនផ្សេងទៀតត្រូវសរសេរអំពីហេតុទាំងនោះចូលក្នុងលិខិតមតកសាសន៍ផងដែរ។[56]

ក្នុងករណីនេះ អ្នកបកប្រែភាសាសញ្ញាជាបុគ្គលដ៏សំខាន់ក្នុងការធ្វើលិខិតមតកសាសន៍នោះឡើង ប្រសិនបើគ្មានវត្តមានអ្នកបកប្រែភាសាសញ្ញាទេ លិខិតមតកសាសន៍នោះក៏មិនអាចធ្វើឡើងបានដែរ។ ទោះបីជាអាចធ្វើឡើងមកបាន ក៏មិនមានអានុភាពគ្រប់គ្រាន់ក្នុងការអនុវត្តន៍ដែរ ដោយសារតែសារការី និងសាក្សីមិនយល់ពីភាសាសញ្ញារបស់ម្ចាស់បណ្តាំ ហើយម្ចាស់បណ្តាំក៏មិនអាចយល់ពីខ្លឹមសារដែលសារការីបានសរសេរ។ ដើម្បីឲ្យលិខិតមតកសាសន៍នោះមានអានុភាពគ្រប់គ្រាន់ទើបចាំបាច់តម្រូវឲ្យមានវត្តមានរបស់អ្នកបកប្រែភាសាសញ្ញាក្នុងការធ្វើលិខិតមតកសាសន៍របស់ជនដែលមិនអាចនិយាយបាន។ ហើយអ្នកបកប្រែភាសាសញ្ញាក៏ត្រូវបានចាត់ទុកជាសាក្សីដ៏សំខាន់ក្នុងការធ្វើលិខិតមតកសាសន៍នេះផងដែរ។

[55] មាត្រា១១៧៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

[56] មាត្រា១១៧៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

# ជំពូកទី២
# អានុភាព ការប្រតិបត្តិ និង ការលុបចោល
# នៃមតកសាសន៍

# ជំពូកទី២

# អានុភាព ការប្រតិបត្តិ និងការលុបចោលនៃមតកសាសន៍

បន្ទាប់ពីបានសិក្សាជំពូកទី១ដែលបានបកស្រាយពី លក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់នៃការបង្កើតលិខិតមតកសាសន៍ សមត្ថភាពរបស់មតកជន ជនដែលអាចក្លាយជាសាក្សី និងទម្រង់នៃមតកសាសន៍ទាំងទម្រង់ធម្មតា និងមតកសាសន៍ស្ថិតក្នុងស្ថានភាពពិសេសនៃការធ្វើលិខិតបណ្តាំកន្លងមកហើយ។ សម្រាប់ជំពូក២នេះបង្ហាញបន្ថែមពីផ្នែកសំខាន់ៗនានាដែលទាក់ទងនឹងលិខិតមតកសាសន៍។ តើកត្តាណាខ្លះដែលអាចឲ្យលិខិតមតកសាសន៍នោះមានអានុភាព? បន្ទាប់ពីបានបង្កើតលិខិតមតកសាសន៍រួច តើអ្នកណាជាអ្នកមានសិទ្ធិអនុវត្តលិខិតមតកសាសន៍? តើលិខិតមតកសាសន៍ធ្វើរួចអាចលុបចោលវិញបានដែរឬទេ? តើអ្នកណាដែលមានសិទ្ធិក្នុងការលុបចោលនេះ? តើការលុបចោលនោះមានអ្វីខ្លះ?

## ផ្នែកទី១៖ អានុភាពនៃមតកសាសន៍

មតកជនអាចធ្វើការបង្ហាញឆន្ទៈក្នុងការចាត់ចែងមត៌ក មុនពេលខ្លួនទទួលមរណភាពស្របតាមទម្រង់នៃមតកសាសន៍ដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណីហើយក៏ដោយ ក៏មិនបានន័យថាលិខិតមតកសាសន៍អាចមានអានុភាពភ្លាមៗដែរ។ នៅក្នុងជំពូកទី២ ផ្នែកទី១ និងនិយាយអំពីអានុភាពនៃលិខិតមតកសាសន៍ដែលមាន២(ពីរ)កថាខណ្ឌដូចជា៖ កថាខណ្ឌទី១ ពេលដែលមតកសាសន៍បង្កើតអានុភាព និងកថាខណ្ឌទី២ អានុភាពនៃការកំណត់ចំណែកមតកសាសន៍។

### កថាខណ្ឌទី១៖ ពេលដែលមតកសាសន៍បង្កើតអានុភាព

កថាខណ្ឌទី១ការបកស្រាយពី លិខិតមតកសាសន៍ដែលបង្កើតអានុភាព ឬជាជំហានដំបូងដែលអ្នកប្រតិបត្តិ ឬអ្នកទទួលអាណត្តិអនុវត្តតួនាទីរបស់ខ្លួន។ លិខិតមតកសាសន៍មានអានុភាពនៅពេលដែលម្ចាស់បណ្តាំទទួលមរណភាព ដោយឡែកលិខិតមតកសាសន៍មានលក្ខខណ្ឌបង្អង់ ដើម្បីយកទៅអនុវត្តបានលុះត្រាតែលក្ខខណ្ឌទាំងនោះត្រូវបានបំពេញចប់សព្វគ្រប់ ទើបបង្កើតឲ្យមានអានុភាពអនុវត្តលិខិតមតកសាសន៍តាមក្រោយ ចំណុចមួយទៀតដែលធ្វើឲ្យលិខិតមតកសាសន៍មានអានុភាពបានគឺ ការប្រកាសពីការបាត់ខ្លួនរបស់ម្ចាស់បណ្តាំ។

### ១. មរណភាពនៃម្ចាស់បណ្តាំ

លិខិតមតកសាសន៍ បង្កើតឲ្យមានអានុភាពបាននៅពេលដែលមតកជន ឬម្ចាស់បណ្តាំទទួលមរណភាព។[57] លិខិតមតកសាសន៍ ត្រូវកើតចេញពីឆន្ទៈផ្ទាល់របស់ម្ចាស់បណ្តាំ ស្របតាមទម្រង់ណាមួយ ហើយធ្វើឡើងដោយគ្មានការចាប់បង្ខំពីតតិយជនណាម្នាក់ ឬម្ចាស់បណ្តាំមិនស្ថិតក្រោមការហាមឃាត់ និងត្រូវបំពេញបែបបទយ៉ាងត្រឹមត្រូវតាមការកំណត់ទុកទើបមានសុពលភាព។ នៅក្រមរដ្ឋប្បវេណី បានបង្ហាញពីសិទ្ធិចាត់ចែងរបស់មតកជន ទៅលើទ្រព្យសម្បត្តិដែលខ្លួនមាននៅពេលខ្លួនជារូបវន្តបុគ្គល។ ឧទាហរណ៍ មតកជនធ្វើលិខិតបណ្តាំដោយក្នុងលិខិតបណ្តាំនេះមតកជនមានខ្លឹមសារថា ផ្ទះ១ខ្នងតម្លៃ ១០០,០០០$ (ដប់ម៉ឺនដុល្លារ) ប្រគល់ A ដែលជាសហព័ន្ធ ដី១កន្លែងប្រគល់ឲ្យB ជាកូនស្រីច្បង និង លុយ ២០០,០០០$ (ម្ភៃម៉ឺនដុល្លារ) នៅក្នុងធនាគារប្រគល់ឲ្យកូនប្រុសរបស់គាត់។ ក្រោយមកម្ចាស់បណ្តាំក៏ទទួលមរណភាព ហើយលិខិតបណ្តាំនឹងមានអានុភាពតាមការកំណត់ក្នុងខ្លឹមសារ។ ការរៀបរាប់ខាងលើនេះសម្រាប់ លិខិតមតកសាសន៍ដែលម្ចាស់បណ្តាំមិនបានចែងបង្កប់ពីលក្ខខណ្ឌបង្អង់នៃលិខិតមតកសាសន៍ និងមានអានុភាពបានភ្លាមៗ បន្ទាប់ពីម្ចាស់បណ្តាំបានទទួលមរណភាព។ ផ្ទុយទៅវិញ បើលិខិតមតកសាសន៍នោះមានភ្ជាប់លក្ខខណ្ឌបង្អង់ តើគេត្រូវធ្វើដូចម្តេច? អានុភាពវាកើតឡើងនៅពេលណា?

### ២. មតកសាសន៍ដែលភ្ជាប់លក្ខខណ្ឌបង្អង់

លិខិតមតកសាសន៍មានភ្ជាប់លក្ខខណ្ឌបង្អង់ គឺជាឆន្ទៈរបស់មតកជនដែលចង់ឲ្យសន្តតិជន ឬជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ បំពេញនូវលក្ខខណ្ឌណាមួយស្របតាមបំណងចុងក្រោយរបស់ខ្លួននាពេលអនាគត បន្ទាប់ពីខ្លួនបានបាត់បង់ជីវិត។ ក្រោយមតកជនទទួលមរណភាព សន្តតិជន ឬជនពាក់ព័ន្ធនឹងផលប្រយោជន៍ ត្រូវបំពេញតាមលក្ខខណ្ឌក្នុងលិខិតមតកសាសន៍ចប់ ទើបលិខិតមតកសាសន៍នោះមានអានុភាពតាមក្រោយ។[58] ឧទាហរណ៍៖ សុខ ដែលជាម្ចាស់បណ្តាំបានធ្វើលិខិតបណ្តាំទុក ហើយនៅក្នុងខ្លឹមសានៃលិខិតមតកសាសន៍ចែងថា ផ្ទះ ដី និងឡាន១គ្រឿង ប្រគល់ឲ្យកូនស្រីរបស់គាត់ បន្ទាប់ពីនាងបានបញ្ចប់ថ្នាក់

បរិញ្ញាបត្រ។ ដូចនេះលិខិតមតកសាសន៍នេះនឹងមានអានុភាពកើតឡើង នៅពេលដែលកូនស្រី(សន្តតិជន)របស់ម្ចាស់បណ្តាំបញ្ចប់ថ្នាក់បរិញ្ញាបត្រតែប៉ុណ្ណោះ។

ចំណុច១និង២ខាងលើនេះ បានបង្ហាញឲ្យដឹងច្បាស់ករណីម្ចាស់បណ្តាំទទួលមរណភាព ហើយលិខិតមតកសាសន៍អាចមានសុពលភាពភ្លាមៗ ឬករណីមានលក្ខខណ្ឌបង្អង់ក្នុងមតកសាសន៍ ត្រូវបំពេញលទើប

---

[57] មាត្រា១១៩៤ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

[58] មាត្រា១១៩៤ វាក្យខ័ណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

បង្កើតឲ្យមានអានុភាពនៃលិខិតមតកសាសន៍។ ជាក់ស្ដែងបើម្ចាស់បណ្ដាំបាត់ខ្លួន តើមាននីតិវិធីបែបណាខ្លះ? ដើម្បីអនុវត្តសន្តតិកម្ម តើលក្ខខណ្ឌណាខ្លះដែលអាចប្រកាសពីការបាត់ខ្លួន?

### ៣. ការប្រកាសពីការបាត់ខ្លួន

ក្នុងករណីបុគ្គលដែលជាម្ចាស់បណ្ដាំ ពុំមានដំណឹងច្បាស់លាស់ថានៅមានជីវិត ឬទទួលមរណភាព ក្នុងកំឡុងពេលណាមួយដូចបានកំណត់តាមនីតិវិធី ត្រូវចាត់ទុកថាម្ចាស់បណ្ដាំបានទទួលមរណភាពចំពោះទំនាក់ទំនងគតិយុត្តទាំងអស់។ ការប្រកាសពីការបាត់ខ្លួននេះត្រូវធ្វើឡើងតាមនីតិវិធីជូនដំណឹងការដាស់តឿនជាសាធារណៈជាមុនសិន។[59] យ៉ាងណាមិញក្រោយពីបានប្រកាសពីការដាស់តឿនជាសាធារណៈរួចហើយ នៅតែមិនឃើញម្ចាស់បណ្ដាំបង្ហាញខ្លួននៅតុលាការ នោះតុលាការនឹងចាប់ផ្ដើមនីតិវិធី ប្រកាសពីការបាត់ខ្លួនសារជាថ្មី ដោយសន្មតថាជននេះបានទទួលមរណភាព ហើយសន្តតិកម្មតាមមតកសាសន៍នឹងមានអានុភាពយកមកអនុវត្តន៍។

បន្ទាប់ពីការប្រកាសពីការបាត់ខ្លួននេះ លិខិតមតកសាសន៍បានបង្កើតអានុភាព ខណៈពេលនោះស្រាប់តែម្ចាស់បណ្ដាំបានបង្ហាញខ្លួន តើករណីនេះបុគ្គលជាម្ចាស់បណ្ដាំទទួលបានការការពារផលប្រយោជន៍ដែរឬទេ? ជាការពិតណាស់យោងតាមក្រមរដ្ឋប្បវេណីបានចែងច្បាស់ថា បុគ្គលដែលត្រូវបានប្រកាសពីការបាត់ខ្លួនដោយសន្តតិជន ឬអ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ មានសិទ្ធទទួលបានការការពារផលប្រយោជន៍របស់ខ្លួនបាន។ ដោយជាដំបូងសាមីខ្លួន ត្រូវដាក់ពាក្យសុំលុបចោល ការប្រកាសពីការបាត់ខ្លួននោះជាមុនសិនទើបអាចទទួលបានសិទ្ធិការពារផលប្រយោជន៍ ទោះបីជាសាមីខ្លួនដែលជាម្ចាស់បណ្ដាំនៅមានជីវិត ប៉ុន្តែបើម្ចាស់បណ្ដាំមិនបានទៅបង្ហាញមុខ ដាក់ពាក្យសុំការលុបចោលពីការប្រកាសបាត់ខ្លួននៅតុលាការនោះទេ នោះអានុភាពនៃការប្រកាសការបាត់ខ្លួននៅតែបន្តកើតមានរហូត។[60]

ការប្រកាសនៃការបាត់ខ្លួនមាន២ប្រភេទ គឺ ការបាត់ខ្លួនធម្មតា និងការបាត់ខ្លួនពិសេស។[61]

ការប្រកាសបាត់ខ្លួនធម្មតា គឺស្ថានភាពដែលមិនដឹងច្បាស់ថាមតកជននៅមានជីវិត ឬបាត់បង់ជីវិតក្នុងកំឡុងពេល៥ឆ្នាំ ដោយគ្មានវត្តមានឬគ្មានដំណឹងរបស់មតកជនសោះ។ ស្ថានភាពបែបនេះសន្តតិជន ឬអ្នកពាក់ព័ន្ធនឹងផលប្រយោជន៍អាចធ្វើការដាក់ពាក្យតាមផ្លូវច្បាប់ សុំទៅតុលាការ ប្រកាសពីការបាត់ខ្លួនរបស់

---

[59] មាត្រា ៤២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

[60] មាត្រា ៤៤ វាក្យខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

[61] នីតិរដ្ឋប្បវេណី *គម្រោងបណ្ដុះបណ្ដាលអ្នកច្បាប់កម្ពុជាឧបត្ថម្ភដោយ JICA* សមិទ្ធិផលរបស់ក្រុមការងារសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំ ២០១២-២០១៧ ទំព័រទី ៧,៨។

មតកជនឬម្ចាស់បណ្តាំបាន។ ឧទាហរណ៍ បុគ្គលឈ្មោះ ក បានធ្វើលិខិតបណ្តាំទុក បន្ទាប់មកខ្លួនក៏ចេញទៅរកស៊ីនៅខេត្តផ្សេង ចោលប្រពន្ធ កូនអស់រយៈពេល៥(ប្រាំ)ឆ្នាំកន្លះ ដោយគ្មានដំណឹងអ្វីសោះស្ថានភាពបែបនេះ ប្រពន្ធកូនរបស់គាត់អាចដាក់ពាក្យសុំប្រកាសពីការបាត់ខ្លួនរបស់ ក ទៅតុលាការបាន ហើយអានុភាពនៃលិខិតបណ្តាំនិងកើតមានផងដែរ។

ការប្រកាសការបាត់ខ្លួនពិសេស គឺជាករណីមួយដែលបុគ្គលជាម្ចាស់បណ្តាំបានចូលទៅ តំបន់មានសង្គ្រាម ឬមានវត្តមាននៅក្នុងនាវាលិចទឹក ឬទៅតំបន់មានគ្រោះថ្នាក់ផ្សេងៗអាចធ្វើឲ្យបាត់បង់ជីវិត ហើយពុំមានដំណឹងច្បាស់លាស់ក្នុងកំឡុងពេល ១ (មួយ)ឆ្នាំ បន្ទាប់ពីហេតុកាណ៍នោះត្រូវបានបញ្ចប់ ត្រូវចាត់ទុកថាបុគ្គលនោះបានទទួលមរណភាព។[62] ដូចនេះលិខិតមតកសាសន៍ មានអានុភាពនូវពេលតុលាការប្រកាសពីការបាត់ខ្លួនរបស់បុគ្គលនោះ។ ឧទាហរណ៍ ក ជាម្ចាស់បណ្តាំ ហើយគាត់ជាទាហានម្នាក់ ចូលរួមធ្វើសង្គ្រាមក្នុងសមរភូមិ។ បន្ទាប់ពីសង្គ្រាមត្រូវបានបញ្ចប់ បែរជាបាត់ដំណឹងរបស់ ក អស់រយៈពេល២ឆ្នាំ ខ ដែលជាប្រពន្ធ និងជាសន្តតិជនបានសម្រេចចិត្តដាក់ពាក្យសុំទៅតុលាការ ដើម្បីធ្វើការប្រកាសពីបាត់ខ្លួនរបស់ ក ឬម្ចាស់បណ្តាំ។

**កថាខណ្ឌទី២៖ អានុភាពនៃការកំណត់ចំណែកមត៌ក**

ជាគោលការណ៍ បើមតកជនបានកំណត់ចំណែកមតកសាសន៍ ឬវិធីបែងចែកមត៌កជាក់លាក់តែមួយ ឬ ច្រើន ដោយអនុប្បទានចំពោះសន្តតិជនតែម្នាក់ ឬច្រើននាក់ តាមរយៈលិខិតមតកសាសន៍ទ្រព្យសម្បត្តិនោះត្រូវធ្លាក់ទៅលើសន្តតិជនដោយស្វ័យប្រវត្តិ ចាប់តាំងពីពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ស្មើនឹងលិខិត មតកសាសន៍មានបង្កើតអានុភាព។[63] ផ្ទុយទៅវិញករណីជនដែលសន្មតថាជាសន្តតិជនបានទទួលមរណភាព មុនពេលចាប់ផ្តើមសន្តតិកម្ម ត្រូវរកសន្តតិជនជំនួស ដើម្បីមកទទួលសន្តតិកម្មនោះ ហើយបើគ្មានសន្តតិជនជំនួសទេ ត្រូវចាត់ទុកថាលិខិតមតកសាសន៍ ចំពោះជនដែលសន្មតថាជាសន្តតិជននោះគ្មានអានុភាព។[64] ក្នុងករណីដែលលិខិតមតកសាសន៍ មិនបានកំណត់ចំណែកមត៌កទៅឲ្យសន្តតិជនណាម្នាក់ ប៉ុន្តែបានចែងពីវិធីបែងចែកចំណែកទ្រព្យសម្បត្តិ នោះអ្នកអនុវត្តមកតសាសន៍ត្រូវធ្វើតាមការកំណត់ក្នុងលិខិតមតកសាសន៍ ដោយមិនចាំបាច់ពិភាក្សាជាមួយសហសន្តតិជនណាឡើយ។

[62] មាត្រា ៤១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

[63] មាត្រា១១៩៥ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

[64] ក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ សមិទ្ធផល គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ ក្រសួងយុត្តិធម៌ បោះពុម្ពលើកទី១.ខែធ្នូ ឆ្នាំ ២០១៥ ទំព័រ៦៣និង៦៤។

មួយវិញទៀត បើលិខិតមតកសាសន៍នោះភ្ជាប់ជាមួយលក្ខខណ្ឌបង្អង់ លុះត្រាតែលក្ខខណ្ឌត្រូវបានបំពេញតាមការកំណត់របស់មតកជន ទើបសន្តតិជនអាចទទួលបាននៅចំណែកមត៌ក នៃទ្រព្យសម្បត្តិដោយប្រតិសកម្មគិតចាប់ពីពេលម្ចាស់បណ្តាំទទួលមរណភាព។

ដោយឡែកចំពោះអច្ច័យទាន ពុំមានអានុភាពឡើយ ប្រសិនបើអច្ច័យលាភីជាអភ័ព្វបុគ្គល ឬទទួលមរណភាពមុនម្ចាស់បណ្តាំ ឬដំណាលគ្នានឹងម្ចាស់បណ្តាំ។ កម្មវត្ថុដែលជាអច្ច័យទានទាំងអស់ត្រូវធ្លាក់ទៅលើសន្តតិជនវិញ។ ប៉ុន្តែបើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈ ពិសេសផ្សេងពីនេះ អ្នកប្រតិបត្តិមតកសាន៍ ត្រូវអនុវត្តតាមខ្លឹមសារនៃបណ្តាំនោះ។ ទោះបីអច្ច័យទាន កើតចេញពីឆន្ទៈនិងសកម្មភាពឯកតោភាគីរបស់ម្ចាស់បណ្តាំក្នុងការបែងចែកទ្រព្យសម្បត្តិទៅឲ្យអច្ច័យលាភីយ៉ាងណាក៏ដោយ ក៏មិនត្រូវចាប់បង្ខំឲ្យអច្ច័លាភីទទួលយកឬអនុវត្តតាមការសម្រេចចិត្តរបស់ម្ចាស់បណ្តាំដែរ។ អច្ច័យលាភី មានសិទ្ធិក្នុងការបដិសេធ និងបោះបង់ចំពោះអច្ច័យទាន ហើយអច្ច័យទានក៏គ្មានអានុភាពចំពោះអច្ច័យលាភីបន្ទាប់ពីការបោះបង់សិទ្ធិនោះ។[65]

## ផ្នែកទី២៖ ការប្រតិបត្តិមតកសាសន៍

ជាទូទៅដើម្បីអនុវត្តលិខិតបណ្តាំបាន អ្នកប្រតិបត្តិមតកសាសន៍ទាំងអស់ត្រូវគោរពតាមគោលការណ៍នីតិវិធីនៃការប្រតិបត្តិមតកសាសន៍ដែលមានចែងក្នុងក្រមរដ្ឋប្បវេណី។ នៅផ្នែកទី២ ចំពោះការប្រតិបត្តិលិខិតមតកសាសន៍នេះ សិក្សាទៅលើ២ កថាខណ្ឌដូចជា៖ កថាខណ្ឌទី១ ការពិនិត្យបញ្ជាក់ និងការបើកលិខិតមតកសាសន៍ កថាខណ្ឌទី២ ការជ្រើសរើសអ្នកប្រតិបត្តិមតកសាសន៍។

### កថាខណ្ឌទី១៖ ការពិនិត្យបញ្ជាក់ និង ការបើកលិខិតមតកសាសន៍

#### ១. តុលាការដែលមានសមត្ថកិច្ចខាងលំនៅឋាន

អ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ ចាំបាច់យកលិខិតនេះទៅពិនិត្យបញ្ជាក់ដោយគ្មានការយឺតយ៉ាវនៅតុលាការ ហើយត្រូវភ្ជាប់ជាមួយនិងលិខិតមតកសាសន៍ ក្រោយមរណភាពរបស់ម្ចាស់បណ្តាំ បន្ទាប់ពីខ្លួនបានដឹងពីពេលចាប់ផ្តើមសន្តតិកម្មមុននឹងយកលិខិតមតកសាសន៍ទៅអនុវត្តន៍។ ករណី រកឃើញលិខិតមតកសាសន៍ ក្រោយមរណភាពរបស់មតកជនដោយគ្មានអ្នកគ្រប់គ្រងលិខិតបណ្តាំ សន្តតិជន ឬអ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ ត្រូវដាក់ពាក្យសុំទៅតុលាការ ដើម្បីធ្វើការពិនិត្យបញ្ជាក់ បន្ទាប់ពីបានរកឃើញនៅលិខិតមតកសាសននោះ។

[65] ក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ សមិទ្ធផល គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ ក្រសួងយុត្តិធម៌ បោះពុម្ពលើកទី១.ខែធ្នូ ឆ្នាំ ២០១៥ទំព័រ៦៥។

គោលបំណងនៃការពិនិត្យបញ្ជាក់នៅតុលាការ គឺដើម្បីការពារការក្លែងបន្លំ និងធ្វើឲ្យសន្តតិជន ឬបុគ្គល ដែលពាក់ព័ន្ធនឹងផលប្រយោជន៍បានដឹងឮ ហើយមានទំនុកចិត្តទៅលើខ្លឹមសារនៃលិខិតមតកសាសន៍ ពោលគឺ បញ្ជាក់ថាលិខិតមតកសាស៍ពិតជាត្រឹមត្រូវទៅតាមផ្លូវច្បាប់ និងស្របតាមទម្រង់ដូចកំណត់ក្នុងក្រមរដ្ឋប្បវេណី។ គ្រប់លិខិតបណ្ដាំទាំងអស់ត្រូវឆ្លងកាត់នីតិវិធី ត្រួតពិនិត្យនៅតុលាការ (លើកលែងលិខិតមតកសាសន៍ធ្វើជា លិខិតយថាភូត) ចៅក្រមជាអ្នកដើរតួនាទីសម្រេចសេចក្ដីដោយអព្យាក្រឹត្យ និងមិនលំអៀងទៅលើការពិនិត្យ និង ការបញ្ជាក់លិខិតមតកសាសន៍។

ករណីលិខិតមតកសាសន៍បិទដោយប្រថាប់ត្រា ត្រូវបើកនៅតុលាការតាមនីតិវិធីរបស់តុលាការ និង មានវត្តមានអ្នកអង្កេតការណ៍ ឬអ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ ឬអ្នកតំណាង។ ការធ្វើបែបនេះ ដើម្បីការពារកុំ ឲ្យមានការកែប្រែ និងបង្កើនទំនុកចិត្តកាន់តែខ្ពស់ទៅលើខ្លឹមសារនៃលិខិតមតកសាសន៍។

ទោសពិន័យចំពោះជនណាប្រព្រឹត្តខុស ឬអ្នកបើកលិខិតមតកសាសន៍នៅក្រៅតុលាការហើយមិន អនុវត្តតាមបញ្ញត្តិនៃនីតិវិធីរបស់តុលាការ និងត្រូវពិន័យស៊ីវិលជាប្រាក់មិនលើសពី ១,០០០,០០០៛ (មួយលាន រៀល)។ យ៉ាងណាមិញ ការបើកលិខិតមតកសាសន៍ដោយផ្ទុយទៅនឹងនីតិវិធីរបស់តុលាការ ឬបើកក្រៅតុលាការ ក៏លិខិតមតកសាសន៍នោះមិនបានបាត់បង់អានុភាពដែរ ប៉ុន្តែអាចធ្វើឲ្យសន្តតិជន ឬអ្នកពាក់ព័ន្ធផលប្រយោជន៍ មានការព្រួយបារម្ភពីសុក្រឹត្យភាពនៃលិខិតមតកសាសន៍នោះប៉ុណ្ណោះ។[66]

**២. លិខិតមតកសាសន៍យថាភូតដែលតម្កល់នៅសារការី**

លិខិតមតកសាសន៍ដែលមតកជនធ្វើឡើង ស្របតាមទម្រង់យថាភូត នៅចំពោះមុខសារការីមាន អានុភាពយកទៅអនុវត្តបាន ដោយមិនចាំបាច់សុំការពិនិត្យបញ្ជាក់ឬបើកនៅតុលាការទេ។ សារការី គឺជាអ្នក ច្បាប់ដែលទទួលបានប្រតិភូកម្មអំណាចពីរដ្ឋ ដើម្បីអនុវត្តមុខងាររបស់ខ្លួនស្របតាមច្បាប់ ហើយសារការីជា អ្នកធានានូវតុល្យាភាព ប្រសិទ្ធិភាព និងសុវត្ថិភាពគតិយុត្តរក្សា និងតម្កល់នៃលិខិតផ្សេង។

**កថាខណ្ឌទី២៖ ការជ្រើសរើសអ្នកប្រតិបត្តិមតកសាសន៍**

កថាខណ្ឌទី២ ការជ្រើសរើសអ្នកប្រតិបត្តិមតកសាសន៍សិក្សាទៅលើ ៥ ចំណុចដូចជា៖ ១. ការកំណត់ អ្នកប្រតិបត្តិដោយម្ចាស់បណ្ដាំ ២.ជនដែលមិនអនុញ្ញាតឲ្យក្លាយជាអ្នកប្រតិបត្តិមតកសាសន៍ ៣.តួនាទីរបស់អ្នក ប្រតិបត្តិមតកសាសន៍ ៤.ការចំណាយសម្រាប់មតកសាសន៍ និង៥.ការបញ្ចប់មុខងារអ្នកប្រតិបត្តិមតកសាសន៍។

[66] មាត្រា១២១៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

## ១. ការកំណត់អ្នកប្រតិបត្តិដោយម្ចាស់បណ្តាំ

### ១.១. ការកំណត់អ្នកប្រតិបត្តិដោយម្ចាស់បណ្តាំនៅក្នុងមតកសាសន៍

ម្ចាស់បណ្តាំអាចកំណត់អ្នកប្រតិបត្តិមតកសាសន៍តែម្នាក់ ឬច្រើននាក់ ឬអាចប្រគល់អាណត្តិឲ្យទៅតតិយជនណាម្នាក់ជាអ្នកកំណត់អ្នកប្រតិបត្តិមតកសាសន៍ តាមរយៈលិខិតមតកសាសន៍បាន។[67] ករណីម្ចាស់បណ្តាំបានកំណត់អ្នកតំណាងឲ្យខ្លួនឯង ដើម្បីធ្វើការកំណត់អ្នកប្រតិបត្តិមតកសាសន៍មានច្រើននាក់ នោះអ្នកប្រតិបត្តិត្រូវសម្រេចដោយសំឡេងលើសពីពាក់កណ្តាល លើកលែងតែម្ចាស់បណ្តាំបានបង្ហាញឆន្ទៈទុកជាមុន។

សន្តតិជន ឬជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍អាចកំណត់ពេលសមរម្យ និងធ្វើការដាស់តឿនចំពោះជនដែលត្រូវបានកំណត់ថាជាអ្នកប្រតិបត្តិមតកសាសន៍ ឬអ្នកទទួលអាណត្តិនោះឲ្យធ្វើការឆ្លើយតបក្នុងកំឡុងពេលមួយថា យល់ព្រម ឬមិនយល់ព្រមចំពោះការកាន់មុខងាររបស់ខ្លួន និងត្រូវអាស្រ័យលើឆន្ទៈរបស់បុគ្គលនោះដែរ។ ករណីដែលមិនឆ្លើយតបបញ្ជាក់តាមកំណត់នៃការដាស់តឿនរបស់សន្តតិជនទេ ត្រូវសន្មតថាអ្នកប្រតិបត្តិមតកសាសន៍បានលាឈប់ពីតួនាទីឬអាណត្តិការងារនោះ។[68]

### ១.២. ការប្រគល់អាណត្តិទៅឲ្យតតិយជនជាអ្នកកំណត់អ្នកប្រតិបត្តិ

ជនទទួលអាណត្តិ ពីមតកជនត្រូវកំណត់អ្នកប្រតិបត្តិមតកសាសន៍ និងជូនដំណឹងទៅឲ្យសន្តតិជន ឬជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ដោយគ្មានការយឺតយ៉ាវ។[69] ករណីនៅក្នុងលិខិតមតកសាសន៍មិនបានចែងពីការហាមឃាត់បុគ្គល ដែលជាអ្នកទទួលអាណត្តិក្នុងការកំណត់អ្នកប្រតិបត្តិមតកសាសន៍ទេ នោះអ្នកទទួលអាណត្តិក៏អាចតែងតាំងខ្លួនជាអ្នកអនុវត្តតួនាទីប្រតិបត្តិមតកសាសន៍បានដែរ។ ផ្ទុយទៅបើអ្នកទទួលអាណត្តិមានបំណងចង់លាឈប់ពីការងាររបស់ខ្លួន នោះត្រូវជូនដំណឹងពីមូលហេតុចំពោះការលាឈប់នេះឲ្យបានសមរម្យទៅសន្តតិជន។ យ៉ាងណាមិញការងារអាណត្តិនេះបានទទួលអាណត្តិពីម្ចាស់បណ្តាំ ដើម្បីធ្វើការកំណត់អ្នកប្រតិបត្តិមតកសាសន៍ក៏ដោយ ក៏មិនត្រូវចាប់បង្ខំឲ្យអនុវត្តករណីកិច្ចនេះដែរ អ្នកទទួលអាណត្តិមានសិទ្ធិបដិសេធចំពោះការងារទទួលអាណត្តិនេះ ហើយត្រូវជូនដំណឹងទៅឲ្យសន្តតិជនដោយគ្មានការយឺងយ៉ាវ។[70]

---

[67] មាត្រា ១១៨៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

[68] មាត្រា១២១៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

[69] មាត្រា១២៤៤ កថាខ័ណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

[70] មាត្រា១២១៤ កថាខ័ណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

ផ្ទុយទៅវិញ បើអ្នកទទួលអាណត្តិក្នុងការកំណត់អ្នកប្រតិបត្តិមតកសាសន៍ មិនអនុវត្តតួនាទីរបស់ខ្លួន តាមការកំណត់ ដោយមានការដាស់តឿនពីសន្តតិជន ឬអ្នកដែលពាក់ព័ន្ធនឹងផលប្រយោជន៍ហើយ នៅតែមិន មានការឆ្លើយតបវិញ នោះត្រូវចាត់ទុកថាបានលាឈប់ពីតួនាទី ឬអាណត្តិការងារ។[71]

## ១.៣ ការជ្រើសតាំងដោយតុលាការ

តុលាការមានសមត្ថកិច្ចក្នុងការជ្រើសតាំង អ្នកប្រតិបត្តិមតកសាសន៍ជាថ្មី តាមការដាក់ពាក្យស្នើសុំ របស់សន្តតិជន ឬអ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍ចាស់បានលាឈប់ ពីការងារ ឬគ្មានអ្នកប្រតិបត្តិ ឬបាត់បង់អ្នកប្រតិបត្តិមតកសាសន៍ ដោយខ្វះលក្ខណសម្បត្តិដូចជា៖ បុគ្គលដែល ត្រូវបានហាមឃាត់តាមការកំណត់របស់ច្បាប់ ការអនុញ្ញាតិឲ្យលាឈប់ពីតុលាការ ឬការបញ្ឈប់តួនាទីដោយ ហេតុណាមួយផ្សេងទៀត។[72]

## ២. ជនដែលមិនអនុញ្ញាតឲ្យក្លាយជាអ្នកប្រតិបត្តិមតកសាសន៍

អ្នកប្រតិបត្តិមតកសាសន៍ ឬអ្នកដែលទទួលអាណត្តិក្នុងការកំណត់អ្នកប្រតិបត្តិមតកសាសសន៍ជាជន ដែលត្រូវសកម្មភាពគតិយុត្តិផ្សេងៗ ហេតុនេះទើបមានការកម្រិតសមត្ថភាពរបស់អ្នកប្រតិបត្តិមតកសាសន៍។

បុគ្គលត្រូវហាមឃាត់មិនឲ្យក្លាយជាអ្នកប្រតិបត្តិមាន[73] ៖

- ជននៅក្រោមអាណាព្យាបាលទូទៅ៖ ជាជនដែលខ្វះខាតសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពី លទ្ធផលតាមផ្លូវច្បាប់នៃសម្មកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី។
- ជននៅក្រោមហិតូបត្ថម្ភ៖ ជាជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និងធ្វើការពិបាកក្នុង ការវិនិឆ្ឆ័យអំពីលទ្ធផលតាមច្បាប់នៃរបស់ទង្វើរបស់ខ្លួន ដោយសារវិបត្តិផ្នែកបញ្ញាស្មារតី ហើយ តុលាការបានប្រកាសចាប់ផ្តើមហិតូបត្ថម្ភលើជននោះ។
- អនីតិជន៖ ជាជនដែលមានអាយុក្រោម១៨ឆ្នាំ។
- និងជនធនក្ស័យ៖ សំដៅដល់ជនដែលត្រូវបានប្រកាសដោយតុលាការដែលមិនអាចសងកាតព្វកិច្ច ដោយសារការដួលរលំនូវសេដ្ឋកិច្ចរបស់ខ្លួន។

---

[71] មាត្រា១២១៦ កថាខ័ណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

[72] មាត្រា១២១៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

[73] មាត្រ១២១៧ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ៣. តួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍

អ្នកប្រតិបត្តិមតកសាសន៍មានសិទ្ធិ និងករណីយកិច្ចក្នុងការគ្រប់គ្រងមត៌ក និងធ្វើនូវរាល់សកម្មភាពផ្សេងទៀតដែលចាំបាច់ ដើម្បីអនុវត្តលិខិតមតកសាសន៍។[74]

ជាដំបូងតួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍បន្ទាប់ពីចូលកាន់មុខងាររបស់ខ្លួននោះ គឺត្រូវរៀបចំបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិរបស់មតកជន។ បន្ទាប់ពីរៀបចំបញ្ជីសារពើភ័ណ្ឌរួច អ្នកប្រតិបត្តិមតកសាសន៍មានករណីយកិច្ចប្រគល់របាយការណ៍ និងត្រូវសងសំណង ករណីខ្លួនបានប្រើប្រាស់លុយដែលជាមត៌ក ឬប្រើប្រាស់លុយសម្រាប់ត្រៀមក្នុងដំណើរការអនុវត្តសន្តតិកម្ម និងត្រូវប្រគល់ឲ្យសន្តតិជន ឬជនពាក់ព័ន្ធនឹងផលប្រយោជន៍ដោយគ្មានការយឺតយ៉ាវ។[75] បញ្ជីសារពើភ័ណ្ឌចាំបាច់ត្រូវមាន ដើម្បីងាយស្រួលកំណត់ឲ្យបានច្បាស់លាស់អំពីកម្មវត្ថុនៃសិទ្ធគ្រប់គ្រងចាត់ចែងមតក៍ ។

សកម្មភាពចាត់ចែងរបស់អ្នកប្រតិបត្តិមតកសាសន៍ ត្រូវមានអានុភាពទៅលើសន្តតិជន និងអ្នកពាក់ព័ន្ធផលប្រយោជន៍ដែលជាប្រធាននៃសិទ្ធិ។ ទោះបីជាសន្តតិជនជាប្រធាននៃសិទ្ធិពិតមែនក៏ដោយ ករណីមានវត្តមានអ្នកប្រតិបត្តិមតកសាសន៍ នោះសន្តតិជនពុំអាចចាត់ចែងមត៌ក ឬធ្វើសកម្មភាពផ្សេងៗរារាំងដល់ការប្រតិបត្តិមតកសាសន៍បានឡើយ។ សន្តតិជន និងអ្នកប្រតិបត្តិមតកសាសន៍មានសិទ្ធអំណាច ការចាត់ចែងទៅលើកមត៌កដូចគ្នា តើនិងមានអ្វីកើតឡើង? ច្បាស់ជាពិបាកដល់ការអនុវត្តមត៌កដែលជារឿងទាក់ទងនិងផលប្រយោជន៍ទាំងអស់ ដូចនេះបើបើកសិទ្ធិឲ្យសន្តតិជនមានសិទ្ធិចាត់ចែងស្មើគ្នា និងអ្នកប្រតិបត្តិមតកសាសន៍នោះអ្នកប្រតិបត្តិមតកសាសន៍ច្បាស់ជាមិនអាចអនុវត្តតួនាទីបានពេញលេញទេ និងអាចធ្វើឲ្យមានការខ្វែងគំនិតគ្នាជាមិនខាន។[76]

### ៤. ការចំណាយសម្រាប់មតកសាសន៍

ដំណើរការនៃការអនុវត្តមតកសាសន៍ តាំងពីដំបូងរហូតដល់បញ្ចប់ មានការចំណាយជាច្រើនសម្រាប់រៀបចំនឹងចាត់ចែងបែបទផ្សេងៗឲ្យមានត្រឹមត្រូវ តាមនីតិវិធីស្របតាមការកំណត់ទុកជាមុន នៃក្រមរដ្ឋប្បវេណី។ ការចំណាយគ្រប់សកម្មភាពនីមួយៗ ដើម្បីដំណើរការប្រតិបត្តិមតកសាសន៍ មិនត្រូវកាត់បន្ថយភាគបម្រុងទេ។

---

[74] មាត្រា១២២០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

[75] មាត្រា១២១៩ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី រៀបចំដោយគណៈកម្មការទទួលបន្ទុកកាពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១៤។

[76] មាត្រា១២២១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

ការចំណាយនេះបែងចែកជា ២(ពីរ) ទី១. ការចំណាយទៅលើសោហ៊ុយនៃការប្រតិបត្តិលិខិតមតកសាន់ និងទី ២. កម្រៃអ្នកប្រតិបត្តិមតកសាសន៍។

## ៤.១ សោហ៊ុយនៃការប្រតិបត្តិមតកសាសាន៍

ការចំណាយទៅលើសកម្មភាពដូចជា៖ ការដាក់ពាក្យសុំពិនិត្យបញ្ជាក់ ទៅលើលិខិតមកតសាសន៍នៅតុលាការ ការចំណាយចាំបាច់ក្នុងការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ ការចំណាយទៅលើការគ្រប់គ្រងមត៌ក ឬសកម្មភាពផ្សេងៗទៀត ពាក់ព័ន្ធនឹងដំណើរការអនុវត្តលិខិតបណ្តាំ ព្រមទាំងកម្រៃរបស់អ្នកប្រតិបត្តិមតកសានសន៍ ជាបន្ទុកដែលត្រូវដកចេញពីចំណែកមត៌ក ប៉ុន្តែការចំណាយទាំងនេះមិនអាចកាត់បន្ថយភាពបម្រុងបានឡើយ។[77]

## ៤.២. កម្រៃអ្នកប្រតិបត្តិមតកសាសន៍

កម្រៃនៃអ្នកប្រតិបត្តិមតកសាសន៍អាចមាន ២ករណី ដូចគ្នានឹងការងារអាណត្តិដែរ៖ការប្រតិបត្តិដោយយកកម្រៃ និងការប្រតិបត្តិដោយមិនយកកម្រៃ ។

### ក.ការប្រតិបត្តិដោយយកកម្រៃ

ការងារប្រតិបត្តិមតកសាសន៍ ជាការងារដែលមានភាពស្មុកស្មាញ ហើយមានករណីកិច្ចចាត់ចែងជាច្រើនដើម្បីធ្វើឲ្យដំណើរការនៃការប្រតិបត្តិមតកសាសន៍ទៅដោយរលូន និងទាមទារឲ្យមានការទទួលខុសត្រូវខ្ពស់ ការប្រុងប្រយ័ត្នខ្ពស់ ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត។ ប្រសិនបើមានករណីប្រតិបត្តិមតកសាសន៍មានបញ្ហា ឬធ្វើឲ្យខូចខាតប៉ះពាល់ដល់មតកសាសន៍នេះ សន្តតិជន ឬអ្នកដែលពាក់ព័ន្ធនឹងផលប្រយោជន៍អាចទាមទារសំណង់នៃការខូចខាតពីអ្នកប្រតិបត្តិមតកសាសន៍បាន។

ចំនួនទឹកប្រាក់របស់អ្នកប្រតិបត្តិមតកសាសន៍ និងត្រូវទទួលបានតាមការកំណត់ទុកជាមុននៅក្នុងលិខិតមតកសាសន៍។ ក្នុងករណី លិខិតមតកសាន៍កំណត់ថាគ្មានកម្រៃ អ្នកប្រតិបត្តិមតកសាសន៍ក៏គ្មានសិទ្ធទាមទារកម្រៃដែរ បើមានការមិនពេញចិត្តក្នុងការអនុវត្តតួនាទី អ្នកប្រតិបត្តិមតកសាសន៍ មានសិទ្ធិការបដិសេធតួនាទីការងារនេះបាន ប៉ុន្តែបើលិខិតមតកសាសន៍មិនបានកំណត់ ពីកម្រៃ ក៏មិនបានកំណត់ថាគ្មានកម្រៃនោះអ្នកប្រតិបត្តិមតកសាសន៍ អាចដាក់ពាក្យសុំទាមទារកម្រៃទៅតុលាការ ហើយតុលាការនឹងកំណត់ពីកម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍ តាមការគួរសមថាត្រូវទទួលបាន ឬមិនត្រូវទទួលបានកម្រៃ។ ជាក់ស្តែងការកំណត់កម្រៃនេះតុលាការត្រូវគណនាហើយពិចារណា តាមស្ថានភាពនៃមតកសាសន៍ និងទំនាក់ទំនងម្ចាស់

[77] មាត្រា១២២៨ នៃរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

បណ្តាំជាមួយអ្នកប្រតិបត្តិមតកសាសន៍ ព្រមទាំងស្ថានភាពផ្សេងៗទៀត ដើម្បីបង់កម្រៃទៅឲ្យអ្នកប្រតិបត្តិមតកសាសន៍។[78]

### ខ.ការប្រតិបត្តិដោយមិនយកកម្រៃ

ការប្រតិបត្តិមតកសាសន៍ដោយមិនយកកម្រៃ អាចកើតមាននៅក្នុងករណី សន្តតិជនជាអ្នកប្រតិបត្តិមតកសាសន៍ ហើយការប្រតិបត្តិនោះមានភាពងាយស្រួល ដូចនេះអ្នកប្រតិបត្តិមតកសាសន៍ដែលជាសន្តតិជនមិចចាំបាច់យកកម្រៃក៏បាន។[79] ករណីមានការខូចខាតដល់ផលប្រយោជន៍របស់សន្តតិជនដទៃ ឬអ្នកដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ដោយខ្វះការប្រុងប្រយ័ត្ន នោះតុលាការនឹងការបន្ថយសំណងនៃខូចខាត និងការទទួលខុសត្រូវរបស់អ្នកប្រតិបត្តិមតកសាសន៍នោះ។[80]

## ៥. ការបញ្ចប់មុខងារអ្នកប្រតិបត្តិមតកសាសន៍

### ៥.១ សិទ្ធិជ្រើសតាំងបន្ត

អ្នកប្រតិបត្តិមកតសាសន៍ មិនត្រូវអនុញ្ញាតិឲ្យតតិយជនអនុវត្តភារកិច្ចរបស់ខ្លួនទេ ប៉ុន្តែបើមានមូលហេតុពុំអាចជៀសវាងបាន និងករណីមានការចែងអនុញ្ញតិទុកជាមុនក្នុងលិខិតបណ្តាំដោយមានការយល់ព្រមពីម្ចាស់បណ្តាំនោះអាចឲ្យតតិយជនអនុវត្តកិច្ចការជំនួសបាន។ ការហាមឃាត់មិនឲ្យតតិយជនអនុវត្តកិច្ចការជំនួស ព្រោះថា មតកជនមានភាពជឿទុកចិត្តទៅលើសមត្ថភាព និងចំណេះដឹងរបស់អ្នកប្រតិបត្តិមតកសាសន៍តាមការជ្រើសតាំងបំពេញមុខងារ ព្រមទាំងផ្តល់សិទ្ធផ្តាច់មុខជាអ្នកតំណាងឲ្យខ្លួន។ ករណីឲ្យតតិយជនអនុវត្តកិច្ចការជំនួស អ្នកប្រតិបត្តិមតកសាសន៍ ត្រូវទទួលសិទ្ធិជ្រើសតាំង អ្នកប្រតិបត្តិមតកសាសន៍ថ្មី។ បើមានការអនុវត្តផ្ទុយពីខាងលើ ដោយឲ្យតតិយជនជាអ្នកអនុវត្តភារកិច្ចជំនួស ហើយគ្មានមូលហេតុច្បាស់លាស់ និងពុំមានការបង្ហាញឆន្ទៈរបស់ម្ចាស់បណ្តាំទុកជាមុន ឬមិនបានអនុវត្ត តាមនីតតិវិធីជ្រើសតាំងបន្ត អ្នកប្រតិបត្តិ

[78] មាត្រ ១២២៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

[79] មាត្រា ១២២៦ វាក្យខណ្ឌ២ កថាខណ្ឌទី២ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី រៀបចំដោយគណៈកម្មការទទួលបន្ទុកកាពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១៤។

[80] មាត្រ៦៤០ វាក្យខណ្ឌ២នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

មតកសាសន៍ត្រូវទទួលខុសត្រូវនៅពេលមានការខូចចខាត និងត្រូវសងសំណងនៃការខូចខាតទាំងនោះទៅឲ្យសន្តតិជន និងអច្ច័យលាភី។[81]

### ៥.២. ការលាឈប់ដោយខ្លួនឯង

អ្នកប្រតិបត្តិមតកសាសន៍ អាចលាឈប់ពីតួនាទីបានដោយមានមូលហេតុត្រឹមត្រូវ និងបង្ហាញពីភាពពិបាកក្នុងការអនុវត្តការងារជាអ្នកប្រតិបត្តិមតកសាសន៍។ មូលហេតុត្រឹមត្រូវ អាចលាឈប់បានមានដូចជា៖ មានជំងឺធ្ងន់ធ្ងរ មានភារកិច្ចជាចាំបាច់ណាមួយ នៅឆ្ងាយប្រើរយៈពេលវែងក្នុងការបំពេញមុខងារ ឬកាន់កាប់មុខងារថ្មីមានភាពមមាញឹកខ្លាំង អាចបង្កឲ្យមានការយឺតយ៉ាវដល់ដំណើរការអនុវត្តន៍មតកសាសន៍ជាដើម។ ដើម្បីធ្វើការលាឈប់ពីតួនាទីអ្នកប្រតិបត្តិមតកសាសន៍ ត្រូវដាក់ពាក្យសុំទៅតុលាការ បើតុលាការយល់ឃើញថាសមហេតុផល និងពិបាកក្នុងការបំពេញតួនាទីភារកិច្ចពិតប្រាកដមែន តុលាការនឹងអនុញ្ញាតឲ្យលាឈប់។[82] ឧទាហរណ៍ ក អ្នកប្រតិបត្តិមតកសាសន៍ ឲ្យគ្រួសារមួយនៅភ្នំពេញ ក្រោយមរណភាពរបស់ម្ចាស់បណ្តាំ ក ដែលជាអ្នកអនុវត្តតួនាទីនោះបានដាក់ពាក្យសុំបញ្ចប់មុខងារខ្លួន ដោយមូលហេតុថាខ្លួនមានជំងឺធ្ងន់ធ្ងរមិនអាចអនុវត្តការងារបាន ករណីនេះ តុលាការនឹងធ្វើការពិចារណា បើតុលាការយល់ឃើញថាសមរម្យ ឬការបង្ហាញឆន្ទៈរបស់ ក គ្មានវិការៈអ្វីទេ នោះតុលាការនិងចេញសាលក្រមអនុញ្ញាតិឲ្យលាឈប់។

### ៥.៣. ការបញ្ឈប់តួនាទីអ្នកប្រតិបត្តិមតកសាសន៍ដោយសន្តតិជន

សន្តតិជន ឬអច្ច័យលាភី មានសិទ្ធិក្នុងការដាក់ពាក្យសុំបញ្ចប់តួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍បាន កាលណាមានមូលហេតុត្រឹមត្រូវដូចជា៖ ភាពខ្ជិលច្រអូសក្នុងការបំពេញការងារ ការធ្វេសប្រហែសក្នុងការងារ ការបាត់ខ្លួនរយៈពេលវែង មានជំងឺរយៈពេលវែង ឬមានមូលហេតុសមរម្យផ្សេងទៀតដែលធ្វើខូចខាតដល់ផលប្រយោជន៍របស់សន្តតិជន ឬជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ នៃលិខិតមតកសាសន៍ជាដើម។ ជាក់ស្តែងបើរកឃើញថា អ្នកប្រតិបត្តិមតកសាសន៍នោះ គឺជាជនស្ថិតក្រោមការហាមឃាត់ មិនឲ្យក្លាយខ្លួនជាអ្នកប្រតិបត្តិមតកសាសន៍ នៅពេលនោះឋានៈ និងតួនាទីរបស់អ្នកប្រតិបត្តិ និងត្រូវបានបញ្ចប់ដោយស្វ័យប្រវត្តិ ហើយសន្តតិជន ឬជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ មិនចាំបាច់ដាក់ពាក្យសុំបញ្ឈប់តួនាទីរបស់អ្នកប្រតិបត្តិ

[81] មាត្រា១២២៤ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីរៀបចំដោយគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី បោះពុម្ពផ្សាយដោយ ក្រសួងយុត្តិធម៌ ឆ្នាំ២០១៤។

[82] មាត្រា១២២៧ វាក្យខ័ណ្ឌ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

មតកសាសន៍ទៅតុលាការទេ ផ្ទុយទៅវិញសន្តតិជន ឬជនពាក់ព័ន្ធនឹងផលប្រយោជន៍ អាចដាក់ពាក្យសុំទៅតុលាការ ដើម្បីជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ថ្មី។[83]

## ផ្នែកទី៣៖ ការលុបចោលនូវមតកសាសន៍

ម្ចាស់បណ្តាំមានសិទ្ធលុបចោលនូវលិខិតមតកសាសន៍មួយភាគឬ ទាំងមូល នៅពេលណាក៏បានមុនពេលខ្លួនទទួលមរណភាព។[84] ការលុបចោលនូវមតកសាសន៍មាន២(ពីរ) កថាកណ្ឌទី១. ការលុបចោលមតកសាសន៍តាមលិខិតមតកសាសន៍ និងកថាខណ្ឌទី២. ការលុបចោលលិខិតមតកសាសន៍តាមច្បាប់កំណត់។

### កថាខណ្ឌទី១៖ ការលុបចោលមតកសាសន៍តាមលិខិតមតកសាសន៍

ការលុបចោលនៅលិខិតមតកសាសន៍ ម្ចាស់បណ្តាំងអាចធ្វើតាមទម្រង់នៃលិខិតមតកសាសន៍បាន។ ការលុបចោលមតកសាសន៍អាចលុបមួយភាគ ឬទាំងមូល ចាប់ពីពេលដែលខ្លួនបានធ្វើមតកសាសន៍ទុករហូតមុនថ្ងៃទទួលមរណភាពរបស់ខ្លួន។[85] ជាមួយគ្នានេះដែល ដើម្បីលុបចោលមតកសាសន៍ដែលបានបង្កើតមុន គឺត្រូវបង្កើតមតកសាសន៍ថ្មី ហើយការបង្កើតមតកសាសន៍ថ្មីមានពីររបៀបគឺ៖ របៀបទី១ ធ្វើលិខិតមតកសាសន៍ថ្មីដោយបញ្ជាក់ច្បាស់អំពីការលុបចោលមតកសាសន៍មុន និងរបៀបទី២ ធ្វើលិខិតមតកសាសន៍ថ្មីដែលផ្ទុយនឹងមតកសាសន៍មុន មានន័យថា បើម្ចាស់បណ្តាំអាចធ្វើមតកសាសន៍ថ្មីហើយមានខ្លឹមសារផ្ទុយគ្នានឹងបណ្តាំមតកសាសន៍មុន នោះលិខិតបណ្តាំថ្មីនឹងត្រូវចាត់ទុកថាមានអានុភាពលុបចោលទៅលើ លិខិតមតកសាសន៍មុន។ ថ្វីត្បិតតែបណ្តាំមតកសាសន៍ធ្វើក្រោយនេះ មានអានុភាពលុបចោលបណ្តាំមតកសាសន៍ដែលបានធ្វើមុន ប៉ុន្តែករណីបើ លិខិតមតកសាសន៍បានធ្វើថ្មីមិនបានបញ្ជាក់ពី ថ្ងៃខែឆ្នាំឲ្យបានច្បាស់លាស់ទេ នោះក៏គ្មានអានុភាពលុបចោលបណ្តាំមតកសាសន៍មុនបានឡើយ។ មួយវិញទៀត ករណីលិខិតមតកសាសន៍មានច្រើនគ្មានថ្ងៃខែឆ្នាំ ហើយមានចំណុចផ្ទុយគ្នា នោះអានុភាពរបស់លិខិតបណ្តាំនឹងកាត់បន្ថយគ្នាទៅវិញទៅមក។ ហើយករណីលិខិតបណ្តាំមានច្រើនហើយខ្លឹមសារភាពស្របគ្នា ឬមានតែមួយ នោះលិខិតមតកសាសន៍នឹងមានអានុភាជាធម្មតា។[86]

[83] មាត្រា១២២៧ វាក្យខ័ណ្ឌ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

[84] មាត្រា១១៨៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

[85] មាត្រា១១៨៩ វាក្យខណ្ឌ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

[86] មាត្រា១១៧០ វាក្យខណ្ឌ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

ការលុបចោលតាមទម្រង់មតកសាសន៍បែបនេះ ទោះបីលិខិតមតកសាសន៍ធ្វើមុនជាទម្រង់លិខិតយថាភូត ឬទម្រង់ផ្សេងៗដែលច្បាប់បានកំណត់ ក៏ម្ចាស់បណ្តាំនៅតែមានសិទ្ធលុបចោលបានដែល ដោយបង្កើតលិខិតមតកសាសន៍ថ្មីជាទម្រង់លិខិតឯកជន។

ឧទាហរណ៍៖ បុគ្គល ក ជាម្ចាស់បណ្តាំបានធ្វើលិខិតបណ្តាំមួយទុកតាមទម្រង់យថាភូត ។ បន្ទាប់មក ក សម្រេចចិត្តលុបចោលលិខិតបណ្តាំនេះ ដោយធ្វើលិខិតបណ្តាំថ្មី បញ្ជាក់ថាលិខិតបណ្តាំបានធ្វើមុន បានលុបចោល ហើយលិខិតបណ្តាំបង្កើតថ្មីនឹងមានអានុភាព និងយកទៅ អនុវត្ត។ ឬបុគ្គល ក បានធ្វើលិខិតថ្មី មានភាពផ្ទុយគ្នាទៅ និងលិខិតបណ្តាំចាស់។ លិខិតបណ្តាំមុន ក បានសរសេរថា គ្រប់សម្បត្តិទាំងអស់ ត្រូវប្រគល់ឲ្យ ខ ដែលជាភរិយា។ ក្រោយមក ក ធ្វើលិខិតមតសាសន៍តាមទម្រង់ឯកជនថ្មីមួយទៀត ចែងថា ទ្រព្យសម្បត្តិរបស់គាត់ ត្រូវធ្វើការចែងចែកស្មើៗគ្នា រវាងសន្តតិជនទាំងអស់ ហើយបញ្ជាក់ថា រួមទាំងកូនចិញ្ចឹម ផងដែរ។ ដូចនេះ លិខិតបណ្តាំធ្វើមុន និងបាត់បង់អានុភាព តាមរយៈការធ្វើលិខិតបណ្តាំថ្មី មានលក្ខណៈផ្ទុយគ្នាទាំងស្រុង ទៅលើលិខិតបណ្តាំដែលបានធ្វើមុន។

**កថាខណ្ឌទី២៖ ការលុបចោលលិខិតមតកសាសន៍តាមការកំណត់នៃច្បាប់**

ការលុបចោលមតកសាសន៍តាមច្បាប់កំណត់នេះមា ៣ (បី)ចំណុចសម្រាប់សិក្សាដូចជា៖ ទី១. ម្ចាស់បណ្តាំចាត់ចែងពេលនៅរស់ ទី២. ការលុបចោលដោយការបដិសេធលិខិតមតកសាសន៍ និង៣. ការលុបចោលអច្ច័យទានជាប់បន្ទុក។

**១.ម្ចាស់បណ្តាំចាត់ចែងពេលនៅរស់**

ការលុបចោលលិខិតមតកសាសន៍ តាមការចាត់ចែងនៅពេលម្ចាស់បណ្តាំមានជីវិត គឺជាការធ្វើសកម្មភាពផ្ទុយគ្នាពីខ្លឹមសារនៃលិខិតបណ្តាំដោយម្ចាស់បណ្តាំបានធ្វើអនុប្បទាន ឬចាត់ចែងទៅលើវត្ថុដែលជាកម្មវត្ថុក្នុងលិខិតបណ្តាំ នៅពេលមានខ្លួនជីវិតទៅបុគ្គលណាម្នាក់ផ្សេងទៀត នោះត្រូវបានសន្មតថា មតកជនលុបចោល នៅលិខិតមតកសាសន៍មួយផ្នែកដែលជាកម្មវត្ថុអនុប្បទាន។[87]

ផ្ទុយទៅវិញ ករណីមានតតិយជនធ្វើឲ្យបាក់បែក ឬខូចខាតកម្មវត្ថុនៅនៃលិខិតបណ្តាំមិនអាចចាត់ទុកថាមានការលុបចោល ចំពោះផ្នែកដែលខូចខាតបានទេ។ សន្តតិជន ដែលជាអ្នកទទួលបានផ្នែកនៃការខូចខាតនោះមានសិទ្ធិទាមទារប្រាក់សំណងពីតតិយជនដែលធ្វើឲ្យការបែកបាក់ ឬខូចខាត ឬក្លែងបន្លំវត្ថុជាកម្មវត្ថុនៃបណ្តាំនោះ។ ដូចគ្នានេះដែល ករណីកម្មវត្ថុនោះបានធ្វើអច្ច័យទានសិទ្ធិក្នុងទាមទារត្រូវសន្មតថាក្លាយជាកម្មវត្ថុ

[87] មាត្រា១១៩០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

នៃអច្ច័យទាន[88] អច្ច័យលាភីដែលទទួលបានអច្ច័យទាននោះ ជាអ្នកមានសិទ្ធិទាមទារសំណងនៃការខូចខាតពីទង្វើរបស់តតិយជនទៅលើកម្មវត្ថុនៃអច្ច័យទាន។

ឧទាហរណ៍ ក បានធ្វើលិខិតបណ្តាំមួយ ទុកសម្រាប់បែងចែកទ្រព្យសម្បត្តិទៅឲ្យ សន្តតិជន បន្ទាប់ពីខ្លួនទទួលមរណភាព។ ក មានសន្តតិជនទាំងអស់ចំនួន៤( តាំង A B C D)នាក់ ហើយទ្រព្យសមបត្តិមាន៖ ផ្ទះ ២កន្លែង (១កន្លែងតម្លៃ១៧០០០០$ ដប់ប្រាំម៉ឺនដុល្លារ) ឡាន២គ្រឿង( លុចស៊ុស៥៧០ និងលុចស៊ុស៣៣០) និងហាងលក់ខោអាវ១កន្លែង នៅផ្សារទំនើប។ ក្នុងលិខិតបណ្តាំនោះ ចែងថា ផ្ទះ១កន្លែង ប្រគល់ឲ្យ A, ផ្ទះ ១កន្លែងទៀត ប្រគល់ឲ្យB, ឡាន១គ្រឿង Lexus570 ប្រគល់ឲ្យC, និងចុងក្រោយ ឡាន 330 ព្រមជាមួយហាងនៅផ្សារទំនើបប្រគល់ឲ្យD។ បន្ទាប់មក ម្ចាស់បណ្តាំ បានធ្វើអនុប្បទានឡាន ១គ្រឿងលុចស៊ុស៣៣០ ទៅឲ្យតតិយជន។ មានន័យថា លិខិតបណ្តាំ ដែលបានចែងថា ឡានលុចស៊ុស ៣៣០ ប្រគល់ឲ្យសន្តតិជន D ត្រូវបានលុបចោល ដោយសកម្មភាពផ្ទាល់របស់ម្ចាស់បណ្តាំ។ ប៉ុន្តែបើមានករណី ឡានជាកម្មវត្ថុនៃអានុប្បទាននេះ ត្រូវបានទទួលរងនៅការខូចខាតដោយទង្វើរបស់ជនណាម្នាក់ បន្ទាប់ពីមរណភាពរបស់ម្ចាស់បណ្តាំ សិទ្ធិទាមទារសំណង់ ត្រូវក្លាយជាកម្មវត្ថុជំនួស។

### ២ ការលុបចោលដោយការបដិសេធលិខិតមតកសាសន៍

កត្តានាំឲ្យមានការលុបចោល លិខិតមតកសាសន៍ដោយការបដិសេធមានពីរយ៉ាង៖ទី១. ម្ចាស់បណ្តាំបានបំផ្លាញច្បាប់ដើមនៃលិខិតមតកសាសន៍តាមវិធីដូចជា៖ ដុត ហែកចោល គូសចោលលើខ្លឹមសារដោយចេតនា នោះត្រង់ផ្នែកដែលបំផ្លាញ ត្រូវចាត់ទុកថាសាមីខ្លួនបានលុបចោល។ ទី២.ម្ចាស់បណ្តាំបានបំផ្លាញវត្ថុដែលជាកម្មវត្ថុនៃលិខិតមតកសាសន៍ដោយចេតនា។ លិខិតមតកសាសន៍ គឺភស្តុតាងតែមួយគត់ អាចបញ្ជាក់ពីការកើតមាននៃលិខិតមតកសាសន៍ ហើយជាភស្តុតាងនៃការបង្ហាញឆន្ទៈរបស់មតកជន ប្រសិនបើគ្មានលិខិតមតកសាសន៍ ឬកម្មវត្ថុក្នុងលិខិតមកតសាសន៍ត្រូវបានបំផ្លាញចោលដោយមតកជនផ្ទាល់ នោះចាត់ទុកថាសាមីខ្លួនបានបង្ហាញឆន្ទៈក្នុងការលុបចោលលិខិតមតកសាសន៍នោះ។[89]

តើការបំផ្លាញដោយតតិយជននូវលិខិតបណ្តាំ ឬកម្មវត្ថុនៃលិខិត មានអានុភាពដែលឬទេ? ហើយករណីបាត់បង់ដោយមូលហេតុប្រធានសក្តិ តើមានអានុភាពដែរឬទេ?

ករណីមានតតិយជនណាម្នាក់ ជាអ្នកបំផ្លាតបំផ្លាញលិខិតមតកសាសន៍ ឬមានហេតុការណ៍កើតមានប្រធានសក្តិដូចជា៖ មានទឹកជំនន់លិចលង់ មានរញ្ជួយដី នាំឲ្យលិខិតបណ្តាំមានការខូចខាត ឬកម្មវត្ថុនៃលិខិត

[88] មាត្រា១២០៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

[89] មាត្រា ១១៩១នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

បណ្ដាំត្រូវបានបាត់បង់ នោះអានុភាពនៃការលុបចោលមតកសាសន៍មិនអាចកើតឡើង។ ប៉ុន្តែករណីលិខិតមតកសាសន៍នោះមើលលែងកើតទាំងស្រុង ត្រូវចាត់ទុកថាគ្មានអានុភាពនៃលិខិតបណ្ដាំ ឬ ខូចខាតតែផ្នែកណាមួយនៃលិខិតបណ្ដាំ ផ្នែកដែលខូចខាតនិងបាត់បង់អានុភាព។[90]

**៣ ការលុបចោលអច្ច័យទានជាប់បន្ទុក**

ករណីបើអច្ច័យលាភី ពុំបានអនុវត្តកាតព្វកិច្ចដែលម្ចាស់បណ្ដាំបានកំណត់ សម្រាប់ជាថ្នូរប្ដូរជាមួយអច្ច័យទានទេនោះ អ្នកប្រតិបត្តិមតកសាសន៍អាចដាស់តឿនទៅអច្ច័យលាភី ដោយកំណត់ពេលណាមួយឲ្យសមរម្យក្នុងការអនុវត្តតាមលិខិតបណ្ដាំ។ ផ្ទុយទៅវិញ បើអច្ច័យលាភីនៅតែមិនអនុវត្ត ករណីកិច្ចក្នុងកំឡុងពេលដែលបានកំណត់នោះទេ អ្នកប្រតិបត្តិមតកសាសន៍អាចដាក់ពាក្យ សុំទាមទារឲ្យតុលាការលុបចោលនៅអច្ច័យទាននោះបាន ។[91] ជាឧទាហរណ៍៖ មតកជនឈ្មោះ ធី បានធ្វើអច្ច័ទានដោយប្រគល់ភាគហ៊ុនចំនួន ២០% ទៅឲ្យ Aដែលជាអ្នកជិតស្និតរបស់គាត់។ ក្នុងលិខិតបណ្ដាំបានចែងថា A និងទទួលបានភាគហ៊ុននេះ ករណីដែលA មកធ្វើការនៅក្នុងក្រុមហ៊ុនម្ចាស់បណ្ដាំ។ ដោយដល់ថ្ងៃកំណត់ A នៅតែមិនព្រមឆ្លើយតប និងមិនអានុវត្តតាមបំណងរបស់ធី ដែលជាម្ចាស់ ករណីនេះសន្តតិជន ឬអ្នកពាក់ព័ន្ធផលប្រយោជន អាចធ្វើការកំណត់ពេលមួយសមរម្យសម្រាប់អច្ច័លាភីនេះ ធ្វើការឆ្លើយតប និងអនុវត្តតាមការកំណត់។ ប្រសិនបើ អច្ច័យលាភីនៅតែមិនធ្វើការឆ្លើយតបហើយមិនអនុវត្តតាម សន្តតិជន ឬអ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ទាំងអស់អាចដាក់ពាក្យសុំធ្វើ ការទាមទារផ្ដាច់អច្ច័យទាន ទៅតុលាការ ដែលមានសមត្ថកិច្ចបាន។

[90] មាត្រា ១១៩១ វាក្យខណ្ឌទី៤ កថាខ័ណ្ឌទី២ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី រៀបចំដោយគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី បោះពុម្ពផ្សាយដោយ ក្រសួងយុត្តិធម៌ ឆ្នាំ២០១៤។

[91] មាត្រ១១៩៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីឆ្លងកាត់ការសិក្សាស្រាវជ្រាវ និងធ្វើការបកស្រាយចំពោះប្រធានបទស្តីពី «**ទម្រង់មតកសាសន៍**» បានបញ្ចប់ អាចធ្វើសេចក្តីសន្និដ្ឋានបានថា៖ ទម្រង់នៃលិខិតមតកសាសន៍ ជាលិខិតគតិយុត្តិម៉្យាងដែលអាចធ្វើពេលណាក៏បានមុនពេលដែលខ្លួនទទួលមរណភាព។ ក្នុងក្រមរដ្ឋប្បវេណី ចែងពីសិទ្ធិក្នុងការចាត់ចែងនៅទ្រព្យរបស់បុគ្គលម្នាក់ៗ និងអាចឲ្យម្ចាស់បណ្តាំបានបង្ហាញឆន្ទៈទៅលើទ្រព្យសម្បត្តិ ចង់ប្រគល់ឲ្យបុគ្គលណាដែលខ្លួនប្រាថ្នា។ ការធ្វើបណ្តាំគឺជាការល្អប្រសើរណាស់ ម្ចាស់បណ្តាំមានពេលវេលាគិតបានល្អិតល្អន់ក្នុងកំណត់ថាបុគ្គលណាគួរបានអ្វី និងទំហំប៉ុណ្ណានៃទ្រព្យរបស់ខ្លួន ហើយបានផ្តល់ឱកាសឲ្យមតកជនមើលឃើញពីគុណសម្បត្តិរបស់សន្តតិជន ការពេញចិត្ត និងការបែងចែកទ្រព្យបានត្រឹមត្រូវទៅលើអ្នកដែលត្រូវទទួលបានមត៌កនាអនាគត បញ្ចៀសការបារម្ភនៅពេលស្លាប់ទៅថា សន្តតិជនរបស់ខ្លួនមិនទទួលបានមត៌ក។ ក្រៅពីបែងចែកទ្រព្យទៅឲ្យសន្តតិជន ម្ចាស់បណ្តាំក៏អាចបង្ហាញឆន្ទៈឲ្យបុគ្គលណាម្នាក់ ជួយបំពេញបំណងណាមួយដូចជា៖ រៀបចំពិធីបុណ្យតាមបែបសាសនា បំពេញកិច្ចណាមួយតាមជាក្តីស្រម៉ៃរបស់ម្ចាស់បណ្តាំជាដើម។ សម្រាប់សន្តតិជន ឬអ្នកដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ត្រូវអនុវត្តតាមបំណងចុងក្រោយនៃខ្លឹមសារក្នុងលិខិតមតកសាសន៍នេះ។ ហើយការធ្វើលិខិតបណ្តាំទុកនេះផងដែរ ម្ចាស់បណ្តាំអាចប្រើប្រាស់ទ្រព្យសម្បត្តិដែលមានដោយបាត់បង់នូវកម្មសិទ្ធិនៅពេលខ្លួនមានជីវិត ខុសពីការផ្តល់ឲ្យភ្លាមៗ នាំឲ្យម្ចាស់ទ្រព្យបាត់បង់នូវកម្មសិទ្ធិ។

ការអនុវត្តលិខិតបណ្តាំនៅកម្ពុជា ឃើញថាពិតជាមានការស្មុគស្មាញ និងមិនសូវមានការពេញនិយមក្នុងការប្រើសប្រាស់ប្រព័ន្ធបែងចែកទ្រព្យបែបនេះទេ ជាហេតុនាំឲ្យងាយកើតមានវិវាទវារហូរហែ រវាងបងប្អូនឬជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ចំពោះការដណ្តើមទ្រព្យសម្បត្តិគ្នា បន្ទាប់ពីម្ចាស់បណ្តាំបានទទួលមរណភាព។ មួយវិញទៀតដើម្បីឲ្យលិខិតមតកសាសន៍អាចអនុវត្តទៅបាន ត្រូវឆ្លងកាត់នីតិវិធីត្រួតពិនិត្យរបស់តុលាការក្នុងការជួយដោះស្រាយ នាំឲ្យខាតបង់ពេលវេលា និងថវិការបស់សន្តតិជន។ នេះជាកត្តាមួយធ្វើនាំឲ្យម្ចាស់ទ្រព្យដែលមានតិចតួចមិនប្រើប្រាស់ លិខិតបណ្តាំក្នុងការបែងចែកទ្រព្យសម្បត្តិរបស់ខ្លួន។ ប្រទេសកម្ពុជាជាប្រទេសដែលកំពុងអភិវឌ្ឍ និងជួបបញ្ហាជាច្រើនទាក់ទងការអនុវត្តច្បាប់នានា ក៏ដូចជាការអនុវត្តបណ្តាំមតកសាសន៍ក៏ឃើញថានៅមានកម្រិតជាខ្លាំង។

បន្ទាប់ពីមតកជនបានទទួលមរណភាពឃើញមានការបែងចែកមត៌កតាមច្បាប់កំណត់ដែលមិនមែនជាឆន្ទៈផ្ទាល់របស់ម្ចាស់បណ្តាំ។ ប្រជាពលរដ្ឋភាគច្រើនមិនបានគិតដល់បញ្ហាដែលកើតមានដោយសារការបែងចែកទ្រព្យសម្បត្តិរបស់ខ្លួននាពេលអនាគត បន្ទាប់ពីមរណភាពរបស់មតកជន។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានសិក្សាស្រាវជ្រាវ ដោយការយកចិត្តទុកដាក់លើប្រធានបទស្តីពី «**ទម្រង់មតកសាសន៍**» រួចមក មានមតិយោបល់ខ្លះៗទាក់ទិននឹងការអនុវត្តទម្រង់មតកសាសន៍នៅប្រទេសកម្ពុជា។

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា គឺជាច្បាប់មួយដែលបានចងក្រងឡើង ដើម្បីអនុវត្ត និងជួយដោះស្រាយរាល់បញ្ហានានារបស់បុគ្គលក្នុងសង្គម ដោយមិនមែនគ្រាន់តែជាប្រយោគទុកក្នុងសៀវភៅនោះទេ។ ការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី «**ទម្រង់មតកសាសន៍**» នេះឡើងដោយមើលឃើញពីការអនុវត្តន៍នូវទម្រង់មតកសាសន៍នោះ នៅមានកម្រិតនៅឡើយ។

ភាពភាន់ច្រឡំទាក់ទងទៅនឹងទម្រង់មតកសាសន៍ ដោយនៅក្នុងទម្រង់លិខិតសម្ងាត់បានអនុញ្ញាតឲ្យតតិយជនធ្វើលិខិតមតកសាសន៍ឲ្យម្ចាស់បណ្តាំបាន ក្នុងករណីដែលម្ចាស់បណ្តាំមិនអាចធ្វើលិខិតបណ្តាំដោយខ្លួនឯងបាន។ នៅក្នុងវចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត បានឲ្យនិយមន័យ នៃពាក្យសម្ងាត់ មានន័យថា មិនលីមាត់ ឬ ឲ្យអ្នកដទៃដឹង។ ប៉ុន្តែលិខិតទម្រង់មតកសាសន៍សម្ងាត់ ម្ចាស់បណ្តាំត្រូវនិយាយនូវខ្លឹមសារនៃលិខិតដែលមតកសាសន៍បានប្រាប់ទៅតតិយជន ដើម្បីឲ្យបុគ្គលនោះសរសេរខ្លឹមសារនៃលិខិតមតកសាសន៍ជំនួយខ្លួន។ ជាមតិយោបល់ទម្រង់មតកសាសន៍នៃលិខិតសម្ងាត់ គួរតែមិនត្រូវអនុញ្ញាតឲ្យតតិយជនជួយសម្រួលក្នុងការសរសេរខ្លឹមសារនោះទេ។

លើសពីនេះ ការអនុវត្តន៍នូវទម្រង់នៃលិខិតមតកសាសន៍ពិតជាមានភាពស្មុកស្មាញ ធ្វើឲ្យប្រជាពលរដ្ឋប្រើប្រាស់ពេលវេលា និងថវិកាជាច្រើនហើយមានការយឺតយ៉ាវក្នុងការអនុវត្តន៍លិខិតបណ្តាំមកអនុវត្តហើយអាចធ្វើឲ្យមានការប៉ះពាល់ដល់ផលប្រយោជន៍របស់សន្តតិជន។ ក្រសួងយុត្តិធម៌នៅមិនទាន់មានការបែងចែកតុលាការក្នុងការដោះស្រាយរឿងក្តីឲ្យដាច់ពីគ្នានៅឡើយ ដោយឃើញថាតុលាការមានសមត្ថកិច្ច គ្របដណ្តប់គ្រប់រឿងក្តីទាំងអស់នៅក្នុងប្រទេស។

ជាសំណូមពរ ក្រសួងយយុត្តិធម៌គួរតែបង្កើតឲ្យមាន «**តុលាការគ្រួសារ**» មួយដែលមានសមត្ថកិច្ចដោយឡែក ដាច់ពីតុលាការបច្ចុប្បន្ន សម្រាប់ជួយដោះស្រាយវិវាទគ្រួសារ និងអាចជួយពន្លឿនដល់នីតិវិធីផ្សេងៗក៏ដូចជាការអនុវត្តលិខិតមតកសាសន៍ ហើយគួរតែផ្តល់សិទ្ធិឲ្យទៅសារការីក្នុងការអនុវត្តតួនាទីនេះកាន់តែច្រើនដោយមិនចាំបាច់កំណត់ពីទម្រង់មត៌តសាសន៍ណាមួយ។ ប្រជាពលរដ្ឋអាចមានសិទ្ធិក្នុងសម្រេចចិត្ត ជ្រើសរើសយកសមត្ថកិច្ចណាមួយសម្រាប់ធ្វើលិខិតបណ្តាំរបស់ខ្លួនតាមការជឿទុកចិត្ត ហើយជួយសម្រួលការងារដល់មមាញឹករបស់ក្រសួងយុត្តិធម៌ ប្រជាពលរដ្ឋមិនចាំបាច់ចំណាយពេលវេលាច្រើន សម្រាប់ការធ្វើលិខិតបណ្តាំ។

# ឯកសារយោង

# ឯកសារយោង

## ១. ក្រមច្បាប់

១.១. ច្បាប់ស្ដីពីការអនុវត្តន៍ក្រមរដ្ឋប្បវេណី ឆ្នាំ២០១១។

១.២. ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

## ២. ច្បាប់ដែលនិរាករណ៍

២.១ ក្រមរដ្ឋប្បវេណីចាស់, ឆ្នាំ១៩២០។

២.២. ច្បាប់ភូមិបាលចាស់, ថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩២។

## ៣. វចនានុក្រម

៣.១. វចនានុក្រមខ្មែរ សម្តេចជួន ណាត (ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ១៩១៥)។

៣.២. សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ អងគ្លេស បារាំង, រដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី បោះពុម្ពលើកទី១ ឆ្នាំ២០០៧ ។

## ៤. សៀវភៅដែលបានបោះពុម្ពផ្សាយ

៤.១. ទី ជីហួត.២០០៤. រឿងតេជោយ៉ត់. បោះពុម្ពលើកទី២ ភ្នំពេញ៖ ស្រី ប៊ុនជន។

៤.២. ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ សមិទ្ធផលគម្រោងអភិវឌ្ឍប្រព័ន្ធច្បាប់ និងតុលាការ ក្រសួងយុត្តិធម៌ បោះពុម្ពលើកទី១ ខែធ្នូ ឆ្នាំ២០១៥។

៤.៣. សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី រៀបចំដោយគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណីបោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ឆ្នាំ២០១៤។

៤.៤. នីតិរដ្ឋប្បវេណី គម្រោងបណ្តុះបណ្តាលអ្នកច្បាប់កម្ពុជា ឧបត្ថម្ភដោយអង្គការJICA សមិទ្ធិផលរបស់ក្រុមការងារសាលកវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំ២០១២ដល់២០១៧។

៤.៥. រុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត ២០១៧ នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ។

៤.៦. កម្រងមេរៀនវិភាគទានច្បាប់ ឆ្នាំ២០១៧ ក្រុមការងាររៀបចំ៖ ១.លោក ខៀវ សិន មេធាវីនិងជាសមាជិកវិភាគទានច្បាប់ ២.លោក ហ៊ឹម សែនណារិទ្ធ សិស្សក្រឡាបញ្ជីជំនាន់ទី៥ និងជាសមាជិកវិភាគទានច្បាប់ ៣.លោក លឹម ដុងលាង សិស្សក្រឡាបញ្ជីជំនាន់ទី៥ និងជាសមាជិកវិភាគទានច្បាប់ ៤.លោក តាំង សៀ

អៀង និស្សិតច្បាប់ឆ្នាំទី៤ និងជាសមាជិកវិភាគទានច្បាប់ ៥.លោក ចាន់ សិលា និស្សិតច្បាប់ឆ្នាំទី៤ និងជាសមាជិកវិភាគទានច្បាប់ ៦.លោក ថៃ ថេង និស្សិតច្បាប់ឆ្នាំទី៤ និងជាសមាជិកវិភាគទានច្បាប់ ៧. លោក សៀ សុខបាន និស្សិតច្បាប់ឆ្នាំទី៤ និងជាសមាជិកវិភាគទានច្បាប់ បោះពុម្ពដោយ វិភាគទានច្បាប់ រៀបរៀងនិងបោះពុម្ពដោយវិភាគទានច្បាប់។

៤.៧. ដោយលោក Tsuji Yasuhiko កម្រងករណីសិក្សាស្តីពី សន្តតិកម្ម និងមតកសាសន៍ ខែមករា ឆ្នាំ២០១៣។

៤.៨. រៀបចំដោយ៖ SHINODA YOICHIRO ឯកសារស្តីពីការធ្វើសន្តតិកម្មទី២ (សន្តតិកម្មតាមមតកសាសន៍) ចែករំលែកបន្តដោយ៖ បណ្ណសារ។

៤.៩. Ms. MIURA YASUKO សិក្ខាសាលាស្តីពី សន្តតិកម្ម ដោយសាស្ត្រាចារ្យនៃវិទ្យាស្ថានស្រាវជ្រាវ និងបណ្តុះបណ្តាលនៃក្រសួងយុត្តិធម៌។

## ៥. សារណាបញ្ចប់ការសិក្សា

៥.១. ក. មាស ចំណូល និងក. អេង ណៃស៊ីម. ២០១៩. អត្ថិភាព និងនត្ថិភាពនៃសន្តតិជន. សារណាបញ្ចប់ការសិក្សានៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

៥.២. ញាណ ចិត្រា និងក.ឌីណាល់ ស្រីម៉ុច.២០១៩. សន្តតិកម្មតាមមតកសាសន៍. សារណាបញ្ចប់ការសិក្សានៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

៥.២. ហ៊ីង គីមឡេង និងទេព សុខ. ២០១៥. មតកសាសន៍. សារណាបញ្ចប់ការសិក្សានៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

៥.៣. ម៉ៃ ចន្ទតារាវុធ និងហូ ឡេងហុង. ២០១៤. សន្តតិកម្មតាមមតកសាសន៍នៅកម្ពុជាបច្ចុប្បន្ន.សារណាបញ្ចប់ការសិក្សានៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

## ៦. គេហទំព័រតាមអ៊ីនធឺណេត

៦.១.មន្ទីរសារការីអង្គរ (ទីតាំង អគារលេខ១អេហ្វ ផ្លូវលេខ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ) ចំណុចដកស្រង់ចេញពី ផ្នែកសេវាកម្ម ចូលមើលថ្ងៃទី ៤ សីហា ឆ្នាំ២០២១ អាចរកបាននៅ http://angkornotary.com.kh/km/

៦.២. លោកគ្រូ អ៊ីង ប៉ូលី កម្មវិធីនាទីច្បាប់របស់BTV ប្រធានបទ៖ ការបែងចែកមតកសាសន៍តាមបណ្តាំ នៅឆ្នាំ២០១៦ ចូលទស្សនានៅថ្ងៃទី ៤ ខែ សីហា ឆ្នាំ ២០២១ អាចចូលមើលបាននៅ https://www.youtube.com/watch?v=YiFcJIOdaSw&list=PL48iwV2gkPae7-7_dWISt6Vr6rZ9LG5NM&index=5

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រមរដ្ឋប្បវេណី

ឆ្នាំ ២០០៧

ពិចារណាទៅលើពេល វិធី និង កម្រិតនៃវិភាគទាននោះ ចំនួនទឹកប្រាក់នៃមត៌ក និង ស្ថានភាពទាំងអស់ផ្សេងទៀត ។

៣-ភាគនៃវិភាគទាន មិនអាចឱ្យលើសពីចំនួនទឹកប្រាក់ដែលបានដកចេញនូវតម្លៃនៃអច្ច័យទាន និង តម្លៃនៃទ្រព្យសម្បត្តិ ដែលមតកជនបានកំណត់ថាជាចំណែកមត៌ករបស់សហសន្តតិជន ឬ ជាវិធីបែងចែកមត៌ក ពីចំនួនតម្លៃនៃមត៌ក ដែលមតកជនមាននៅពេលចាប់ផ្ដើមសន្តតិកម្មឡើយ ។

៤-ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ អាចធ្វើបានក្នុងករណីដែលមានពាក្យសុំ ដោយយោងតាមកថាខណ្ឌទី ១ នៃមាត្រា ១២៧០ (ការបែងចែកដោយតុលាការ) ឬ មានពាក្យបណ្ដឹង ដោយយោងតាមមាត្រា ១២៧៤ (ការទាមទាររបស់ជនដែលត្រូវបានទទួលស្គាល់ក្រោយការបែងចែកមត៌ក) ។

**មាត្រា ១១៦៧.–** ទំនាក់ទំនងជាមួយនឹងតតិយជន

ការសម្រួលចំណែកមត៌កដែលយោងតាមបញ្ញត្តិនៃផ្នែកទី ៣ (ការសម្រួលចំណែកមត៌ក) នេះ មិនអាចយកមកអះអាងនឹងតតិយជនបានឡើយ បើមិនមានល័ក្ខខ័ណ្ឌតាំងចំពោះលទ្ធផលនៃការបែងចែកមត៌ក ដោយផ្អែកលើការសម្រួលនោះទេ ។

## ជំពូកទី ៣

## សន្តតិកម្មតាមមតកសាសន៍

### ផ្នែកទី ១

### សមត្ថភាពក្នុងការធ្វើមតកសាសន៍

**មាត្រា ១១៦៨.–** បុគ្គលដែលអាចធ្វើមតកសាសន៍បាន

១-បុគ្គលដែលជានីតិជន និង អនីតិជនដែលបានអត្តាធីនភាពរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬ អំណាចមេបា អាចធ្វើមតកសាសន៍បាន ។

២-បញ្ញត្តិនៃមាត្រា ២៦ (សិទ្ធិលុបចោលសកម្មភាព) និង មាត្រា ៣០ (សិទ្ធិលុប

បោលសកម្មភាព) នៃក្រមនេះ មិនត្រូវយកមកអនុវត្តចំពោះមតកសាសន៍ឡើយ ។

**មាត្រា ១១៦៩.–** សមត្ថភាពនាពេលធ្វើមតកសាសន៍

១-ម្ចាស់បណ្តាំ ត្រូវមានសមត្ថភាព នៅពេលធ្វើមតកសាសន៍ ។

២-បុគ្គលដែលអះអាងអំពីការខ្វះសមត្ថភាពរបស់ម្ចាស់បណ្តាំ ត្រូវបញ្ជាក់ភស្តុតាងអំពីហេតុនោះ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបានកំណត់នៅក្នុងមាត្រា ១១៧៦ (មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

## ផ្នែកទី ២
## ទម្រង់នៃមតកសាសន៍

**មាត្រា ១១៧០.–** ភាពចាំបាច់នៃទម្រង់មតកសាសន៍

១-មតកសាសន៍ ពុំអាចធ្វើបានឡើយ បើពុំផ្អែកតាមទម្រង់ដែលបានកំណត់ក្នុងក្រមនេះទេ ។

២-មតកសាសន៍ដែលធ្វើមិនត្រូវនឹងទម្រង់ណាមួយក្នុងបញ្ញត្តិនៃក្រមនេះ ត្រូវចាត់ទុកជាមោឃៈ ។ ប៉ុន្តែ មតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ ត្រូវចាត់ទុកថាមានសុពលភាព លុះត្រាតែមតកសាសន៍នោះ មិនផ្ទុយនឹងមតកសាសន៍ផ្សេងទៀតដែលបានធ្វើដោយម្ចាស់បណ្តាំដូចគ្នានេះ ។ នៅក្នុងករណីដែលមតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ មានចំនួនច្រើន ហើយបើមតកសាសន៍ទាំងនេះ ផ្ទុយនឹងគ្នា អានុភាពនៃមតកសាសន៍ទាំងនោះត្រូវកាត់បន្ថយគ្នាទៅវិញទៅមក ។

**មាត្រា ១១៧១.–** សុពលភាពនៃទម្រង់

មតកសាសន៍ដែលត្រូវនឹងទម្រង់ណាមួយដែលបានកំណត់នៅក្នុងក្រមនេះ ត្រូវចាត់ទុកថាមានសុពលភាពចំពោះទម្រង់ ។

**មាត្រា ១១៧២.–** បុគ្គលដែលមិនអាចក្លាយជាសាក្សី ជាអាទិ៍

បុគ្គលដែលកំណត់ដូចខាងក្រោមនេះ មិនអាចធ្វើជាសាក្សី ឬ ជាអ្នកសង្កេតការណ៍នៅពេលធ្វើមតកសាសន៍បានឡើយ :

ក-អនីតិជន ឬ ជននៅក្រោមអាណាព្យាបាលធម្មតា ។

ខ-ជនដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី ហើយនិងសហព័ទ្ធ និង ញាតិលោហិតខ្សែផ្ទាល់ របស់ជនទាំងនោះ ។

គ-បើសារការីជាអ្នកពាក់ព័ន្ធក្នុងការធ្វើមតកសាសន៍ជាលិខិតយថាភូត ឬ ជាលិខិតមតកសាសន៍សម្ងាត់ សហព័ទ្ធរបស់សារការី ញាតិលោហិតខ្សែផ្ទាល់ ក្រឡាបញ្ជី និង និយោជិត របស់សារការីនោះ ។

**មាត្រា ១១៧៣.–** មតកសាសន៍ដោយលិខិតយថាភូត

១-មតកសាសន៍ដោយលិខិតយថាភូត ត្រូវធ្វើឡើងដោយម្ចាស់បណ្តាំ នៅចំពោះមុខសារការី តាមទម្រង់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងក្រោមនេះ ។

២-មតកសាសន៍ដោយលិខិតយថាភូត ត្រូវធ្វើឡើង ដោយយោងតាមទម្រង់ដូចខាងក្រោមនេះ :

ក-ត្រូវមានវត្តមានរបស់សាក្សីយ៉ាងតិច ២ (ពីរ) នាក់ ។

ខ-ម្ចាស់បណ្តាំត្រូវប្រាប់ផ្ទាល់មាត់ នូវខ្លឹមសារនៃមតកសាសន៍ ចំពោះសារការី ។

គ-សារការីត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំនោះ ជាលាយល័ក្ខណ៍អក្សរ ហើយត្រូវសូត្រឱ្យម្ចាស់បណ្តាំ និង សាក្សីនោះស្តាប់ ។

ឃ-បន្ទាប់ពីម្ចាស់បណ្តាំ និង សាក្សី បានទទួលស្គាល់ថាកំណត់ជាលាយល័ក្ខណ៍អក្សរនោះត្រឹមត្រូវហើយ ជននីមួយៗនោះត្រូវធ្វើឱ្យមានភាពច្បាស់លាស់នៅលើឯកសារអំពីឈ្មោះ អាយុ និង លំនៅឋាន ហើយ ត្រូវចុះហត្ថលេខា រៀងៗខ្លួន ។ ប៉ុន្តែបើម្ចាស់បណ្តាំ មិនអាចសរសេរអក្សរ ឬ មិនអាចចុះហត្ថលេខាបានទេ សារការីអាចជំនួសការសរសេរ និង ហត្ថលេខាដូចកំណត់ខាងលើនេះ ដោយសរសេរឈ្មោះ អាយុ និង លំនៅឋានរបស់ជននោះ ហើយត្រូវសរសេរបន្ថែមនូវហេតុនោះផង ។

ង-សារការីត្រូវសរសេរថ្ងៃខែឆ្នាំ ហើយត្រូវចុះហត្ថលេខា ។

**មាត្រា ១១៧៤.–** មតកសាសន៍ដោយលិខិតឯកជន

១-មតកសាសន៍ដោយលិខិតឯកជន ត្រូវធ្វើឡើង ដោយម្ចាស់បណ្ដាំសរសេរពាក្យទាំងអស់ និង ចុះថ្ងៃខែឆ្នាំ ដោយខ្លួនឯង ហើយត្រូវចុះហត្ថលេខាលើលិខិតនោះ ។ មតកសាសន៍ដោយលិខិតឯកជនដែលត្រូវបានសរសេរជំនួសដោយអ្នកដទៃ ឬ ដែលត្រូវបានសរសេរដោយប្រើម៉ាស៊ីនដូចជាអង្គុលីលេខ ជាអាទិ៍ នឹងត្រូវចាត់ទុកជាមោឃៈ ។

២-ការបន្ថែម ការលុប ឬ ការកែប្រែផ្សេងទៀត នៅក្នុងមតកសាសន៍ដោយលិខិតឯកជន ពុំមានអានុភាពឡើយ បើម្ចាស់បណ្ដាំមិនបានបង្ហាញនូវកន្លែង ហើយសរសេរបន្ថែមនូវហេតុនៃការកែប្រែនោះ ជាពិសេសបើមិនបានចុះហត្ថលេខាទេ ។

**មាត្រា ១១៧៥.–** មតកសាសន៍ដោយលិខិតសម្ងាត់

មតកសាសន៍ដោយលិខិតសម្ងាត់ ត្រូវធ្វើឡើង ដោយយោងតាមទម្រង់ដូចខាងក្រោមនេះ :

ក-ម្ចាស់បណ្ដាំត្រូវចុះហត្ថលេខាលើលិខិតនោះ ។

ខ-ម្ចាស់បណ្ដាំត្រូវដាក់លិខិតនោះក្នុងស្រោមបិទជិត ហើយត្រូវចុះហត្ថលេខា ឬ សរសេរសញ្ញាសំគាល់ ឬ មធ្យោបាយផ្សេងទៀតដែលអាចវិនិច្ឆ័យបានអំពីការបានបើក ឬ មិនបានបើកស្រោមលិខិតនោះ នៅមាត់ស្រោមលិខិតនោះ ។

គ-ម្ចាស់បណ្ដាំត្រូវដាក់លិខិតដែលបានបិទជិតនោះ នៅចំពោះមុខសារការីម្នាក់ និង សាក្សី ២ (ពីរ) នាក់ និង ធ្វើសេចក្ដីថ្លែងការណ៍ថា លិខិតនេះជាលិខិតមតកសាសន៍របស់ខ្លួន ហើយបើមានជនក្រៅពីសាមីខ្លួនបានសរសេរ ត្រូវធ្វើសេចក្ដីថ្លែងការណ៍អំពីឈ្មោះ និង លំនៅឋានរបស់ជនដែលបានសរសេរនោះ ។

ឃ-សារការីត្រូវចុះថ្ងៃខែឆ្នាំដែលសាមីខ្លួនបានដាក់លិខិតនោះ និង សរសេរសេចក្ដីថ្លែងការណ៍របស់ម្ចាស់បណ្ដាំ នៅលើលិខិតដែលបិទជិតនោះ ហើយត្រូវចុះហត្ថលេខាលើលិខិតនោះ ជាមួយគ្នានឹងសាក្សី និង ម្ចាស់បណ្ដាំ ។

**មាត្រា ១១៧៦.–** មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ

១-ដើម្បីធ្វើមតកសាសន៍ នៅពេលដែលជននៅក្រោមអាណាព្យាបាលទូទៅ បាន សះស្បើយមួយរយៈឡើងវិញ នូវសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាម ផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ត្រូវមានវត្តមានរបស់វេជ្ជបណ្ឌិត យ៉ាងតិច ២ (ពីរ) នាក់ ។

២-វេជ្ជបណ្ឌិតដែលមានវត្តមាននៅពេលធ្វើមតកសាសន៍ ត្រូវសរសេរបញ្ជាក់បន្ថែម លើលិខិតមតកសាសន៍នោះថា នៅពេលដែលម្ចាស់បណ្ដាំបានធ្វើមតកសាសន៍នោះ ម្ចាស់ បណ្ដាំពុំបានស្ថិតក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផល តាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិស្មារតីទេ ហើយត្រូវចុះហត្ថលេខា ដោយបញ្ជាក់ថា ខ្លួនជាវេជ្ជបណ្ឌិតផងដែរ ។

**មាត្រា ១១៧៧.–** មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់ អាយុជីវិត

១-ប្រសិនបើជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ដោយសារ ជម្ងឺ ឬ ហេតុផ្សេងទៀត មានបំណងចង់ធ្វើមតកសាសន៍ មតកសាសន៍នេះអាចធ្វើបាន ដោយតម្រូវឱ្យមានវត្តមានរបស់សាក្សីយ៉ាងតិច ៣ (បី) នាក់ ហើយដោយប្រកាស ខ្លឹមសារនៃមតកសាសន៍នោះ ដោយផ្ទាល់មាត់ ចំពោះជនម្នាក់ ក្នុងចំណោមសាក្សីនោះ ។ នៅក្នុងករណីនេះ ជនដែលបានទទួលការប្រកាសដោយផ្ទាល់មាត់នោះ ត្រូវសរសេរជា លាយល័ក្ខណ៍អក្សរ ហើយអានឱ្យសាក្សីស្ដាប់ ឬ ឱ្យមើល ហើយនៅក្រោយពេលដែល សាក្សីនីមួយៗបានទទួលស្គាល់ថាការសរសេរនោះត្រឹមត្រូវហើយ សាក្សីនីមួយៗនោះ ត្រូវ ចុះហត្ថលេខាលើលិខិតនោះ ។

២-មតកសាសន៍ដែលបានធ្វើតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំមាន អានុភាពឡើយ បើសាក្សីណាម្នាក់ ឬ បុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ពុំបានដាក់ ពាក្យសុំទៅតុលាការ នៅក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានធ្វើ មតកសាសន៍នោះ ហើយពុំបានទទួលការបញ្ជាក់ទេ ។

៣-តុលាការមិនអាចធ្វើការបញ្ជាក់មតកសាសន៍បានឡើយ ប្រសិនបើពុំមានជំនឿ

ទុកចិត្តថាមតកសាសន៍នោះ ចេញពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំ ។

**មាត្រា ១១៧៨.–** មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង ជាអាទិ៍

១-បុគ្គលដែលជាប់ឃុំឃាំងនៅទីកន្លែងដាច់ដោយឡែក ដោយសាលក្រម ឬ សាលដីកា ឬ ដោយសារការចាត់ចែងផ្នែករដ្ឋបាល អាចធ្វើលិខិតមតកសាសន៍បាន ដោយត្រូវឱ្យមានវត្តមានរបស់នគរបាល ឬ មន្ត្រីនៃមន្ទីរឃុំឃាំងម្នាក់ និង សាក្សី យ៉ាងតិច ២ (ពីរ) នាក់ ។

២-បុគ្គលដែលនៅក្នុងនាវា ឬ យន្តហោះ អាចធ្វើលិខិតមតកសាសន៍បាន ដោយត្រូវឱ្យមានវត្តមានមេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះម្នាក់ និង សាក្សីយ៉ាងតិច ២ (ពីរ) នាក់ ។

៣-នៅពេលធ្វើមតកសាសន៍ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ ម្ចាស់បណ្តាំអាចធ្វើមតកសាសន៍ ដោយផ្ទាល់មាត់ ចំពោះនគរបាល មន្ត្រីនៃមន្ទីរឃុំឃាំង មេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះបាន ។

៤-បញ្ញត្តិពីចំណុច ខ ដល់ចំណុច ង កថាខណ្ឌទី ២ នៃមាត្រា ១១៧៣ (មតក-សាសន៍ដោយលិខិតយថាភូត) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ។ ក្នុងករណីនេះ ពាក្យ សារការីត្រូវបានបកស្រាយថាជា នគរបាល មន្ត្រីនៃមន្ទីរឃុំឃាំង មេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះ ។

៥-មតកសាសន៍ដែលត្រូវបានធ្វើឡើង ដោយយោងតាមបញ្ញត្តិពីកថាខណ្ឌទី ១ ដល់កថាខណ្ឌទី ៤ ខាងលើនេះ ពុំមានអានុភាពឡើយ បើម្ចាស់បណ្តាំបន្តនៅរស់ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីពេលដែលម្ចាស់បណ្តាំនោះ បែរជាអាចធ្វើមតកសាសន៍បាន តាមទម្រង់ណាមួយដែលបានកំណត់ចាប់ពីមាត្រា ១១៧៣ (មតកសាសន៍ដោយលិខិតយថាភូត) ដល់មាត្រា ១១៧៥ (មតកសាសន៍ដោយលិខិតសម្ងាត់) នៃក្រមនេះ ក្រោយពេលខ្លួនត្រូវបានដោះលែងពីមន្ទីរឃុំឃាំង ឬ ចុះពីនាវា ឬ យន្តហោះ ។

**មាត្រា ១១៧៩.–** ការធ្វើមតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបាន ជាអាទិ៍

១-នៅក្នុងករណីដែលបុគ្គលមិនអាចនិយាយបាន ធ្វើមតកសាសន៍តាមទម្រង់ដែលបានកំណត់នៅក្នុងមាត្រា ១១៧៣ (មតកសាសន៍ដោយលិខិតយថាភូត) មាត្រា ១១៧៥ (មតកសាសន៍ដោយលិខិតសម្ងាត់) មាត្រា ១១៧៧ (មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត) នៃក្រមនេះ ម្ចាស់បណ្តាំនោះអាចជំនួសការប្រាប់បាន ដោយធ្វើសេចក្តីថ្លែងការណ៍អំពីខ្លឹមសារនៃមតកសាសន៍ ឬ សេចក្តីថ្លែងការណ៍ថាលិខិតនោះជាលិខិតមតកសាសន៍ តាមការបកប្រែរបស់អ្នកបកប្រែ ឬ សរសេរដោយដៃខ្លួនផ្ទាល់ នៅចំពោះមុខសារការី ឬ សាក្សី ។

២-ក្នុងករណីដែលសារការី ឬ បុគ្គលផ្សេងទៀតដែលបានកំណត់នៅក្នុងក្រមនេះ ត្រូវអានឱ្យម្ចាស់បណ្តាំ ឬ សាក្សី ស្តាប់នូវអត្ថន័យនៃមតកសាសន៍ ក្រោយពេលបានសរសេរជាលាយលក្ខណ៍អក្សរនូវខ្លឹមសារនៃមតកសាសន៍នោះ បើម្ចាស់បណ្តាំ និង សាក្សីនោះ បែរជាមនុស្សថ្លង់មិនអាចស្តាប់បានទេ សារការី ឬ បុគ្គលផ្សេងទៀតដែលត្រូវបានកំណត់នៅក្នុងក្រមនេះ អាចជំនួសការអានឱ្យស្តាប់បាន ដោយប្រាប់អំពីអត្ថន័យដែលខ្លួនបានសរសេរនោះ តាមការបកប្រែរបស់អ្នកបកប្រែ ទៅម្ចាស់បណ្តាំ ឬ សាក្សីនោះ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ សារការី ឬ បុគ្គលផ្សេងទៀតដែលបានកំណត់នៅក្នុងក្រមនេះ ត្រូវសរសេរអំពីហេតុនោះចូលទៅក្នុងលិខិតនោះ ។

**មាត្រា ១១៨០.–** ការសរសេរនាមត្រកូល និង នាមខ្លួន និង ការផ្តិតស្រាមដៃ ជំនួសឱ្យការចុះហត្ថលេខា

ក្នុងករណីដែលសារការី និង សាក្សី ត្រូវចុះហត្ថលេខា សារការី និង សាក្សីគ្រាន់តែសរសេរនាមត្រកូល និង នាមខ្លួន និង ផ្តិតស្រាមដៃ ជាការគ្រប់គ្រាន់ហើយ ។

**មាត្រា ១១៨១.–** បទប្បញ្ញត្តិពិសេសចំពោះមតកសាសន៍របស់ជនជាតិខ្មែរដែលរស់នៅបរទេស

បើជនជាតិខ្មែរមានបំណងចង់ធ្វើមតកសាសន៍ដោយលិខិតយថាភូត ឬ លិខិត

សម្ងាត់ នៅកន្លែងដែលមានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅ កុងស៊ុលនោះត្រូវអនុវត្តមុខនាទីរបស់សារការី ។

## ផ្នែកទី ៣
## ចំណុចនៃមតកសាសន៍

**មាត្រា ១១៨២.–** ការកំណត់ចំណែកមត៌ក

១-មតកជនអាចកំណត់ចំណែកមត៌ករបស់សហសន្តតិជនតាមមតកសាសន៍ ឬ អាចបង្ហាញឆន្ទៈផ្ទុយពីបញ្ញត្តិនៃមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) នៃក្រមនេះ ស្ដីពីចំណែកមត៌ករបស់បុគ្គលដែលបានទទួលផលប្រយោជន៍ពិសេសបាន ។ ប៉ុន្តែ ការកំណត់ចំណែកមត៌កដែលបំពានភាគបម្រុង ត្រូវអនុលោមតាមបញ្ញត្តិស្ដីពីភាគបម្រុង ។

២-បើមតកជនបានកំណត់ចំណែកមត៌ក ចំពោះសន្តតិជនតែម្នាក់ ឬ ច្រើននាក់ក្នុងចំណោមសហសន្តតិជនទាំងអស់ ចំណែកមត៌ករបស់សហសន្តតិជនផ្សេងទៀត ត្រូវកំណត់ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ៣ (ការសម្រួលចំណែកមត៌ក) ជំពូកទី ២ ។

**មាត្រា ១១៨៣.–** ការកំណត់នូវវិធីបែងចែកដោយមតកសាសន៍ ជាអាទិ៍

មតកជន អាចកំណត់នូវវិធីបែងចែកតាមមតកសាសន៍ ឬ អាចប្រគល់អាណត្តិឱ្យតតិយជនកំណត់វិធីនោះ ឬ អាចហាមឃាត់មិនឱ្យបែងចែកនៅក្នុងអំឡុងពេលដែលមិនលើសពី ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលចាប់ផ្ដើមសន្តតិកម្មនោះ បាន ។

**មាត្រា ១១៨៤.–** អនុប្បទានទ្រព្យសម្បត្តិ

ម្ចាស់បណ្ដាំអាចធ្វើប្រទានកម្មនូវទ្រព្យសម្បត្តិទាំងអស់ ឬ មួយផ្នែក ឬ អាចធ្វើប្រទានកម្មដោយមតកសាសន៍ តាមវិធីដែលបានកំណត់នៅក្នុងមាត្រា ១១៩៩ (និយមន័យនៃអច្ច័យទាន) នៃក្រមនេះបាន នៅក្នុងល័ក្ខខ័ណ្ឌដែលអនុលោមតាមបញ្ញត្តិស្ដីពីភាគបម្រុង ។

**មាត្រា ១១៨៥.–** អនុប្បទានទ្រព្យសម្បត្តិចំពោះសន្តតិជន

១-បើមតកជនបានធ្វើមតកសាសន៍ដែលមានអត្ថន័យជាការធ្វើអនុប្បទានទ្រព្យសម្បត្តិជាក់លាក់តែមួយ ឬ ច្រើន ឱ្យទៅសហសន្តតិជនតែម្នាក់ ឬ ច្រើននាក់ មតកសាសន៍នោះត្រូវបានសន្មតថាបានកំណត់នូវវិធីបែងចែកមត៌ក លើកលែងតែនៅក្នុងករណីដែលមតកសាសន៍នោះមានអត្ថន័យជាអច្ច័យទានយ៉ាងច្បាស់លាស់ ដូចជាអច្ច័យទានដែលភ្ជាប់ជាមួយនឹងបន្ទុក ជាអាទិ៍ ហើយបើតម្លៃនៃទ្រព្យសម្បត្តិដែលបានកំណត់នោះ មានចំនួនលើសពីចំណែកមត៌ករបស់សន្តតិជន នោះត្រូវសន្មតថាបានកំណត់ចំណែកមត៌កផងដែរ ។

២-ក្នុងករណីដែលមតកជនបានធ្វើមតកសាសន៍ ចំពោះទ្រព្យសម្បត្តិតែមួយភាគនៅក្នុងចំណោមមត៌ក បើតម្លៃនៃទ្រព្យសម្បត្តិនោះ មានចំនួនតិចជាងចំណែកមត៌ក ដែលសន្តតិជននោះត្រូវទទួល លុះត្រាតែពុំមានការបង្ហាញឆន្ទៈផ្សេងទៀតនៅក្នុងមតកសាសន៍នោះ ត្រូវសន្មតថាបានកំណត់ត្រឹមតែវិធីបែងចែកមត៌កដែលត្រូវធ្លាក់ទៅលើសន្តតិជននោះតែប៉ុណ្ណោះ ។

**មាត្រា ១១៨៦.–** ការកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍

ម្ចាស់បណ្ដាំអាចកំណត់អ្នកប្រតិបត្តិមតកសាសន៍ម្នាក់ ឬ ច្រើននាក់ ឬ អាចប្រគល់អាណត្តិឱ្យតតិយជនកំណត់អ្នកប្រតិបត្តិនោះ តាមមតកសាសន៍បាន ។

**មាត្រា ១១៨៧.–** ចំណុចផ្សេងៗ

ក្រៅពីធ្វើមតកសាសន៍តាមចំណុចដែលបានកំណត់នៅក្នុងក្រមនេះ ម្ចាស់បណ្ដាំអាចធ្វើមតកសាសន៍ដោយផ្ដល់ដំបូន្មាន ឬ យោបល់ ដើម្បីឱ្យមានភាពសុខដុមរមនាដល់ក្រុមគ្រួសារ និង ចំណុចផ្សេងៗទៀតបាន ។ នៅក្នុងករណីនេះ សន្តតិជន ជាអាទិ៍ ត្រូវគោរពទៅតាមមតកសាសន៍នោះ ។

## ផ្នែកទី ៤
## ការលុបចោលនូវមតកសាសន៍

**មាត្រា ១១៨៨.–** ពេល និង ទម្រង់នៃការលុបចោលនូវមតកសាសន៍

ម្ចាស់បណ្តាំអាចលុបចោលនូវមតកសាសន៍ មួយភាគ ឬ ទាំងមូល នៅពេលណាក៏បាន ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ៤ (ការលុបចោលនូវមតកសាសន៍) នេះ ។

**មាត្រា ១១៨៩.–** ការលុបចោលដោយទម្រង់នៃមតកសាសន៍

១-ម្ចាស់បណ្តាំអាចលុបចោលនូវមតកសាសន៍ មួយភាគ ឬ ទាំងមូលបាន តាមទម្រង់នៃមតកសាសន៍ ។

២-បើមតកសាសន៍ដែលបានធ្វើក្រោយនេះ មានភាពផ្ទុយនឹងមតកសាសន៍ដែលបានធ្វើមុន ត្រូវចាត់ទុកថា មតកសាសន៍ដែលបានធ្វើក្រោយនោះ បានលុបចោលមតកសាសន៍ដែលបានធ្វើមុន ចំពោះផ្នែកដែលផ្ទុយគ្នានោះ ។

**មាត្រា ១១៩០.–** ការលុបចោលមតកសាសន៍ ដោយការចាត់ចែងនាពេលនៅរស់

បើម្ចាស់បណ្តាំបានធ្វើអនុប្បទាន ឬ បានធ្វើសកម្មភាពផ្សេងទៀត ចំពោះវត្ថុដែលជាកម្មវត្ថុនៃមតកសាសន៍ នាពេលនៅរស់ ត្រូវចាត់ទុកថា ម្ចាស់បណ្តាំបានលុបចោលមតកសាសន៍ ចំពោះផ្នែកដែលផ្ទុយនឹងអនុប្បទាន ឬ សកម្មភាពផ្សេងនោះ ។

**មាត្រា ១១៩១.–** ការលុបចោលដោយការបដិសេធលិខិតមតកសាសន៍ ជាអាទិ៍

បើម្ចាស់បណ្តាំបានបំផ្លាញច្បាប់ដើមនៃមតកសាសន៍ ដោយចេតនា ត្រូវចាត់ទុកថាបានលុបចោលមតកសាសន៍ ចំពោះផ្នែកដែលត្រូវបានបំផ្លាញនោះ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលម្ចាស់បណ្តាំបានបំផ្លាញវត្ថុ ដែលជាកម្មវត្ថុនៃមតកសាសន៍ ដោយចេតនា ។

**មាត្រា ១១៩២.–** ការបោះបង់សិទ្ធិលុបចោលមតកសាសន៍

ម្ចាស់បណ្តាំមិនអាចបោះបង់សិទ្ធិលុបចោលមតកសាសន៍ បានឡើយ ។

**មាត្រា ១១៩៣.–** ការលុបចោលអច្ច័យទានដែលភ្ជាប់បន្ទុក

បើអច្ច័យលាភីពុំបានអនុវត្តករណីយកិច្ចដែលម្ចាស់បណ្តាំបានតម្រូវឱ្យអច្ច័យលាភីនោះទទួលបន្ទុកជាថ្នូរនឹងអច្ច័យទានទេ អ្នកប្រតិបត្តិមតកសាសន៍ ឬ បើគ្មានអ្នកប្រតិបត្តិមតកសាសន៍នោះទេ សន្តតិជនអាចដាស់តឿនឱ្យអច្ច័យលាភីនោះ អនុវត្តករណីយកិច្ចនោះ ដោយកំណត់អំឡុងពេលសមរម្យ ហើយប្រសិនបើអច្ច័យលាភីនោះ មិនបានអនុវត្តករណីយកិច្ច នៅក្នុងអំឡុងពេលនោះទេ អ្នកប្រតិបត្តិមតកសាសន៍ ឬ សន្តតិជននោះអាចទាមទារទៅតុលាការ ឱ្យលុបចោលអច្ច័យទាននោះបាន ។

## ផ្នែកទី ៥
## អានុភាពនៃមតកសាសន៍

**មាត្រា ១១៩៤.–** ពេលដែលមតកសាសន៍បង្កើតអានុភាព

១-មតកសាសន៍ ត្រូវបង្កើតអានុភាព ចាប់ពីពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ។

២-នៅក្នុងករណីដែលមតកសាសន៍ ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ បើល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញនៅក្រោយពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព មតកសាសន៍នោះ ត្រូវមានអានុភាព ចាប់ពីពេលដែលល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញ ។

**មាត្រា ១១៩៥.–** អានុភាពនៃការកំណត់ចំណែកមត៌ក ជាអាទិ៍

១-បើមតកជនបានកំណត់ចំណែកមត៌ក ឬវិធីបែងចែកមត៌ក ដោយធ្វើអនុប្បទានទ្រព្យសម្បត្តិជាក់លាក់តែមួយ ឬ ច្រើន ឱ្យចំពោះសន្តតិជនតែម្នាក់ ឬ ច្រើននាក់ ដោយមតកសាសន៍ ទ្រព្យសម្បត្តិជាក់លាក់នោះ ត្រូវធ្លាក់ទៅសន្តតិជនដែលនឹងត្រូវទទួលទ្រព្យសម្បត្តិនោះ ដោយស្វ័យប្រវត្តិ ព្រមគ្នានឹងពេលមតកសាសន៍នោះបង្កើតអានុភាព ។

២-នៅក្នុងករណីដែលមតកសាសន៍ ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ បើល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញនៅក្រោយពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចាត់ទុកថា ត្រូវបានធ្លាក់ទៅ

សន្តតិជនដែលនឹងត្រូវទទួលទ្រព្យសម្បត្តិនោះ ដោយប្រតិសកម្ម គិតចាប់តាំងពីពេលដែលមតកជននោះ បានទទួលមរណភាព ។

**មាត្រា ១១៩៦.–** មរណភាពនៃជនដែលត្រូវបានសន្មតថាជាសន្តតិជន ជាអាទិ៍

១-នៅក្នុងករណីដែលមតកជនបានកំណត់ចំណែកមតិករបស់សន្តតិជន ឬ វិធីនៃការបែងចែកមតិក ដោយមតកសាសន៍ បើជនដែលត្រូវបានសន្មតថាជាសន្តតិជន បានទទួលមរណភាព នៅមុនពេលចាប់ផ្ដើមសន្តតិកម្ម ឬ បានបាត់បង់សិទ្ធិសន្តតិកម្ម ដោយត្រូវនឹងបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) នៃក្រមនេះ ឬ ដោយការកាត់កាល់សន្តតិជន ការកំណត់នោះត្រូវបានចាត់ទុកថា បានធ្វើចំពោះអ្នកទទួលសន្តតិកម្មជំនួសរបស់ជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើគ្មានអ្នកទទួលសន្តតិកម្មជំនួសជនដែលត្រូវបានសន្មតថាជាសន្តតិជននោះទេ ការកំណត់ចំពោះជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ ពុំត្រូវបង្កើតអានុភាពឡើយ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសន្តតិជនបានបោះបង់សន្តតិកម្ម ។

៣-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះក៏ដោយ បើមតកជនបានបង្ហាញឆន្ទៈផ្សេង ក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

**មាត្រា ១១៩៧.–** ការកម្រិតនូវមតកសាសន៍ ចំពោះអ្នកអាណាព្យាបាល ជាអាទិ៍

១-បើជនដែលនៅក្រោមអាណាព្យាបាលទូទៅ បានធ្វើមតកសាសន៍ ដែលជាផលប្រយោជន៍ដល់អ្នកអាណាព្យាបាល ឬ សហព័ទ្ធ ឬ បច្ឆាញាតិផ្ទាល់របស់អ្នកអាណាព្យាបាលនោះ នៅមុនពេលបញ្ចប់ការគណនានូវចំណូលចំណាយក្នុងកិច្ចការអាណាព្យាបាល មតក-សាសន៍នោះត្រូវចាត់ទុកជាមោឃៈ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលញាតិលោហិតផ្ទាល់ សហព័ទ្ធ ឬ បងប្អូនបង្កើត ជាអ្នកអាណាព្យាបាលទូទៅ ។

**មាត្រា ១១៩៨.–** សិទ្ធិទទួលទ្រព្យសម្បត្តិ ក្នុងករណីដែលអច្ច័យទានមោឃៈ ជាអាទិ៍

បើអច្ច័យទានពុំបានបង្កើតអានុភាព ដោយសារអច្ច័យលាភីជាអភ័ព្វបុគ្គល ឬ ទទួលមរណភាព ឬ ដោយសារហេតុផ្សេងទៀត ឬ បើពុំបានបង្កើតអានុភាពដោយសារការបោះបង់ ទ្រព្យដែលអច្ច័យលាភីត្រូវទទួលនោះ ត្រូវធ្លាក់ទៅសន្តតិជនរបស់មតកជន ។ ប៉ុន្តែ បើម្ចាស់បណ្ដាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

## ផ្នែកទី ៦
## អច្ច័យទាន

**មាត្រា ១១៩៩.–** និយមន័យនៃអច្ច័យទាន

អច្ច័យទានសកល គឺជាប្រទានកម្មដែលម្ចាស់បណ្ដាំធ្វើទៅឱ្យមនុស្សម្នាក់ ឬ ច្រើននាក់ នូវទ្រព្យសម្បត្តិទាំងអស់ ឬ មួយផ្នែកដែលកំណត់ទៅតាមភាគ រីឯអច្ច័យទានមានកំណត់ គឺជាប្រទានកម្មដែលកំណត់ទ្រព្យសម្បត្តិជាក់លាក់ ទៅឱ្យមនុស្សម្នាក់ ឬ ច្រើននាក់ ដោយមតកសាសន៍ ។

**មាត្រា ១២០០.–** មរណភាពរបស់អច្ច័យលាភី

១-អច្ច័យទានពុំបង្កើតអានុភាពឡើយ បើអច្ច័យលាភីបានទទួលមរណភាព នៅមុន ឬ ក្នុងពេលដែលម្ចាស់បណ្ដាំទទួលមរណភាព ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអច្ច័យទានភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ ហើយអច្ច័យលាភីបានទទួលមរណភាព នៅមុនពេលដែលល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញ ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ បើម្ចាស់បណ្ដាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

៣-ក្នុងករណីដែលសន្តតិជនដែលត្រូវបានសន្មត ជាអច្ច័យលាភី បញ្ញត្តិនៃកថា-ខណ្ឌទី ១ ខាងលើនេះ មិនរារាំងចំពោះការយកបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ១១៩៦ (មរណភាពនៃជនដែលត្រូវបានសន្មតថាជាសន្តតិជន ជាអាទិ៍) នៃក្រមនេះ មកអនុវត្តឡើយ ។

**មាត្រា ១២០១.–** ការបោះបង់អច្ច័យទាន

១-នៅក្រោយពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព អច្ច័យលាភីអាចបោះបង់អច្ច័យទាន នៅពេលណាក៏បាន ។ ប៉ុន្តែ ចំពោះការបោះបង់អច្ច័យទានសកល ត្រូវអនុលោមតាមបញ្ញត្តិស្តីពីការបោះបង់សន្តតិកម្ម ។

២-ការបោះបង់អច្ច័យទាន ត្រូវមានអានុភាពប្រតិសកម្ម ចាប់ពីពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ។

**មាត្រា ១២០២.–** ការដាស់តឿនរបស់ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍

បុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធទៅនឹងអច្ច័យទាន ឬ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ អាចដាស់តឿនឱ្យអច្ច័យលាភីទទួលស្គាល់ ឬ បោះបង់អច្ច័យទានបាន ដោយកំណត់អំឡុងពេលសមរម្យ ។ បើអច្ច័យលាភីមិនបានបង្ហាញឆន្ទៈ ចំពោះបុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធទៅនឹងអច្ច័យទាន នៅក្នុងអំឡុងពេលដែលបានកំណត់នោះទេ ត្រូវចាត់ទុកថា អច្ច័យលាភីបានទទួលស្គាល់អច្ច័យទាននោះ ។

**មាត្រា ១២០៣.–** ការបោះបង់ ឬ ការទទួលស្គាល់ ដោយសន្តតិជនរបស់អច្ច័យលាភី

បើអច្ច័យលាភីបានទទួលមរណភាព ដោយមិនបានទទួលស្គាល់ ឬ បោះបង់អច្ច័យទានទេ សន្តតិជនរបស់អច្ច័យលាភីនោះ អាចទទួលស្គាល់ ឬ បោះបង់អច្ច័យទានបាន ត្រឹមទំហំនៃសិទ្ធិលើសន្តតិកម្មរបស់ខ្លួន ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

**មាត្រា ១២០៤.–** ការលុបចោលនូវការទទួលស្គាល់ ឬ ការបោះបង់

១-ការទទួលស្គាល់ ឬ ការបោះបង់អច្ច័យទាន ពុំអាចលុបចោលវិញបានទេ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១២៥២ (ការលុបចោលការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការទទួលស្គាល់ និងការបោះបង់អច្ច័យទាននេះ ។

**មាត្រា ១២០៥.–** ការទទួលស្គាល់ ឬ បោះបង់ ក្នុងករណីដែលអច្ច័យលាភីជាសន្តតិជន

១-ក្នុងករណីដែលអច្ច័យលាភីជាសន្តតិជន បើបានបោះបង់សន្តតិកម្ម បុគ្គលនោះ ត្រូវបានចាត់ទុកថាបានបោះបង់អច្ច័យទានផងដែរ ។ អច្ច័យលាភីនោះ មិនអាចទទួលស្គាល់អច្ច័យទាន ដោយបោះបង់សន្តតិកម្មបានឡើយ ។

២-ទោះបីបានទទួលស្គាល់សន្តតិកម្មហើយក៏ដោយ ក៏អច្ច័យលាភីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចបោះបង់អច្ច័យទានមានកំណត់ បានដែរ ។

**មាត្រា ១២០៦.–** សិទ្ធិទទួលផលរបស់អច្ច័យលាភី

អច្ច័យលាភីអាចទទួលផល ចាប់តាំងពីពេលដែលខ្លួនអាចទាមទារឱ្យអនុវត្តអច្ច័យ-ទានបាន ។ ប៉ុន្តែ បើម្ចាស់បណ្ដាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

**មាត្រា ១២០៧.–** អច្ច័យទាននៃសិទ្ធិដែលមិនស្ថិតនៅក្នុងមតិក

អច្ច័យទាន ពុំមានអានុភាពឡើយ បើសិទ្ធិដែលជាកម្មវត្ថុនៃអច្ច័យទាននោះ ពុំស្ថិតនៅក្នុងមតិក នៅពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព ។

**មាត្រា ១២០៨.–** អច្ច័យទាននៃវត្ថុ ឬ សិទ្ធិដែលភ្ជាប់ជាមួយនឹងសិទ្ធិរបស់តតិយជន

បើវត្ថុ ឬ សិទ្ធិ ដែលជាកម្មវត្ថុនៃអច្ច័យទាន ជាកម្មវត្ថុនៃសិទ្ធិរបស់តតិយជន នៅពេលដែលម្ចាស់បណ្ដាំទទួលមរណភាព អច្ច័យលាភីមិនអាចទាមទារឱ្យរំលត់សិទ្ធិនោះចំពោះជនដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទានបានឡើយ ។

**មាត្រា ១២០៩.–** ឧបាទេសកម្មលើវត្ថុ

១-បើម្ចាស់បណ្ដាំមានសិទ្ធិទាមទារប្រាក់សំណង ចំពោះតតិយជន ដោយការបាត់បង់ ឬ កែបន្លំវត្ថុដែលជាកម្មវត្ថុនៃអច្ច័យទាន ឬ បាត់បង់ការកាន់កាប់វត្ថុនោះ ត្រូវសន្មតថាបានយកសិទ្ធិនោះ មកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។

២-ក្នុងករណីដែលវត្ថុដែលជាកម្មវត្ថុនៃអច្ច័យទាន មានភាពជាប់គ្នា លាយគ្នា ឬ

ច្របល់គ្នានឹងវត្ថុផ្សេងទៀត បើម្ចាស់បណ្ដាំបានក្លាយជាកម្មសិទ្ធិករតែឯង ឬ ជាម្ចាស់កម្មសិទ្ធិអវិភាគនៃវត្ថុដែលបានផ្សំ ដោយយោងតាមបញ្ញត្តិនៃមាត្រា ១៨៦ (ការជាប់គ្នារវាងចលនវត្ថុ និង អចលនវត្ថុ) ឬ មាត្រា ១៩៨ (ការជាប់គ្នា ការលាយច្របល់គ្នានៃចលនវត្ថុ) នៃក្រមនេះ ត្រូវសន្មតថា ម្ចាស់បណ្ដាំបានយកកម្មសិទ្ធិទាំងអស់ ឬ កម្មសិទ្ធិអវិភាគនោះ មកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។

**មាត្រា ១២១០.–** ឧបាទេសកម្មលើវត្ថុ នៃអច្ច័យទាននៃសិទ្ធិលើបំណុល

១-ក្នុងករណីដែលសិទ្ធិលើបំណុលត្រូវបានយកមកធ្វើជាកម្មវត្ថុនៃអច្ច័យទាន បើម្ចាស់បណ្ដាំបានទទួលសំណង ហើយបើវត្ថុដែលបានទទួលនោះ នៅតែមានក្នុងមត៌ក ត្រូវសន្មតថាបានយកវត្ថុនោះមកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។

២-ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ត្រូវសន្មតថាបានយកប្រាក់ និង ប្រាក់បញ្ញើ មកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ត្រឹមកម្រិតនៃប្រាក់ដែលមាននៅក្នុងមត៌ក និង ប្រាក់ដែលបានបញ្ចូលក្នុងប្រាក់បញ្ញើ ក្រោយពីបានសង ។

**មាត្រា ១២១១.–** ការទទួលខុសត្រូវរបស់អច្ច័យលាភី នៅក្នុងអច្ច័យទានភ្ជាប់បន្ទុក

១-ជនដែលបានទទួលអច្ច័យទានភ្ជាប់បន្ទុក ត្រូវទទួលខុសត្រូវក្នុងការអនុវត្តករណីយកិច្ចដែលខ្លួនទទួលបន្ទុក ត្រឹមតែកម្រិតដែលមិនលើសពីតម្លៃនៃកម្មវត្ថុនៃអច្ច័យទាននោះប៉ុណ្ណោះ ។

២-បើតម្លៃនៃកម្មវត្ថុនៃអច្ច័យទានភ្ជាប់បន្ទុក បានចុះថយ ដោយសារការទទួលស្គាល់សន្តតិកម្មដោយមានកម្រិត ឬ ដោយសារការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង អច្ច័យលាភីត្រូវរួចផុតពីករណីយកិច្ចដែលខ្លួនត្រូវទទួលបន្ទុក តាមសមាមាត្រនៃភាគដែលចុះថយនោះ ។ ប៉ុន្តែ បើម្ចាស់បណ្ដាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

**មាត្រា ១២១២.–** សិទ្ធិ និង ករណីយកិច្ចរបស់អច្ច័យលាភីសកល

១-អច្ច័យលាភីសកល មានសិទ្ធិ និង ករណីយកិច្ច ដូចគ្នានឹងសន្តតិជន ។

២-បើមត៌កទាំងអស់ត្រូវបានធ្វើអច្ច័យទានសកលឱ្យទៅបុគ្គលផ្សេងដែលមិនមែនជាសន្តតិជន សន្តតិជនត្រូវបានចាត់ទុកថា មិនបានទទួលសន្តតិកម្ម លើកលែងតែសិទ្ធិលើភាគបម្រុង ។

## ផ្នែកទី ៧
## ការប្រតិបត្តិមតកសាសន៍

**មាត្រា ១២១៣.–** ការពិនិត្យបញ្ជាក់ និង ការបើកលិខិតមតកសាសន៍

១-អ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ ត្រូវដាក់ពាក្យសុំការបញ្ជាក់លិខិតនោះ ដោយភ្ជាប់លិខិតមតកសាសន៍នោះ ជូនទៅតុលាការ ដោយគ្មានការយឺតយ៉ាវ ក្រោយពីខ្លួនបានដឹងអំពីការចាប់ផ្ដើមសន្តតិកម្ម ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលគ្មានអ្នកថែរក្សាគ្រប់គ្រង ក្រោយពេលដែលសន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ផ្សេងទៀត បានរកឃើញលិខិតមតកសាសន៍នោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះមតកសាសន៍ដែលបានធ្វើដោយលិខិតយថាភូត ។

៣-លិខិតមតកសាសន៍ដែលបិទដោយប្រថាប់ត្រា អាចបើកបានតែនៅតុលាការ ដោយមានវត្តមានរបស់អ្នកសង្កេតការណ៍ជាសន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ ឬ អ្នកតំណាងរបស់ជននោះ ។

៤-បុគ្គលដែលបានបើកលិខិតមតកសាសន៍ នៅក្រៅតុលាការ ដោយផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ នឹងត្រូវពិន័យស៊ីវិលជាប្រាក់ មិនលើសពី ១.០០០.០០០ (មួយលាន) រៀល ។

៥-ចំពោះលិខិតមតកសាសន៍ ទោះបីជាបានបើកនៅក្រៅតុលាការ ដោយផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ក៏ដោយ មិនត្រូវបាត់បង់អានុភាព ដោយសារតែមូលហេតុនោះឡើយ ។

**មាត្រា ១២៦៤.-** ការកំណត់អ្នកប្រតិបត្តិមតកសាសន៍

១-បើម្ចាស់បណ្តាំបានប្រគល់អាណត្តិឱ្យតតិយជនកំណត់អ្នកប្រតិបត្តិមតកសាសន៍តាមមតកសាសន៍ ជនដែលបានទទួលអាណត្តិ ត្រូវកំណត់អ្នកប្រតិបត្តិមតកសាសន៍ ហើយត្រូវជូនដំណឹងនោះទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

២-បើជនដែលបានទទួលអាណត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មានបំណងលាឈប់ពីអាណត្តិនោះ ជននោះត្រូវជូនដំណឹងអំពីហេតុនោះ ទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

**មាត្រា ១២៦៥.-** ការកាន់មុខងាររបស់អ្នកប្រតិបត្តិមតកសាសន៍

បើអ្នកប្រតិបត្តិមតកសាសន៍ បានយល់ព្រមកាន់មុខងារហើយ អ្នកប្រតិបត្តិមតក-សាសន៍នោះ ត្រូវអនុវត្តភារកិច្ចនោះ ភ្លាមៗ ។

**មាត្រា ១២៦៦.-** ការដាស់តឿនឱ្យអ្នកប្រតិបត្តិមតកសាសន៍កាន់មុខងារ

១-សន្តតិជន ឬ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ផ្សេងទៀត អាចកំណត់អំឡុងពេលសមរម្យ ហើយដាស់តឿន ចំពោះជនដែលត្រូវបានកំណត់ជាអ្នកប្រតិបត្តិមតក-សាសន៍ ឱ្យឆ្លើយបញ្ជាក់ច្បាស់ក្នុងអំឡុងពេលនោះ អំពីការយល់ព្រម ឬ មិនយល់ព្រមកាន់មុខងារជាអ្នកប្រតិបត្តិមតកសាសន៍បាន ។ បើអ្នកប្រតិបត្តិមតកសាសន៍ មិនបានឆ្លើយបញ្ជាក់ច្បាស់ ក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថា បានលាឈប់ពីការងារនោះ ។

២-បញ្ញត្តិនៃវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលតតិយជន ដែលត្រូវបានប្រគល់អាណត្តិឱ្យកំណត់អ្នកប្រតិបត្តិមតកសាសន៍ ពុំបានកំណត់អ្នកប្រតិបត្តិមតកសាសន៍ ឱ្យបានឆាប់រហ័ស ។ ក្នុងករណីនេះ បើតតិយជននោះមិនបានកំណត់អ្នកប្រតិបត្តិមតកសាសន៍ នៅក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថា បានលាឈប់ពីអាណត្តិនោះ ។

**មាត្រា ១២៦៧.-** បុគ្គលដែលមិនអាចក្លាយជាអ្នកប្រតិបត្តិមតកសាសន៍

ជននៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមហិត្តបត្ថម្ភ អនីតិជន និង ជន

ធនក្ស័យ ពុំអាចធ្វើជាអ្នកប្រតិបត្តិមតកសាសន៍បានឡើយ ។

**មាត្រា ១២១៨.–** ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍

បើគ្មានអ្នកប្រតិបត្តិមតកសាសន៍ទេ ឬ បើបាត់បង់អ្នកប្រតិបត្តិមតកសាសន៍ តុលាការអាចជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍បាន តាមការទាមទាររបស់សន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ ។

**មាត្រា ១២១៩.–** ការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ

១-អ្នកប្រតិបត្តិមតកសាសន៍ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ ហើយប្រគល់បញ្ជីសារពើភ័ណ្ឌនោះទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

២-សន្តតិជន អាចមានវត្តមាន នៅពេលដែលអ្នកប្រតិបត្តិមតកសាសន៍ ធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិបាន ។

**មាត្រា ១២២០.–** សិទ្ធិអំណាច មុខនាទី នៃអ្នកប្រតិបត្តិមតកសាសន៍

អ្នកប្រតិបត្តិមតកសាសន៍ មានសិទ្ធិ និង ករណីយកិច្ចក្នុងការគ្រប់គ្រងមត៌ក និង ធ្វើនូវរាល់សកម្មភាពផ្សេងទៀតដែលចាំបាច់ ដើម្បីប្រតិបត្តិមតកសាសន៍ ។

**មាត្រា ១២២១.–** ការបាត់បង់នូវសិទ្ធិចាត់ចែងរបស់សន្តតិជន

១-បើមានអ្នកប្រតិបត្តិមតកសាសន៍ សន្តតិជនពុំអាចចាត់ចែងមត៌ក ឬ ធ្វើសកម្មភាពផ្សេងទៀតដែលនាំឱ្យរារាំងដល់ការប្រតិបត្តិមតកសាសន៍បានឡើយ ។

២-ការចាត់ចែងដែលបានធ្វើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុភាពឡើយ ។

**មាត្រា ១២២២.–** ការប្រតិបត្តិមតកសាសន៍ ចំពោះទ្រព្យសម្បត្តិដែលបានកំណត់ជាក់លាក់

ក្នុងករណីមតកសាសន៍ ទាក់ទងនឹងទ្រព្យសម្បត្តិដែលបានកំណត់ជាក់លាក់ បញ្ញត្តិចាប់ពីមាត្រា ១២១៩ (ការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ) រហូតដល់មាត្រា ១២២១

(ការបាត់បង់នូវសិទ្ធិចាត់ចែងរបស់សន្តតិជន) នៃក្រមនេះ ត្រូវយកមកអនុវត្ត ចំពោះតែទៅលើទ្រព្យសម្បត្តិនោះប៉ុណ្ណោះ ។

**មាត្រា ១២២៣.–** ឋានៈនៃអ្នកប្រតិបត្តិមតកសាសន៍

១-អ្នកប្រតិបត្តិមតកសាសន៍ ត្រូវធ្វើសកម្មភាព នៅក្នុងនាមជាអ្នកប្រតិបត្តិមតក-សាសន៍ ចំពោះមតិកដែលខ្លួនត្រូវប្រតិបត្តិ ។

២-សកម្មភាពដែលអ្នកប្រតិបត្តិមតកសាសន៍បានធ្វើជាមុខនាទី ត្រូវមានអានុភាពផ្ទាល់ ចំពោះសន្តតិជន ។

**មាត្រា ១២២៤.–** សិទ្ធិជ្រើសតាំងបន្តរបស់អ្នកប្រតិបត្តិមតកសាសន៍

១-បើគ្មានមូលហេតុដែលពុំអាចជៀសវាងបានទេ អ្នកប្រតិបត្តិមតកសាសន៍ ពុំអាចឱ្យតតិយជនអនុវត្តភារកិច្ចរបស់ខ្លួនបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេង នៅក្នុងមតកសាសន៍ ។

២-ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍ បានឱ្យតតិយជនអនុវត្តភារកិច្ចរបស់ខ្លួន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អ្នកប្រតិបត្តិមតកសាសន៍នោះត្រូវទទួលខុសត្រូវក្នុងការជ្រើសតាំង និង ការត្រួតពិនិត្យជននោះ ចំពោះអច្ច័យលាភី និង សន្តតិជន ។ បើអ្នកប្រតិបត្តិមតកសាសន៍ បានឱ្យតតិយជនអនុវត្តភារកិច្ចនោះ ដោយផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវសងសំណងនៃការខូចខាត ដែលកើតឡើងដោយសារហេតុនោះ ចំពោះអច្ច័យលាភី និង សន្តតិជន ។

**មាត្រា ១២២៥.–** សហអ្នកប្រតិបត្តិមតកសាសន៍

១-ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍មានច្រើននាក់ ការអនុវត្តភារកិច្ចនោះត្រូវសម្រេចដោយសម្លេងលើសពីពាក់កណ្តាល ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ អ្នកប្រតិបត្តិមតក-សាសន៍នីមួយៗ អាចធ្វើសកម្មភាពរក្សាទុកបាន ។

**មាត្រា ១២២៦.–** កម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍

១-អ្នកប្រតិបត្តិមតកសាសន៍ អាចទទួលកម្រៃដែលបានកំណត់នៅក្នុងមតកសាសន៍បាន ។

២-ក្នុងករណីដែលមតកសាសន៍ពុំបានកំណត់កម្រៃទេ តុលាការត្រូវកំណត់ចំនួនទឹកប្រាក់នៃកម្រៃនោះ តាមពាក្យសុំរបស់អ្នកប្រតិបត្តិមតកសាសន៍ បើយល់ឃើញថាសមរម្យក្នុងការបង់កម្រៃ ដោយពិចារណាទៅលើស្ថានភាពនៃមតិក ទំនាក់ទំនងរវាងម្ចាស់បណ្តាំ និង អ្នកប្រតិបត្តិមតកសាសន៍ និង ស្ថានភាពផ្សេងទៀត ។

**មាត្រា ១២២៧.–** ការលាឈប់ និង ការបញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍

១-បើមានមូលហេតុត្រឹមត្រូវ អ្នកប្រតិបត្តិមតកសាសន៍ អាចលាឈប់ពីភារកិច្ចបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

២-បើអ្នកប្រតិបត្តិមតកសាសន៍ បានធ្វេសប្រហែសក្នុងភារកិច្ច ឬ បើមានមូលហេតុត្រឹមត្រូវផ្សេងទៀត អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ អាចដាក់ពាក្យសុំទៅតុលាការឱ្យបញ្ឈប់ជននោះបាន ។

**មាត្រា ១២២៨.–** សោហ៊ុយនៃការប្រតិបត្តិមតកសាសន៍

សោហ៊ុយដែលទាក់ទងទៅនឹងការប្រតិបត្តិមតកសាសន៍ ត្រូវជាបន្ទុកនៃមតិក ។ ប៉ុន្តែ មិនអាចបន្ថយភាគបម្រុង ដោយសារបន្ទុកនេះឡើយ ។

**មាត្រា ១២២៩.–** ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីអាណត្តិ

បញ្ញត្តិស្តីពីអាណត្តិ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះមុខនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍ លើកលែងតែមានភាពផ្ទុយនឹងលក្ខណៈនៃតួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍នោះ ។